ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Oct-2012, 15:54
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០៥ នាទី**

**សវនាការលើកទី១២២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វ៉េង ហ៊ត់

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ *(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក វ៉ែន ពៅ

លោកស្រី ម៉ុច សុវណ្ណារី

លោក ឡៅ ជុនធី

លោក គឹម ម៉េងឃី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្នួរ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោកស្រី ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក សុខ ឈិន (TCW-661) | ខ្មែរ |
| លោកស្រី ឡាយ បូនី (TCCP-64) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី ÷ លោក សុខ ឈិន** (TCW-661)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖......ទំព័រ ២
សួរដោយលោក វេង ហ៊ត់ ផ្តើមពី៖ ......ទំព័រ ៦
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖......ទំព័រ ១៤
សួរដោយលោក វ៉ែន ពៅ ផ្តើមពី៖......ទំព័រ ៣១
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី៖......ទំព័រ ៣៦
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖......ទំព័រ ៤៥
សួរដោយលោក ហ្សាស្តេ ប៉ៅ ផ្តើមពី៖ ......ទំព័រ ៤៦

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី÷ លោកស្រី ឡាយ បូនី** (TCCP-64)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖......ទំព័រ ៦៧
សួរដោយលោកស្រី ម៉ុច សុវណ្ណារី ផ្តើមពី៖......ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៣៣]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាដំបូងនេះអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនឲ្យបានជ្រាបថា អង្គជំនុំជម្រះនៅថ្ងៃនេះគឺគ្រោងស្ដាប់សក្ខីកម្មបុគ្គលមួយរូប ក្នុងឋានៈជាសាក្សី ពុំមែនជាដើមបណ្ដឹងរដ្ឋប្បវេណីទេ។ គឺសាក្សីដែលមានរហស្សនាម TCW-661 ដែលនឹងផ្ដើមសួរសំណួរដំបូងមុនភាគីឯទៀត ដោយតំណាងសហព្រះរាជអាជ្ញា ដោយមានការភ័ន្តច្រឡំពីម្សិលមិញ។

ហើយទន្ទឹមនឹងនេះក៏អង្គជំនុំជម្រះបានរៀបចំនូវ កោះអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបដែលមានរហស្សនាម TCCP-64 មកជាការបម្រុងទុកផងដែរ។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្ដីមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី អវត្តមានដោយមូលហេតុសុខភាព។ ប៉ុន្តែយោងតាមពាក្យសុំលះបង់សិទ្ធិរបស់ជនជាប់ចោទ ឯកសារលេខ E237 ជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងដំណើរការសវនាការនៃការស្ដាប់សក្ខីកម្មសាក្សីនិងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន។ ក្នុងនោះមានសាក្សី TCW-661 ដែលអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មនៅក្នុងថ្ងៃនេះ និងដើមបណ្ដឹងរដ្ឋប្បវេណីបម្រុងមួយរូប គឺ TCCP-64។

លោក អាកទួរ វែកគែន មេធាវីអន្តរជាតិការពារឲ្យលោក ខៀវ សំផន អវត្តមាន ដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។ ដោយឡែកសាក្សី TCW-661 មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់

ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប គឺលោក នួន ជា, អៀង សារី និង ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ -- នៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សូមអរគុណ។

[០៩:០៨:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អង្គជំនុំជម្រះសូមបញ្ជាក់ឡើងវិញថា អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ គាត់សុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការ ពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីចំនួន១០រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំមួយរូប។ ក្នុងចំណោមសាក្សីចំនួន១០រូប ក៏មានឈ្មោះសាក្សីដែលមានរហស្សនាម TCW-661 ម្នាក់ដែរ។

យោងតាមរបាយការណ៍គ្រូពេទ្យនៃមន្ទីរមិត្តភាពខ្មែរ-សូវៀត ដែលទទួលព្យាបាលលោក អៀង សារី ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ បញ្ជាក់ថាលោក អៀង សារី បច្ចុប្បន្នកំពុងតែសម្រាកទទួលការព្យាបាលនៅផ្នែកទូទៅនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ ហើយនៅពេលនេះលោក អៀង សារី ស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដោយមានដែនកំណត់។ ដោយគាត់មានសុខភាព -- មានបញ្ហាសុខភាពត្រូវសម្រាក ដើម្បីទទួលការព្យាបាលនៅមន្ទីរពេទ្យ តែរូបកាយនិងស្មារតីសមស្រប។ អង្គជំនុំជម្រះសម្រេចធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-661 ដោយមិនមានវត្តមានលោក អៀង សារី ដោយអនុវត្តតាមវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-661 ចូលមកកាន់បន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១២:០៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីសាក្សី! តើលោកឈ្មោះអី?

**លោក សុខ ឈិន៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** លោកៗអាចអង្គុយចុះ លោកអង្គុយចុះ ហើយលោករង់ចាំ ក្បាលមីក្រូនេះ ឲ្យសញ្ញាក្រហម ឬក៏មានភ្លើងក្រហមនៅផ្នែកខាងក្រោមនៃឧបករណ៍ហ្នឹង សូមលោកឆ្លើយ។ នោះទើបសំឡេងរបស់លោកចូលនឹងប្រព័ន្ធសំឡេង ដែលអាចនឹងបកប្រែជាភាសាអង់គ្លេស និងភាសាបារាំង ផងដែរ។ ម្តងទៀត តើលោកឈ្មោះអី?

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំបាទឈ្មោះ សុខ ឈិន។

**ស៖** បាទ អរគុណ លោក សុខ ឈិន ហើយតើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំមានអាយុ៦៧ឆ្នាំ ឆ្នាំនេះបាទ។

**ស៖** បាទ អរគុណ។ ហើយលោក សុខ ឈិន តើទីលំនៅសព្វថ្ងៃរស់នៅទីកន្លែងណា? ហើយប្រកបមុខរកស៊ីធ្វើអ្វី?

[០៩:១៣:១៧]

**ឆ៖** ទីលំនៅសព្វថ្ងៃ នៅផ្ទះលេខ១៣ ក្រុមសាមគ្គី ភូមិកំពង់ក្របី ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

**ស៖** លោកប្រកបមុខរកស៊ីធ្វើអ្វីដែរសព្វថ្ងៃ?

**ឆ៖** ខ្ញុំបាទជានិវត្តន៍ជន។

**ស៖** បាទ អរគុណ។ ចុះឪពុករបស់លោក -- ឪពុកបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** គាត់ឈ្មោះ សុខ ស៊ុក។ ស្លាប់។

**ស៖** ចុះម្តាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** គាត់ឈ្មោះ យិន នួន។ ស្លាប់។

[០៩:១៤:១១]

**ស៖** ប្រពន្ធរបស់លោក គាត់ឈ្មោះអីដែរ?

**ឆ៖** គ្រួច សារឿយ នៅរស់នៅជាមួយនឹងខ្ញុំសព្វថ្ងៃ។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** កូនខ្ញុំមានប្រាំនាក់។

**សះ** បាទ អរគុណ។ ហើយលោក សុខ ឈិន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ អម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធ ជាមួយនឹងបុគ្គលដែលត្រូវទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះទេ។ ហើយក៏មិនជាប់ ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីនាក់ដែរ គឺលោក នួន ជា, លោក អៀង សារី និង លោក ខៀវ សំផន។ តើជាការពិតមែនដែរឬទេ?

[០៩:១៥:០៣]

**ឆះ** បាទ ជាការពិត។

**សះ** ហើយតាមរបាយការណ៍ដដែល អម្បាញ់មិញនេះថា លោកបានធ្វើសម្បថមុខអ្នកតាដំបង ដែករួចហើយ មុននឹងចូលមកបន្ទប់សវនាការនេះ។ តើពិតមែនដែរឬទេ?

**ឆះ** ពិតមែន។

**សះ** បាទ ឥឡូវនេះអង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សី ចំពោះមុខអង្គជំនុំជម្រះអំពីសិទ្ធិលោក សុន ឈិន នៅក្នុងនាមលោកជាសាក្សី នៅក្នុងកិច្ចដំណើរការ នីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើ អំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីយកិច្ច លោក សុខ ឈិន ក្នុងនាមលោកជាសាក្សី ត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយ ដែលភាគី ឬអង្គជំនុំជម្រះបានសួរចំពោះលោក។ លោកជាសាក្សីត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ ចងចាំ ឬក៏ធ្លាប់ មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់ នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមបានសួរលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ច ក្នុងនាមជាសាក្សីនេះដែរឬទេ?

[០៩:១៦:៣៩]

**ឆះ** បាទខ្ញុំយល់។

**សះ** លោក សុខ ឈិន តើលោកធ្លាប់បានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃ ការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ កន្លងមក ប៉ុន្មានឆ្នាំមុននេះ? ហើយប្រសិនដែលធ្វើ

តើប្រព្រឹត្តទៅប៉ុន្មានដង ហើយធ្វើនៅកន្លែងណា នៅពេលណា?

**ឆ៖** ខ្ញុំបាទបានធ្លាប់ធ្វើម្តង គឺនៅក្នុងទីលំនៅរបស់ខ្ញុំ បាទទីលំនៅបច្ចុប្បន្នជាក់ស្តែង។

**ស៖** នៅពេលណាដែរ លោកចាំដែរទេ?

**ឆ៖** បាទ ខ្ញុំមិនបានចាំ។

**ស៖** បាទ អរគុណ។ ហើយមុនពេលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោក សុខ ឈិន បានពិនិត្យមើល ឬក៏បានអាន នូវកំណត់ហេតុស្តាប់សក្ខីកម្មរបស់លោក ដែលបានធ្វើជាមួយអ្នកស៊ើបអង្កេតកន្លងមកដែរឬទេ ដើម្បីរំឭកការចងចាំនោះ?

[០៩:១៧:៤៩]

**ឆ៖** ខ្ញុំបានមើលម្តងពីរដងដែរ។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង និងចាំ ថាតើលោកអាចបញ្ជាក់បានទេ ថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ ឬវាសមស្រប ស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសជាមួយអ្នកស៊ើបអង្កេតពេលមុននោះដែរឬទេ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ និងស៊ីសង្វាក់គ្នា។

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

ហើយអង្គជំនុំជម្រះសូមជម្រាបជូនតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀត។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបរំឭកជូនតំណាងសហព្រះរាជអាជ្ញាផងដែរថា ក្នុងការសួរដេញដោលសាក្សីរូបនេះ គឺទាំងសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលតែកន្លះថ្ងៃទេ គឺ១ព្រឹកនេះតែប៉ុណ្ណោះ។ សូមជ្រាប។

សូមអញ្ជើញ!

[០៩:១៩:០០]

**លោក លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។ សូមគោរពលោកប្រធាន! សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ! ហើយ

សួស្តីមិត្តភក្តិរួមការងារទាំងអស់ ដែលនៅទីនេះ។

សួស្តីលោក សុខ ឈិន។ ខ្ញុំឈ្មោះ វ៉េង ហ៊ត់ មកពីការិយាល័យសហព្រះរាជអាជ្ញា។ បន្តិចទៀតនេះ ខ្ញុំមានសំណួរខ្លះៗចង់ឲ្យលោកជួយបំភ្លឺ។ ប្រសិនបើលោកមិនយល់នឹងសំណួរខ្ញុំ លោក សុខ ឈិន អាចសុំទៅលោកប្រធាន ឬក៏សុំឲ្យខ្ញុំសួរម្តងទៀតបាន។ ខ្ញុំរីករាយនឹងទទួល។

[០៩:១៩:៥១]

តទៅនេះ លោកប្រធានខ្ញុំសូមជូនឯកសារ D232/76 ជូនទៅសាក្សី ដើម្បីនៅពេលដែលយើងខ្ញុំក្រុមការងារព្រះរាជអាជ្ញាបង្ហាញ ងាយស្រួលឲ្យគាត់បានឃើញផងបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** សួស្តីលោក សុខ ឈិន! លោកកុំអានទាន់មើលឯកសារនេះ នៅពេលដែលខ្ញុំបង្ហាញចំណុចណាដែលលោកមើល ចាំលោកមើល។ ហើយតទៅនេះ ខ្ញុំសូមអនុញ្ញាតសួរលោក។

ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំចង់ដឹងថា តើលោកមានភារកិច្ចធ្វើអ្វីដែរបាទ?

[០៩:២១:២២]

**លោក សុខ ឈិន៖**

**ឆ៖** ខ្ញុំបាទធ្វើជាបុគ្គលិកនៅក្នុងក្រុមហ៊ុនដឹកជញ្ជូនផ្លូវដែកកម្ពុជា កាលពីដើមឈ្មោះរាជាយ-ស្ម័យយានកម្ពុជា។

**ស៖** ខ្ញុំចង់សួរលោកក្រោយថ្ងៃ១៧ មេសា អត់សួរមុនហ្នឹងទេបាទ។

**ឆ៖** ខ្ញុំធ្វើជាកម្មករ កម្មករជួសជុលផ្លូវដែក។

**ស៖** លោកធ្វើកម្មករនេះក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់បុគ្គលណាមួយដែរ?

**ឆ៖** ក្រោមការគ្រប់គ្រងរបស់កងទ័ពខ្មែរក្រហម។ ឈ្មោះក្រោមរបបយោធាខ្មែរក្រហម។

**ស៖** ខ្ញុំចង់ដឹងបន្ថែមទៀត ក្រោមការគ្រប់គ្រងរបស់យោធា ក៏ប៉ុន្តែបុគ្គលទាំងនោះ យោធានោះ គាត់ឈ្មោះអីដែលជាមេចាត់តាំងលោកហ្នឹង?

[០៩:២២:៥៦]

**ផ៖** គាត់ឈ្មោះ តាមូម។

**ស៖** អរគុណលោក។ នៅក្នុងឯកសារលេខ ឆ.៧ សូមលោកលើកឯកសារនុំងមើលទៅ មានលេខ ឆ.៧។ ពណ៌រាងត្រួយចេក។ ឆ.៧ ត្រង់នេះ ខ្ញុំសួរថា ហេតុអ្វីលោកដឹងថា តាមូម គ្រប់គ្រងប្រជាជនរាប់ពាន់នាក់ រួមទាំងកុមារផង? តើលោកដឹង តាមូម គ្រប់គ្រងតាមវិធីអីដែរបាទ?

**ផ៖** គាត់ជាអ្នកក្តោបក្តាប់ទាំងនារី ទាំងកុមារ ទាំងអស់នៅក្នុងៗក្រុមហ៊ុនហ្នឹង នៅក្នុងកំបន់ហ្នឹងទាំងអស់។

**ស៖** ខ្ញុំដឹងបន្តទៀត តើពាក្យក្នុងន័យដែលលោកបានបង្ហាញនេះថា "គ្រប់គ្រង" ក្នុងន័យ "គ្រប់គ្រង" នេះ គឺពាក្យថា "គ្រប់គ្រង" បានន័យថាបង្ខំឲ្យធ្វើការ ឬមួយក៏ក្នុងន័យគ្រប់គ្រងផ្សេងពីនេះបាទ?

**ផ៖** គ្រប់គ្រងបង្ខំឲ្យធ្វើការ ហើយឲ្យរៀននយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

**ស៖** ចុះចំពោះកុមារតូចៗ តើ តាមូម នេះគាត់ជាអ្នកឲ្យរៀននយោបាយរបៀបម៉េចដែរ ឬមួយក៏បង្ខំឲ្យធ្វើការយ៉ាងដូចម្តេចដែរ ដែលលោកបានឃើញជាក់ស្តែងនោះ?

[០៩:២៥:០៤]

**ផ៖** កុមារតូចៗក្រោមប្រាំមួយឆ្នាំឲ្យនៅជាមួយនឹងមណ្ឌលកុមារ ឯលើពីប្រាំមួយឆ្នាំឡើងទៅទៅធ្វើពលកម្មនៅតាមតំបន់ៗផ្សេងៗ កន្លែងផ្សេងៗ។

**ស៖** អរគុណលោក។ យើងខ្ញុំក្រុមការងារព្រះរាជអាជ្ញា ក៏មានចម្ងល់ផងដែរ ហើយនិងសូមឲ្យលោកជួយបង្ហាញហេតុផលដូចជាថា រទេះភ្លើងក្រឡាប់ពួកគេនឹងយកយើងទៅវាយចោល។ នៅក្នុង ឆ.៧ ដដែលនេះខ្ញុំចង់ដឹងថា តើនៅក្នុងសម័យនោះដែលមានរទេះភ្លើងក្រឡាប់ទេ? ទី១។ ទី២ តើមានគេយកមនុស្សទៅវ៉ៃចោលដោយសាររទេះភ្លើងក្រឡាប់ឬទេ? ហើយទី៣ ប្រសិនបើលោកមិនដឹងហេតុផលទី១, ទី២, ទី៣ តើលោកដឹងព័ត៌មាននេះថ្នាក់ដឹកនាំណាខ្លះ?

[០៩:២៦:៣៦]

**ផ៖** ខ្ញុំមិនបានដឹងទេ ប៉ុន្តែឯកសារគេ តាមូម គាត់បង្ហាត់អីចឹង ៗ ថាយើងត្រូវប្រយ័ត្នប្រយែងក្នុងការងារ ប្រយ័ត្នតែមានរទេះភ្លើងភ្លូក ឬធ្លាក់ យើងត្រូវគេយកទៅវ៉ៃចោលហើយបាទ។

**ស៖** អរគុណលោក។ នៅក្នុងសំណួរដដែលនេះ លោកបានសំដៅទៅលើពាក្យមួយ លោកថា "ពួកគេ -- ពួកគេនឹងយកមនុស្សទៅវ៉ៃចោល" តើពួកគេនេះលោកអាចបង្ហាញអង្គសវនាការបានទេថា ពួកគេនេះ គឺសំដៅលើអ្នកណា?

**ឆ៖** ពួកគេនេះ សំដៅទៅលើ តាមូច តែម្តង និងយោធាដែលនៅក្រោមបង្គាប់ តាមូច។

**ស៖** អរគុណលោក។ ខ្ញុំថែមសំណួរមួយទៀត នៅក្នុង ឆ.១៣ លោកអាចបើកមើលវាមានសញ្ញាដែលខ្ញុំបានគូសជូនលោកត្រូវហើយ។ នៅក្នុង ឆ.១៣ នេះ លោកបានប្រាប់ទៅក្រុមស៊ើបអង្កេតថា "លោកមិនប៊ាននិយាយទេ ខ្លាចគេសម្លាប់"។ ខ្ញុំចង់សួរទៅលោកវិញថា តើលោកដែលធ្លាប់ឃើញ ឬក៏ធ្លាប់ឮមនុស្សដែលនិយាយនោះត្រូវបានគេសម្លាប់ដែរឬទេ?

[០៩:២៨:៥៤]

**ឆ៖** ខ្ញុំមិនដែលឃើញទេ ប៉ុន្តែឯកសារបង្ហាត់ថា អ៊ីចឹង។ យើងមិនត្រូវនិយាយអីផ្តេសផ្តាស យើង -- ការងារយើងត្រូវគោរពការងារតែប៉ុណ្ណឹង។ ខ្ញុំមិនដែលបានឃើញទេ។ តែឯកសាររៀនអ៊ីចឹង តែនិយាយផ្តេសផ្តាសមិនមានការពិត គេសម្លាប់ហើយ។

**ស៖** ខ្ញុំចង់ដឹងលោកដែលដឹងរឿងនេះជាក់ស្តែង តើសិទ្ធិសម្រេចនៅក្នុងការសម្លាប់បុគ្គលម្នាក់ៗ ឬក៏សម្លាប់មនុស្សនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹងឋានៈរបស់គេប៉ុនណាដែលមានសិទ្ធិសម្លាប់មនុស្សបាន?

**ឆ៖** ខ្ញុំមិនបានដឹងពីឋានៈរបស់គេទេ។ តែក្រោមការគ្រប់គ្រង តាមូច តែមួយគាត់ចង់ចាត់ចែងម៉េចទៅតាមគាត់ ខ្ញុំមិនដឹងឋានៈគាត់ជាស្អី អត់ដឹង។

[០៩:៣០:០៦]

**ស៖** ខ្ញុំបន្តសំណួរទៅទៀត ខ្ញុំសួរម្តងនេះ គឺផ្តោតអារម្មណ៍ទៅលើស្បៀងអាហារ។ នៅក្នុងចម្លើយខាងលើ លោកបានប្រាប់ថា "តាមូច នោះគាត់គ្រប់គ្រងមនុស្សរាប់ពាន់នាក់ រួមទាំងកុមារផងដែរ គឺឲ្យធ្វើការចាប់ពីអាយុ១០ អ៎! ៧ឆ្នាំទៅ គឺថាឲ្យទៅធ្វើការហើយ"។ អ៊ីចឹងក្នុងចំនួនមនុស្សរាប់ពាន់នាក់ រួមទាំងកុមារតូចៗខាងលើ តើក្រុមមនុស្សទាំងអស់នេះ ជាក្រុមមនុស្សនៅក្នុងមូលដ្ឋានចាស់ ឬមួយក៏លោកសំដៅលើក្រុមមនុស្សដែលទើបតែជម្លៀសពីទីក្រុងភ្នំពេញទៅទីនោះ?

**ឆ៖** ក្រុមពួកទាំងអស់នោះសុទ្ធជាក្រុមថ្មីទាំងអស់ ទើបជម្លៀសពីទីក្រុងភ្នំពេញទៅ អត់មានមូលដ្ឋានចាស់ទេ។

**ស៖** អរគុណលោក សុខ ឈិន។ ទាក់ទងនឹងចំណុចដដែលនេះ ខ្ញុំសូមសួរថា មនុស្សរាប់ពាន់នាក់ដូច្នេះ។ តើរបបអាហារគេផ្តល់ជូនពួកគាត់យ៉ាងដូចម្តេចដែរ ហើយស្ថានភាពដែលលោកបានឃើញជាក់ស្តែង សូមលោកជួយបង្ហាញផង?

[០៩:៣១:៤៣]

**ឆ៖** អាហារនៅពេលនោះ វាអត់ត្រឹមត្រូវស្មើគ្នាទេ កន្លែងណាពលកម្មបានបបរៗ ដូចប៊ិៗទៅ កន្លែងណាពលកម្មទាប គឺបបររាវមួយកំប៉ុងបួនដប់ម្តែទាក់អ៊ីចឹងទៅ។ វាអត់ស្មើគ្នា។

**ស៖** ចុះលោកអាចដឹងពីអ្នកជំងឺទេទី១? ទី២ លោកអាចដឹងពីសុខភាពស្ត្រី និងកុមារតូចៗ? ទី៣ បញ្ហាសម្លៀកបំពាក់យ៉ាងដូចម្តេចដែរនៅក្នុងពេលនុំងបាទ?

**ឆ៖** កាលនៅពេលនុំង តែឈឺគេត្រូវបញ្ជូនទៅពេទ្យ មិនឲ្យឪពុកម្តាយទៅតាមជាមួយទេ ដែលកូននៅតូចៗ ហើយអ្នកធំទៅ -- អ្នកដែលមានអាយុខ្ពស់ជាងហ្នឹង គឺទៅនៅក្នុងពេទ្យតែម្នាក់ឯង គ្មានអ្នកការពារមើល និងរបបស្រេចនឹងខាងពេទ្យទេ។ ជួនកាលមានបបរទៅ ជួនកាលថ្ងៃណាអត់មានស្អីហូបទៅបាទ។ វាអត់គ្រប់គ្រាន់របបនៅពេលនោះ។

**ស៖** ចុះកុមារ និងសម្លៀកបំពាក់របស់គាត់ គេរៀបចំរបៀបម៉េចដែរ?

**ឆ៖** ដាច់រយីករយាក របស់ដែលយើងសល់ពី ពីមុនជម្លៀសទៅ មានក្រមា មានកន្សែងអីល្អេកល្អាច។ អត់មានរបបខោអាវទេ ជំនាន់នោះ។ ជំនាន់នោះអត់មានរបបខ្មៅរអាវ បាទ។

**ស៖** សូមលោកជួយបើកឯកសារដដែល គឺសំណួរនៅក្នុង ឆ.១១ ៗ ហើយខ្ញុំដាក់សញ្ញា ដើម្បីឲ្យលោកជួយ -- ស្រួលមើលហើយ។ បាទ ខ្ញុំមានសំណួរសួរលោក។ នៅក្នុងសំណួរ ឆ.១១ នេះ លោកដូចលោកបានប្រាប់អម្បាញ់មិញខាងលើអ៊ីចឹង របបអាហារមិនគ្រប់គ្រាន់ អ្នកជំងឺមិនមានការយកចិត្តទុកសម្លៀកបំពាក់ កុមារ និងស្ត្រី គឺរយីរយាក ខ្វះស្បៀងអាហារ។ អ៊ីចឹងខ្ញុំសួរ តើតាមួម នេះ។ សំណួររបស់ខ្ញុំនេះ តាមួម ហ្នឹងគាត់រាយការណ៍ផ្ទាល់។ លោកប្រាប់អ៊ីចឹង រាយការណ៍ផ្ទាល់។អ៊ីចឹងខ្ញុំចង់ដឹងថា តើរាយការណ៍ផ្ទាល់ហ្នឹង រាយការណ៍ទៅខាងណា?

[០៩:៣៥:១០]

**ឆ៖** គាត់រាយការណ៍ទៅខាងថ្នាក់លើ ខាងអង្គការលើ គឺនៅភ្នំពេញ។

**ស៖** អរគុណលោក ដែលបានបញ្ជាក់ចំណុចនេះច្បាស់។ ខ្ញុំសួរមួយទៀត ទន្ទឹមនឹងបញ្ហាស្បៀងអាហារខ្វះចំពោះប្រជាជនរាប់ពាន់នាក់នេះ តើលោកធ្លាប់ដឹង ឬក៏ធ្លាប់ទទួលព័ត៌មានថា តាមួម

គាត់មានមករៀនពីថ្នាក់ដឹកនាំផ្នែកខាងលើអំពីប្រជាជនហ្នឹងដែរទេ បាទ?

**ឆ៖** ខ្ញុំៗ អត់បានដឹងគាត់រៀនពីអ្វី។

**ស៖** ខ្ញុំចង់បញ្ជាក់ជូនលោកមួយសាទៀត នៅក្នុងចម្លើយលេខ១១ ដែលលោកបង្ហាញនេះ លោកបានប្រាប់អ្នកស៊ើបអង្កេតថា "តាមូម បានមករៀននៅភ្នំពេញ"។ លោកប្រាប់អ៊ីចឹង។ តើលោកធ្វើម្តេចដឹងថា តាមូម នេះគាត់មករៀននៅភ្នំពេញ?

[០៩:៣៦:៥៣]

**ឆ៖** ខ្ញុំៗដឹងតាមរយៈ ដែលខ្ញុំធ្វើការនៅតាមផ្លូវដែក ឃើញគាត់ជិះៗអាត្រីហ៊ុល រទេះភ្លើងមកភ្នំពេញ។

**ស៖** អរគុណលោក។ បន្ទាប់ពី តាមូម បានមកសិក្សា ឬក៏ទទួលការណែនាំពីថ្នាក់ដឹកនាំនៅភ្នំពេញនេះ នៅពេលដែល តាមូម គាត់ត្រឡប់ទៅវិញ តើគាត់មានណែនាំរបៀបសេដ្ឋកិច្ចយ៉ាងម៉េចខ្លះទៅដល់ក្រុមលោក រួមទាំងក្រុមប្រជាជនទាំងអស់នោះបាទ?

**ឆ៖** នៅពេលដែល តាមូម ត្រឡប់មកពីរៀននៅភ្នំពេញវិញ គឺគាត់តែងតែហៅបុគ្គលិក ហៅកម្មករដែលនៅក្រោមឱវាទរបស់គាត់ បើកការរៀនសូត្រជាប្រចាំ។

**ស៖** តើខ្លឹមសារនៃការរៀនសូត្រ ដែល តាមូម ទទួលបានពីទីក្រុងភ្នំពេញទៅនោះ គេបង្រៀនរបៀបធ្វើអ្វីខ្លះ? ដូចជាបង្កបង្កើនផល ឬក៏ផ្សេងៗដែលលោកបានទទួលជាក់ស្តែងនោះ។

**ឆ៖** ខ្ញុំដែលបានទទួលការរៀនសូត្រ គឺពង្រឹងជំហរ គោលជំហរសតិអារម្មណ៍ ពង្រឹងពីការងារបដិវត្តន៍ ឲ្យឈរនៅលើខាងបដិវត្តន៍ទាំងអស់ អត់មានងាករេទៅណាទេ។

[០៩:៣៩:០៥]

**ស៖** ចុះបញ្ហាសេដ្ឋកិច្ច ដូចជាស្បៀងនេះ តើ តាមូម គាត់មានយុទ្ធវិធី ឬក៏ណែនាំលោកយ៉ាងម៉េចដែរ?

**ឆ៖** គាត់ណែនាំ ប្រឹងឲ្យយើងទៅធ្វើពលកម្មខ្លួនឯងទៅ មានការងារស្នូល មានការងារសង្គមនិយម ដាំដុះ បាទធ្វើស្រែចម្ការដាំដុះ បានហូបខ្លួនឯង តែការពិតធ្វើស្រូវបាន អត់ទេ នៅតែបបរដដែល។

**ស៖** សូមអធ្យាស្រ័យ ខ្ញុំសូមថែមសួរសំណួរបន្តិចទៀត លោកថា "ធ្វើស្រូវបាននៅតែបបរដដែល"។ តើស្រូវនេះ ម៉េចបានបបរគេយកស្រូវហ្នឹងទៅណា? សូមលោកជួយបំភ្លឺចំណុចហ្នឹងបន្តិចមក។

**ឆៈ** ខ្ញុំអត់បានដឹងគេយកទៅណាទេ ព្រោះគេធ្វើឃ្លាំងធំៗ ហើយដល់នេះ ទៅមើលក្នុងឃ្លាំង បាត់ មិនដឹងគេលាក់ការណ៍ យកទៅណាបាត់អស់។ គេធ្វើឃ្លាំងដាក់អ៊ីចឹងទៅ ដល់ក្រោយឡើង បាត់អស់ មិនដឹងទៅខាងណា បាទ។

**សៈ** អរគុណលោក។ ឥឡូវសំណួរទាក់ទងបញ្ហាសេដ្ឋកិច្ចនេះ ខ្ញុំស្ទេះប៉ុណ្ណេះសិន។ ខ្ញុំបន្តសំណួរទៅទៀត ទាក់ទងពីប្រព័ន្ធទំនាក់ទំនងយោធាវិញម្តង។ នៅក្នុង ឆ.១៩ វាមានប្រទាក់ក្រឡាគ្នាទាក់ទងជាមួយនឹងការផ្ទេរភារកិច្ចរបស់លោកទៅផ្លូវលាជ ខេត្តពោធិ៍សាត់។ បាទ លោកបានឃើញហើយ ទៅផ្លូវលាជ ខេត្តពោធិ៍សាត់។ ខ្ញុំចង់ដឹងថា តើអ្នកណាផ្ទេរភារកិច្ចលោក ដែលទៅធ្វើការនៅផ្លូវលាជ ខេត្តពោធិ៍សាត់ហ្នឹង? ហើយប្រសិនបើលោកចងចាំ លោកចាំបញ្ជាក់ថាតើឆ្នាំណា ដែលលោកអាចផ្ទេរភារកិច្ចទៅពោធិ៍សាត់ហ្នឹងបាន?

[០៩:៤១:៥១]

**ឆៈ** តាមូម គាត់យករថភ្លើងទៅ -- យកពីខ្ញុំ ពីបាត់ដំបងមក មកនៅខេត្តពោធិ៍សាត់ ថាអង្គការឲ្យ បាទ អង្គការចាត់តាំងឲ្យខ្ញុំមកខាងពោធិ៍សាត់។

**សៈ** នៅត្រង់តំបន់ខេត្តពោធិ៍សាត់នេះ តើ តាមូម គាត់ជាអ្នកគ្រប់គ្រង ឬក៏យោធាជាអ្នកគ្រប់គ្រងនៅក្នុងតំបន់នោះ ដែលលោកបានជួបប្រទះជាក់ស្តែង?

**ឆៈ** តាមូម គាត់អ្នកគ្រប់គ្រង ហើយយោធាទាំងអស់នោះ នៅក្រោមបង្គាប់ តាមូម ដែរ។

**សៈ** អរគុណលោក។ នៅក្នុង -- នៅតាមផ្លូវលាជ នៅក្នុង ឆ.១៨ -- នៅ ឆ-១៨ ត្រង់កន្លែងនេះ លោកបានប្រាប់អ្នកស៊ើបអង្កេតថា “ទាហានប្រដាប់ដោយអាវុធយាមប្រជាជន។ ទាហានប្រាប់កន្លែង និងពេលវេលាដែលត្រូវចាកចេញ”។ យើងខ្ញុំចង់សួរលោកថា លោកដឹងតាមរយៈអ្វី ថាទាហានយាមប្រជាជន ឬមួយក៏ពិនិត្យមើលសិទ្ធិសេរីភាពរបស់ប្រជាជនគ្រប់ពេលនោះ? លោកដឹងតាមរយៈលោកឃើញផ្ទាល់ ឬក៏ឮគេនិយាយ?

[០៩:៤៤:០៨]

**ឆៈ** ខ្ញុំបានឃើញផ្ទាល់ ដោយសារកន្លែងនោះ ផ្លូវនោះ ខ្ញុំជាកម្មករទៅពង្រឹងផ្លូវដែក ត្រង់កន្លែងនោះ ជារៀងរាល់ថ្ងៃ។

**សៈ** លោកចងចាំទេថា តើពេលនោះ នៅចាំខែប៉ុន្មាន ឆ្នាំប៉ុន្មានដែរទេ ដែលលោកបានឃើញស្ថានភាពជាក់ស្តែងនោះ?

**ធ៖** ខ្ញុំមិនបានចាំខែឆ្នាំទេ ប៉ុន្តែក្រោយពីជម្លៀសពីទីក្រុងភ្នំពេញ ទៅតាមខេត្តនានា ហើយដឹក -- ហើយធ្វើប្រវត្តិរូបនៅខេត្តនានាហើយ ប្រជាជនទាំងអស់នោះ ត្រូវដឹកមកតាមរថភ្លើងមកដាក់នៅលាជហ្នឹងហើយ។

**សៈ** ឥឡូវនេះ ខ្ញុំចង់សួរសំណួរដែលចំណុចដែលជាក់លាក់ មិនមែនរឿង តាមូម គ្រប់គ្រងនៅមនុស្សរាប់ពាន់នាក់ហ្នឹងទេ។ ខ្ញុំសួរទាក់ទងជាមួយតែមនុស្សដែលនៅលើក្បាលរទេះភ្លើង។ តើលោកបានពិនិត្យឃើញមានកុមារតូចៗ ស្ត្រី មនុស្សចាស់ជរា អ្នកជំងឺ នៅក្នុងក្បាលរទេះភ្លើងដែលគេដឹកមកពីភ្នំពេញហ្នឹង មានសភាពយ៉ាងដូចម្ដេចដែរ?

[០៩:៤៦:00]

**ធ៖** ...នៅកុមារ មនុស្សចាស់ជរា ប្រុសស្រី ដឹកតាមៗរទេះភ្លើងមកវារយឹករយាកវាអត់អីហូបមកដាក់ចោលនៅកន្លែងផ្លូវលាជហ្នឹង ដើម្បីដឹកជញ្ជូនចែកតាមតំបន់សហករណ៍ផ្សេងៗ។ ខ្ញុំឃើញជាក់ស្ដែង។ ខ្លះក៏មានឈឺទៅអីទៅ តាមបាទ ទម្រាំគេមកដឹកជូន២-៣ថ្ងៃ ជួន១អាទិត្យអីចឹង វាមិនទៀង។

**សៈ** ខ្ញុំចង់ដឹងផងដែរថា នៅក្នុងទូររថភ្លើងដែលដាក់ប្រជាជននេះ មួយទូៗមានទាហានយាមប៉ុន្មាននាក់ដែរ ដែលលោកបានឃើញ?

**ធ៖** នៅក្នុងទូហ្នឹងមានទាហានយាមមួយទូប្រហែលជាពីរនាក់ចុងដើមទូ។

**សៈ** ខ្ញុំក៏ចង់សួរផងដែរថា តើលោកអាចកត់សម្គាល់ថា មានប្រជាជនចាមដែលត្រូវបានគេដឹកទៅទីនោះដែរទេបាទ?

**ធ៖** ខ្ញុំមិនបានឃើញចាមទេ តែប្រជាជនហ្នឹងចម្រុះ បាទ ចម្រុះគ្នា។ ចាមក៏មាន ខ្មែរយើងក៏មាន ចិនក៏មានចម្រុះគ្នា ដែលចេញពីភ្នំពេញទៅបាទ។ យកទៅចែកតាមសហករណ៍នៅក្នុងខេត្តពោធិ៍សាត់។

**សៈ** បាទ ខ្ញុំតសំណួរទៅមួយទៀត ទាក់នឹង -- ទាក់ទងនឹងប្រព័ន្ធយោធានេះ។ ឥឡូវនេះយើងរំលងសំណួរដែលទាក់ទងជាមួយនឹងមនុស្សដែលនៅក្នុងទូរថភ្លើង ដែលត្រូវបានយាមកាមយ៉ាងតឹងរ៉ឹងពីកងទ័ព។ បន្ទាប់ពីដាក់ពីរថភ្លើងមក -- ដាក់ចុះពីរថភ្លើងមក តើមានអង្គភាពណាមួយដែលដឹកប្រជាជនចេញ ក្រៅពីយោធា ឬមួយក៏សុទ្ធតែយោធាទាំងអស់ដឹកប្រជាជនចេញ?

**ធ៖** ខ្ញុំមិនបានដឹងទេ។ អង្កាល់នុំងមានប្រជា -- មានយោធាដឹកក៏មាន ស៊ីវិលក៏មាន។ បាទ

លាយឡំគ្នា។ ជួនកាលឡានស៊ីវិលទៅ ជួនកាលឃើញឡានយោធាទៅ។ បាទដឹកចម្រុះគ្នា។

[០៩:៤៩:៣៧]

**សៈ** មុនពេលដឹកប្រជាជនចេញពីលាជ ពីផ្លូវលាជហ្នឹង នៅក្នុង ឆ.២៣ -- នៅក្នុងសំណួរ ឆ.២៣ នេះ លោកបានប្រាប់ថា "ប្រជាជនទាំងអស់ត្រូវបានគេពិនិត្យប្រវត្តិរូប"។ ខ្ញុំចង់ដឹងថា កន្លែងលាជនេះ ជាកន្លែងពិនិត្យប្រវត្តិរូបមុននឹងចូលទៅបាត់ដំបង ឬក៏មុននឹងចុះនឹងកន្លែងលាជហ្នឹង ជាកន្លែងដែលធំ ដើម្បីពិនិត្យប្រវត្តិរូបសិន ដើម្បីឲ្យបន្តរថភ្លើងទៅទៀត ឬមួយក៏ត្រូវបំបែកប្រជាជនជាកង់ៗនៅទីនេះ? លោកស្តាប់សំណួរខ្ញុំបានទេ បើមិនបាន ខ្ញុំអាចសុំ ខ្ញុំអាចបញ្ជាក់លោកឡើងវិញ។

**ឆៈ** ប្រជាជនដែលជម្លៀសពីទីក្រុងភ្នំពេញ ទៅតាមទិសរបស់ពួក ប៉ុល ពត ទៅដល់ភូមិឃុំគេធ្វើប្រវត្តិរូបរួចបានគេដឹងយកមកភ្នំពេញ ហើយឡើងពីភ្នំពេញយកមកទុកមកដាក់ចោលនៅលាជនៅតាមដងផ្លូវទាំងអស់ លាជទៅមក បឹងខ្នារ ពោធិ៍សាត់ បាត់ដំបង អ៊ីចឹងមកបាទ។

[០៩:៥១:៣២]

**សៈ** អ៊ីចឹងតាមលោកយល់អម្បាញ់មិញនេះ បើតាមក្រុមការងារអយ្យការយល់ថា លោកថាប្រជាជនត្រូវបានគេសួរប្រវត្តិរូបហើយបានបង្វិលចេញតាមសាខាផ្សេងៗទៀត។ តើអ៊ីចឹងមែនទេ?

**ឆៈ** បាទ ត្រឹមត្រូវអ៊ីចឹងមែន។

**សៈ** អរគុណលោក។ តើលោកបានធ្លាប់ឮអំពីជោគវាសនានៃជីវិតទាហាន លន់ នល់ ដែលត្រូវបានគេស្រាវជ្រាវឃើញប្រវត្តិរូបជាមួយនឹងរដ្ឋការនៃរបប លន់ នល់ លោកអាចដឹងពីជោគវាសនារបស់ក្រុមគាត់ដែរទេ?

**ឆៈ** កាលដែលខ្ញុំអង្គការចាត់តាំងឲ្យខ្ញុំទៅនៅស្វាយស៊ីសុផុន ខ្ញុំឃើញផ្ទាល់សកម្មភាពយោធាមកពីរៀននៅប្រទេសថៃ ដឹកតាមឡានមក ហើយក៏បង្ហួសដឹកតាមរទេះភ្លើង ហើយពួកគេទាំងអស់នោះគ្នាដូចជាវាមិនដឹងរឿងអី សុទ្ធតែពាក់ស័ក្តិនៅលើស្មា មានស័ក្តិម្រាំង សាកាដូធំៗ ទីនុយស្បែកជើងម៉ៃហ្វកអ៊ីចឹងទៅ។ ដឹកតាមរទេះភ្លើង តែខ្ញុំមិនដឹងថាដឹងទៅៗត្រង់ណាទេ។ ដឹកពីស្វាយស៊ីសុផុនមកខាងបាត់បង ឬមិនដឹងក៏ដឹកទៅណាទៀតទេ អត់ដឹង។ បាទខ្ញុំឃើញផ្ទាល់នឹងភ្នែកខ្ញុំនៅហ្នឹង កាលហ្នឹងខ្ញុំនៅស្វាយ ស្វាយស៊ីសុផុន។

[០៩:៥៣:១៩]

**សៈ** ខ្ញុំមានសំណួរមួយទៀតទេ ហើយបន្ទាប់មក ខ្ញុំនឹងឲ្យក្រុមការងារសហព្រះរាជអាជ្ញាអន្តរ

ជាតិបន្តសួរសំណួរលោក។ ខ្ញុំសួរចុងក្រោយ។ នៅពេលដែលទាហានទាំងអស់ត្រូវបានគេដឹកមក មានសក្តិ មានយសអីតាមរទេះភ្លើងពីស្វាយមកបាត់ដំបងមិនដឹង មកពោធិ៍សាត់មិនដឹង។ តើលោកស្គាល់ទួលពោធិ៍ជ្រៃទេ? លោកដែលឮទេ សម័យនុំងបាទ?

**ឆ៖** ខ្ញុំអត់ដែលស្គាល់ អត់ដែលឮ។

**លោក វេង ហ៊ត៖**

ខ្ញុំសូមសម្តែងនូវការអរគុណ លោក សុខ ឈិន ដែលបានខំប្រឹងប្រែងឆ្លើយនូវសំណួររបស់ក្រុមការងារព្រះរាជអាជ្ញា។ សូមអរគុណផងដែរលោកប្រធាន និងសូមអរគុណក្រុមប្រឹក្សាជំនុំជម្រះទាំងអស់។ បាទ សូមអរគុណ។

[០៩:៥៥:៤៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមគោរពលោក លោកស្រីចៅក្រម មេធាវី ភាគីទាំងអស់ និងលោក ឈិន លោក សុខ ឈិន! ខ្ញុំនឹងសូមសួរលោកសំណួរមួយចំនួន ដើម្បីបន្តពីសំណួររបស់សហសេវិករបស់ខ្ញុំដែលបានសួរលោកអម្បាញ់មិញនេះ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ដោយសារតែលោកបានផ្លាស់ប្តូរកន្លែងការងាររបស់លោកក្នុងរយៈកាលខ្មែរក្រហម ក្នុងរបបខ្មែរក្រហម ខ្ញុំសូមសួរបញ្ជាក់ត្រង់ការផ្លាស់ប្តូរកន្លែងការងារនេះ ហើយកន្លែងណាខ្លះដែលលោកបានបំពេញការងារក្នុងដំណាក់កាលនីមួយៗ។ នៅក្នុងចម្លើយ-សំណួរទី២ លោកបានឆ្លើយថា "មុនឆ្នាំ១៩៧៥ លោកជាអ្នកលក់សំបុត្ររថភ្លើង ហើយស្ថានីយដែលលោកធ្វើការគឺនៅមោងឫស្សី ខេត្តបាត់ដំបង។ យើងបានស្តាប់ឮលោកបាននិយាយបញ្ជាក់មុននេះផងដែរ។ ក្រោយមកលោកធ្វើការនៅស្វាយស៊ីសុផុនផងដែរ។ ខ្ញុំសូមសួរលោកថា នៅពេលដែលលោកផ្លាស់ប្តូរពីមោងឫស្សី ខេត្តបាត់ដំបូងទៅស៊ីសុផុននោះ គឺសេរី ឬក៏យើងហៅថា សិរីសោភ័ណនោះ តើលោកប្តូរនៅឆ្នាំណាដែរពីមោងឫស្សី ទៅសិរីសោភ័ណនោះ?

[០៩:៥៦:១៩]

**ឆ៖** ១៩៦៧ ខ្ញុំចេញធ្វើការ ខ្ញុំនៅមោង ហើយខ្ញុំ -- ឆ្នាំ១៩៧០ បានខ្ញុំផ្លាស់ពីមោងឫស្សីទៅនៅស្វាយស៊ីសុផុន ហៅ សិរីសោភ័ណហ្នឹង។

**ស៖** សូមអរគុណច្រើនដែលលោកបានបញ្ជាក់បំភ្លឺត្រង់ចំណុចនេះ។ តើសិរីសោភ័ណបច្ចុប្បន្ននេះ នៅក្នុងខេត្តបន្ទាយមានជ័យហ្នឹងអ៊ីចឹងដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** តើលោកនៅបន្តធ្វើការងារនៅស៊ីសុផុន ឬសេរីសោភ័ណ្ឌនេះរហូតទៅដល់ចុងឆ្នាំ៧៥ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ត្រឹមត្រូវបាទ។

[០៩:៥៧:៣៤]

**ស៖** យោងតាមចម្លើយដែលលោកបានឆ្លើយ គឺសំណួរ-ចម្លើយទី៨ នៅពេលដែល ចម្លើយ -- សំណួរ-ចម្លើយទី៤ គឺនៅពេលដែលខ្មែរក្រហមកាន់កាប់អំណាចគឺពួកគេលុបបំបាត់ការលក់សំបុត្រចោល ហើយគេឲ្យលោកជួសជុលផ្លូវដែក។ ហើយលោកថា តាមូម ផ្លាស់ប្តូរលោកពីសិរីសោភ័ណទៅប្រាសាទ -- ពោធិ៍សាត់ តើលោកអាចបញ្ជាក់ជូនយើងខ្ញុំដែរឬទេ ការផ្លាស់ប្តូរទៅពោធិ៍សាត់នោះ គឺនៅក្នុងឆ្នាំ -- មុនឆ្នាំ១៩៧៥ ឬក៏ក្រោយមក?

**ឆ៖** ក្រោយឆ្នាំ១៩៧៥ ប្រហែលក្នុងរង្វង់ ៤, ៥ខែក្រោយ។

**ស៖** ប្រសិនបើខ្ញុំយល់តាមចម្លើយដែលលោកបានឆ្លើយនៅសំណួរ-ចម្លើយលេខ៧ លោកបានបញ្ជាក់ថា លោកធ្វើការនៅឃុំត្រពាំងជង នៅក្នុងខេត្តពោធិ៍សាត់ តើអ៊ីចឹងដែរឬទេ?

[០៩:៥៩:១៥]

**ឆ៖** បាទ ត្រឹមត្រូវ ខ្ញុំធ្វើការនៅគេហៅថា សង្កាត់ត្រពាំងជង ទទួលខុសត្រូវ ២៦គីឡូម៉ែត្រ។ ២១ គីឡូម៉ែត្រ បាទសូមទោស! ២១បាទ ។

**ស៖** សូមអរគុណ។ តាមូមៗ លោកបានបញ្ជាក់ថា ជាអ្នកទទួលខុសត្រូវគឺផ្នែករបស់លោក តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា តាមូម នេះគឺក៏គេបានផ្លាស់ប្តូរជាមួយនឹងលោកឲ្យទៅស៊ីសុផុនជាមួយនឹងលោក តើអ៊ីចឹងដែរឬទេ?

**ឆ៖** កាលជំនាន់នោះ តាមូម គាត់មិនទាន់ចូលមកឯណា ទាល់តែបែក ប៉ុល ពត ហើយបានមានតាមូម។ អង្កាល់ណោះ ខ្ញុំនៅធ្វើការនៅសម័យសង្គមរាស្ត្រនិយមហ្នឹង គេផ្លាស់ខ្ញុំបាទ។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេ លោកទៅដល់ត្រពាំងជង នោះប្រហែលជា៤ខែ ក្រោយខ្មែរក្រហមកាន់កាប់អំណាច។ ប្រសិនបើលោកចាំ តើតាមូម ហ្នឹងមកកាន់កាប់នៅត្រពាំងជង ហ្នឹងនៅ

ក្នុងឆ្នាំណាដែរ?

**ឆ៖** តាមូម គាត់ជាប្រធានតំបន់ ហើយខ្ញុំធ្វើការគេហៅនៅសង្កាត់។ ក្នុងមួយតំបន់ហ្នឹង ខ្ញុំមិនចាំ បែបមានប្រាំ ប្រាំមួយសង្កាត់។ ខ្ញុំប្រហែលមិនចាំ មិនដឹងប៉ុន្មាន ធ្វើការក្នុងមួយតំបន់ហ្នឹង ព្រោះ តាមូម ជាប្រធានតំបន់ ហើយខ្ញុំនៅខាងសង្កាត់។ សង្កាត់ហ្នឹងទទួលខុសត្រូវផ្លូវដែក២១គីឡូ បាទ។

[១០:០១:៣៧]

**ស៖** ដោយសារតែពេលវេលា គឺខ្ញុំសូមបន្តទៅសួរលោកបន្តទៀត។ ខ្ញុំគ្រាន់តែចង់សួរបញ្ជាក់ លោក តាមាយ -- តាមាក់ គឺជាអ្នកគ្រប់គ្រងក្រុមរបស់លោក ហើយតាមអ្វីដែលលោកឆ្លើយនោះ គឺថា គាត់ហ្នឹងជាអ្នកគ្រប់គ្រងនៅក្នុងឃុំរបស់លោក។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ មិនត្រឹមត្រូវទេ ព្រោះ តាមាក់ គាត់ជាប្រធានសង្កាត់ ទទួលខុសត្រូវ មេទទួលខុសត្រូវ២១គីឡូហ្នឹងឯង។ មិនមែននៅក្នុងភូមិទេបាទ ជាប្រធានសង្កាត់ ទទួលខុសត្រូវផ្នែកនយោបាយ ការងារទាំងអស់។ បាទ រៀនសូត្រនៅលើ តាមាក់ ហ្នឹងហើយ។ ទាំងជីវភាពរស់នៅ ទាំងអី ទាំងអស់ នៅក្នុងសង្កាត់របស់ខ្ញុំ ២១គីឡូនៅត្រពាំងជង ហ្នឹង តាមាក់ គាត់ទទួលខុសត្រូវទាំងអស់។

[១០:០២:៤២]

**ស៖** សូមអរគុណ។ តាមពិតយើងពិភាក្សាចំណុច ដូចដែលយើងទេ ប្រហែលជាមានការបកប្រែមិនសូវច្បាស់។ ឥឡូវនេះ យើងទៅខាងមុខបន្តិចទៀត ទាក់ទងទៅនឹងហេតុការណ៍មួយចំនួន ដែលលោកបានពិភាក្សាជាមួយសហព្រះរាជអាជ្ញាជាតិ។ ខ្ញុំចង់ពិនិត្យមើលសំណួរ-ចម្លើយលេខ១៦ នៅក្នុងចម្លើយរបស់លោក។ បាទ សំណួរ-ចម្លើយ១៥ បាទ ហើយខ្ញុំនឹងអានសេចក្តីដកស្រង់សង្ខេបដើម្បីឱ្យបានព័ត៌មានច្បាស់លាស់។ លោកបាននិយាយថា "ខ្ញុំបានឃើញរថភ្លើង២ដងក្នុង១អាទិត្យ រថភ្លើងហ្នឹងមានទូពី២០ ទៅ២៥ ដែលជាតួសម្រាប់គេយកអ្នកដឹកទំនិញ ហើយតួនីមួយៗ ដឹកមនុស្ស៤០ ទៅ៥០ នាក់។ ការដឹកជញ្ជូនមានពីរដំណាក់កាល លើកទី១ ក្រោយពីខែមេសា ឆ្នាំ១៩៧៥ ក្នុងខែតុលា វិច្ឆិកា និងខែធ្នូ ប្រជាជនត្រូវបានដឹកចេញពីទីក្រុងភ្នំពេញ"។ ខ្ញុំចង់ពិភាក្សាចំណុចនេះ អំពីការដឹកចេញពីភ្នំពេញដើម្បីឱ្យលោកបញ្ជាក់លម្អិតបន្ថែមទៀត។ តាមដែលខ្ញុំ តើត្រូវដែរឬទេថា គឺនៅក្នុងខែតុលា វិច្ឆិកា និងធ្នូ ដែលលោកបានឃើញរទេះភ្លើងទាំងអស់នោះ ដែលថារទេះភ្លើងនីមួយៗមានទូពី២០ទៅ ២៥ ហើយដឹកមនុស្សចេញពីភ្នំពេញមកនោះ?

[១០:០៤:៣៧]

**ឆ៖** បាទ ត្រឹមត្រូវអ៊ីចឹងហើយបាទ។

**ស៖** នេះជារយៈពេលវែងមកហើយ ក៏ប៉ុន្តែតើលោកចាំដែរឬទេ ថាតើការដឹកហ្នឹងគឺដឹកជាបន្តបន្ទាប់៣ខែទេ ពីខែតុលា វិច្ឆិកា ធ្នូ ឬក៏ដឹកក្នុងតែរយៈពេលខ្លី ឬក៏ពេញ១១ខែ?

**ឆ៖** រយៈដឹក បើ១ -- ខ្ញុំមិនបានចាំពិតប្រាកដទេ ប៉ុន្តែដឹករហូតដល់ចប់ ចប់ខែធ្នូ បានអស់ប្រជាជន បាទក្នុងមួយវគ្គហ្នឹង។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ តាមចម្លើយរបស់លោក លោកនិយាយថា លោកបានឃើញរទេះភ្លើងទាំងអស់នេះនៅពេលដែលលោកធ្វើការនៅត្រពាំងជង ខេត្តពោធិ៍សាត់នោះ?

**ឆ៖** បាទ ត្រឹមត្រូវ។ ខ្ញុំនៅធ្វើការតាមផ្លូវ ដល់ពេលរទេះភ្លើងវាមកដល់ខ្ញុំត្រូវសម្រាក បាទខ្ញុំដឹងបាទ ក្រឡេកមើលទៅឃើញសុទ្ធតែប្រជាជនបាទ។

[១០:០៦:១០]

**ស៖** នៅពេលដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញាជាតិ លោកនិយាយថា “បានឃើញបុរសស្ត្រី ហើយនិងកុមារផងដែរ”។ តើលោកឃើញមនុស្សទាំងអស់ហ្នឹងនៅរទេះភ្លើង ដែលលោកបាននិយាយអម្បាញ់មិញហ្នឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ ខ្ញុំឃើញរទេះភ្លើងដែលដឹកមកហ្នឹងមានចម្រុះ។

**ស៖** នៅក្នុងចម្លើយរបស់លោក នៅក្នុងសំណួរចម្លើយលេខ១៨ លោកបានរៀបរាប់ពីមនុស្សដែលយាមអ្នកដែល បាទដឹកនោះគឺថា “ទាហាន ប៉ុល ពត ប្រដាប់ដោយអាវុធ យាមពួកគេនៅលើរថភ្លើង”។ ខ្ញុំសូមរៀបសំណួរឡើងវិញ។ តើលោកដឹងថាទាហានអ្នកយាមប្រជាជននោះមកពីណាហ្នឹងគឺដឹងដោយរបៀបណា?

**ឆ៖** ខ្ញុំមិនដឹងមកពីទីណាទេ ប៉ុន្តែឃើញគាត់នៅលើរទេះភ្លើង ស្ពាយកាំភ្លើង។ បាទ ខ្ញុំដឹងថាមើលទៅឃើញដឹងថាយោធា បាទ មិនមកដឹងពីណាទេ *អេសស្កក* ប្រជាជនមក ខ្ញុំអត់បានដឹងទេ។ មិនដឹងមក -- យោធាហ្នឹងមិនដឹងមកពីណា អីខាងណា។

[១០:០៧:៤៩]

**ស៖** លោកក៏បាននិយាយផងដែរថា នៅក្នុងសំណួរនិងចម្លើយលេខ១៩ គឺថា “រទេះភ្លើងនៅខេត្តពោធិ៍សាត់ ជួនកាលរទេះភ្លើងនោះក៏បានឈប់នៅត្រង់ផ្លូវទៅលាជ”។ ហើយខ្ញុំក៏ចង់សួរលោកផងដែរ ថាតើលោកបានឃើញរទេះភ្លើងដែល១ឈប់នៅក្នុងខេត្តពោធិ៍សាត់ដែរឬទេ?

**ឆ៖** រទេះភ្លើងដែលដឹកប្រជាជន គេមិនយកមកដាក់តាមខេត្តទេ គេដាក់ស្ថានីយតាមព្រៃ បាទ ស្ថានីយនៅក្នុងព្រៃៗ។ ខេត្ត គេជម្លៀសពីខេត្តចេញទាំងអស់ ហើយគេដឹកប្រជាជនពីភ្នំពេញមក យកមកដាក់ស្ថានីយដែលៗ ស្ថានីយណាដែលឆ្ងាយ ព្រៃ តាមព្រៃឆ្ងាយៗ អត់មានដឹកចូលក្នុងខេត្តទេ។

**ស៖** តើលោកអាចឃើញរទេះភ្លើងហ្នឹងច្បាស់ដែរឬទេ ដែលថាមកឈប់នៅកន្លែងមួយៗ ដែលថាលោកថា ស្ថានីយតាមព្រៃហ្នឹង ឃើញច្បាស់ដែរឬទេ?

**ឆ៖** បើដាក់តាមព្រៃ តាមស្ថានីយដែលតាមព្រៃ ខ្ញុំសួរដំណឹងតាមដែលខ្ញុំមិនបានឃើញច្បាស់ទេ ដឹងដំណឹងតាមអ្នកបើកបរ ដែលនេះគេនិយាយថា "អ្ហ៎! រទេះភ្លើងដាក់នៅខាងណោះៗ" គេប្រាប់មកអ៊ីចឹង។ បាទ ខ្ញុំមិនបានឃើញទេ ព្រោះខ្ញុំឃើញតែលាជជាក់ស្តែងនៅនឹងភ្នែក នឹងមុខខ្ញុំ ខ្ញុំដឹងបាទ។

[១០:០៩:៥៤]

**ស៖** ឥឡូវនេះយើងនិយាយអំពីនៅលាជ អ្វីដែលលោកនិយាយនៅក្នុងចម្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេតនោះ គឺនៅសំណួរចម្លើយលេខ១៩ "នៅក្នុងលាជ គឺប្រជាជនគេទុកឱ្យនៅ ១សប្តាហ៍ ហើយបន្ទាប់មក គឺគេដឹកទៅដើម្បីរង់ចាំឱ្យទៅដឹកកន្លែងផ្សេងទៀត តាម ទៅក្រុងពោធិ៍សាត់ ដឹកតាមឡានទាហាន និងឡានស៊ីវិល"។ ថាតើលោកបានឃើញច្បាស់ដែរឬទេ ដែលថាឃើញថាមានឡានទាហាន និងឡានស៊ីវិលមកដឹកប្រជាជន? តើឃើញហ្នឹង ឃើញនៅក្នុងលាជហ្នឹង ឬក៏កន្លែងណា?

**ឆ៖** ខ្ញុំឃើញច្បាស់នឹងភ្នែក គឺនៅក្នុងលាជហ្នឹងឯង ដាក់តាមដងផ្លូវទៅលាជផង ដាក់តាមដួរផ្លូវរទេះភ្លើង គឺប្រជាជននៅពេញហ្នឹងទាំងអស់ បាទ។

[១០:១១:០៤]

**ស៖** តើលាជនៅចម្ងាយប៉ុន្មានពីត្រពាំងជង ពីកន្លែងដែលថា ជាផ្នែកមួយដែលលោកធ្វើការដែរនោះ?

**ឆ៖** ខ្ញុំធ្វើការនៅពេលនោះ ជួនចល័ត។ ផ្លូវរទេះភ្លើងដែលខូចខាត កម្មករធ្វើមិនទាន់ ខ្ញុំទៅជំនួយ បាទ នៅពេលហ្នឹង ខ្ញុំទៅជំនួយការ គេហៅទៅ ធ្វើការសម្រុកនៅកន្លែងហ្នឹង ដើម្បីឱ្យផ្លូវហ្នឹងបានល្អ។ បាទ ខ្ញុំមិនដឹងប៉ុន្មានទេ ជួនកាលខ្ញុំមិនដឹងប៉ុន្មានគីឡូៗ ខ្ញុំមិនបានចាំ។

**ស៖** ដើម្បីឱ្យខ្ញុំយល់ឱ្យច្បាស់ពីចម្លើយរបស់លោកនោះ តើត្រូវដែរឬទេ លោកបានឃើញរទេះភ្លើងឆ្លងកាត់តាមពោធិ៍សាត់ គឺថានៅក្នុងកន្លែងមួយចំនួន ហើយលោកបានឃើញថា រទេះភ្លើងមួយ

ចំនួនឈប់នៅលាជ បាទ តើអ្វីដែលលោកឃើញហ្នឹង គឺឃើញបែបហ្នឹងឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ ឃើញបែបហ្នឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះ និយាយពីមនុស្សដែលលោកបានឃើញ ដែលថាដឹកទៅដល់ ហើយចេញពីរទេះភ្លើងនោះ ហើយលោកបានប្រាប់ទៅសហព្រះរាជអាជ្ញាជាតិថា គេទុកនៅទីនោះប្រហែលជា១អាទិត្យ។ បាទនៅក្នុងចម្លើយរបស់លោកដែរ នៅក្នុងសំណួរចម្លើយ១៩ សូមដកស្រង់ “មិនមានអ្នកណាម្នាក់ចាកចេញបានទេ ដោយសារតែពួកគេត្រូវបានយាមកាម ហើយអ្នកដែលមានជំងឺក៏នឹងស្លាប់នៅទីនោះដែរ”។ ខ្ញុំសូមសួរលោកតទៅទៀត ថាតើលោកបានឃើញអ្នកណាម្នាក់ដែលបានស្លាប់ ក្នុងពេលដែលរង់ចាំនៅកន្លែងនោះ មុននឹងគេមកយកដែរឬទេ?

**ឆ៖** ខ្ញុំបានយកទៅកប់ផ្ទាល់ដៃ ព្រោះដែលទុកនៅតាមផ្លូវរទេះភ្លើងហ្នឹង វាធុំក្លិនស្អុយ។ ស្អុយទៅ ខ្ញុំយកកប់ផ្ទាល់ដៃ ខ្មោចម្នាក់ ប៉ុន្តែមិនស្គាល់អត្តសញ្ញាណទេបាទ។

[១០:១៣:៥៨]

**ស៖** ខ្ញុំសូមសួរថយក្រោយបន្តិច ចំពោះប្រជាជនដែលនៅរង់ចាំនៅក្នុងលាជ នៅក្នុងស្ថានីយលាជនោះ តើលោកអាចធ្វើការប៉ាន់ប្រមាណបានទេថា ប្រហែលមានចំនួនប៉ុន្មាន ដែលគេដឹកមួយជើងៗមកហ្នឹង គឺថាអាចថាជា ១០០, ២០០ ឬក៏អាចដល់ទៅ ៧០០ ជាដើមហ្នឹង?

**ឆ៖** ក្នុងទូមួយ វាមានចំណុះពី ៤០ ទៅ៥០។ បើដឹកនាំ២០ទូមក វាត្រូវ២០០នាក់។ បើដឹក ២៥ទៅ វាកើនតាមហ្នឹងទៅទៀតបាទ។

**ស៖** ចំពោះការគណនារបស់ខ្ញុំ មិនសូវច្បាស់ទេ។ បើសិនជាអាចនឹងថាមាន២០ *ប៉ារុង*រទេះភ្លើង ថាតើអាចមានដល់ ១០០០ ដែរអ៊ីចឹង ដែរឬទេ? តើលោកអាចប៉ាន់ប្រមាណដោយវិធីណា?

**ឆ៖** ចំពោះប្រជាជនដឹកមក វាប៉ាន់ស្មានមិនដឹងទេ ប៉ុន្តែខ្ញុំខាងរទេះភ្លើងខ្ញុំ វាមានចំណុះប្រជាជនដែលដាក់នៅហ្នឹង២០ -- ៤០ ទៅ ៥០ នាក់បាទ។ វាចំណុះទូៗរថភ្លើងមួយៗបាទ។ តែឃើញក្រឡេកមើលឃើញទៅពេញ។ បាទ ឃើញជាក់ស្តែងនឹងភ្នែក ឃើញពេញទូបាទ។ ទាំងក្មេងទាំងចាស់ទាំងស្រី ទាំងប្រុសបាទ។ ពេញទូ ខ្ញុំប៉ាន់ស្មានថាប្រហែលជា៤០ ទៅ ៥០នាក់។

**ស៖** លោកបានប្រាប់យើងខ្ញុំថា ពួកគេយាមប្រជាជននៅតាមទូរទេះភ្លើងនោះ ហើយលោកក៏បានជម្រាបតុលាការផងដែរថា ពួកគេមិនអាចចាកចេញទៅណាបានទេ នៅពេលដែលគេរង់ចាំនៅស្ថានីយលាជនោះ។ នៅក្នុងចម្លើយរបស់លោក នៅក្នុងសំណួរនិងចម្លើយលេខ ១៧ សួរថា “តើពួកគេ

មើលទៅសប្បាយរីករាយដែរឬទេ?" លោកបានឆ្លើយថា "ទេ ពួកគេមិនសប្បាយទេ"។ តើលោកអាចជម្រាបខ្ញុំឱ្យបានលម្អិតជាងហ្នឹងបន្តិចទេ ដែលលោកនិយាយថា "ពួកគេមិនសប្បាយទេហ្នឹង" តើលោកមានអ្វីបន្ថែមលើហ្នឹងដែរឬទេ?

[១០:១៦:៣៨]

**ឆ៖** អង្គាល់ដែលប្រជាជនជម្លៀសនៅពេលនោះ ក្នុងមួយគ្រួសារ ខ្ញុំបានដឹងថាគេចែកអង្ករក្នុង១០នាក់ មួយកំប៉ុង ម៉្លោះហើយគ្នាអត់អីហូប មានហូបអត់គ្រប់គ្រាន់ទេ។ បាទ ព្រោះអ្នកដែលជម្លៀសពីភ្នំពេញទៅ មានតែសម្ភាយខោអាវ និងប្រាក់រៀលខ្មែរ យកទៅជាមួយ ឯអង្ករ ស្លឹកគ្រៃហ្នឹងអត់បានយកទៅជាមួយទេនៅពេលនោះ ម៉្លោះហើយ សតិអារម្មណ៍គ្នាហ្នឹងវា តាំងពីជីវភាពរស់នៅវាអត់កើត មើលទាំងទឹកមុខ -- ទឹកមុខផងគេហ្នឹងវា យើងសម្គាល់ថា គេមិនសប្បាយចិត្ត។ បាទ ក្រៀមក្រំទុក្ខសោកបាទ។

**ស៖** តើលោកអាចនិយាយទៅពួកគាត់ណាម្នាក់បានដែរទេ ពេលដែលគាត់រង់ចាំនៅទីនោះ?

**ឆ៖** បាទ ខ្ញុំមិនដែលនិយាយទៅរកគេទេ ព្រោះការងារវាផ្សេងគ្នា យើងអត់ត្រូវដឹងពីរឿងការងារទេ។ គ្រាន់តែឃើញជាក់ស្តែងនឹងភ្នែក អត់ដែលបាននិយាយទៅរកពីណាទេ។

**ស៖** ថាតើមានសមាជិកក្នុងក្រុមរបស់លោកហ្នឹង តើគេអនុញ្ញាតឱ្យទៅសួរនាំ ទៅប្រជាជនដែលឆ្លងកាត់តាមលាជទេ ទាំងអតីតទាហានជាដើមហ្នឹង មានអ្នកណាអាចទៅសួរនាំអីអ្នកនោះបានទេ?

**ឆ៖** មុខងារវាខុសគ្នា។ ខ្ញុំពង្រឹងផ្លូវដែក ជួសជុលផ្លូវដែក អត់មានសិទ្ធិទៅបានទៅសួរនាំអីទេបាទ។ គិតតែពីរឿងការងារ ដែលទិសថ្នាក់លើដាក់ឲ្យ។ ខំតែពង្រឹងការងារផ្លូវដែក គ្មានពេលចេញដើរឆ្ងាយពីផ្លូវដែកបានទេ។ បាទ គ្មានពេលទៅសួរទៅនាំអី ទៅពិភាក្សាដោះស្រាយ សួរនាំសុខទុក្ខអីអត់មានទេបាទ។

[១០:១៨:៥៥]

**ស៖** ខ្ញុំចង់សួរបន្ថែមទៀត នៅពេលដែលលោកនិយាយថា លោកមិនប៉ានសួរទៅអ្នកណាម្នាក់ហេតុអីបានជាលោកមិនប៉ានសួរបែបនោះ គឺថា តើមានហេតុផលអីដែលលោកថាមិនប៉ានសួរទៅពួកអ្នកយាម ពួកទាហានអ្នកយាមនោះក៏មិនប៉ានសួរ -- មិនសួរ -- មិនប៉ានសួរថាគេដើរហើរទៅណាហ្នឹងក៏មិនប៉ាន។ ហេតុអីក៏បានមិនប៉ាន?

**ឆ៖** ព្រោះទិសថ្នាក់លើ ព្រោះអារឿងយើង យើងមិនត្រូវដឹង។ ដឹងតែទិសគេដាក់ឲ្យបាទ។ ទិសសួរណែនាំមានអ្នកផ្សេងទៀត។ ទិសខ្ញុំមានតែពង្រឹងផ្លូវដែក។ គេដាក់ទិសមកអ៊ីចឹង ថ្នាក់លើបាទ។ យើងអត់មានទៅអាចសួរនាំគេបាន។ ព្រោះទិសថ្នាក់លើ រៀនសូត្រឯកសារគេនិយាយអ៊ីចឹងបាទ។

[១០:១៩:៥០]

**ស៖** តើមានការណែនាំអ្វីដែលលោកបានទទួលមកពីតាមូម ឬក៏តាមាក់ហ្នឹង គាត់បានណែនាំអ្វីខ្លះ អំពីរឿងនេះ?

**ឆ៖** គឺរៀនសូត្ររាល់ថ្ងៃ តាមូម គាត់ដាក់ទិសមកឲ្យរៀនសូត្ររាល់ថ្ងៃ។ ពង្រឹងជំហរ គោលជំហរសតិអារម្មណ៍ ការងារចាត់តាំង បាទ។ រឿងជីវភាពរស់នៅអត់មានតវ៉ា។ ថ្នាក់លើបក្សឲ្យហូបអីហូបហ្នឹងបាទ។ អត់មានទៅទាមទារតវ៉ាអីបាន។

**ស៖** តើគេប្រាប់លោកថាអាចនឹងមានបញ្ហាអ្វីទេ បើយើងមិនគោរពទៅតាមអ្វីដែលគេអប់រំនោះ?

**ឆ៖** លើកទី១ គេកសាង។ លើកទី២ គេកសាង។ លើកទី៣ យកទៅរៀនសូត្រ។ រៀនសូត្រហ្នឹង គឺមិត្តភក្តិខ្ញុំមួយចំនួន គេទៅរៀនសូត្រ គឺទៅបាត់ខ្លួនបណ្តោយ។

[១០:២១:៣២]

**ស៖** តើលោកធ្លាប់ដឹងដែរឬទេ ថាតើអ្នកដែលគេយកទៅ ដែលថាជាមិត្តភក្តិរបស់លោកយកទៅរៀនសូត្របាត់ខ្លួននោះ ហើយក្រោយមកមានអ្វីកើតឡើងចំពោះអ្នកទាំងនោះ?

**ឆ៖** ខ្ញុំមិនដឹង គឺយកទៅរៀនសូត្រ ប៉ុន្តែអត់ចូលមកតាមអង្គភាពវិញ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងត្រឡប់ទៅអំពីលក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជនដែលលោកបាននិយាយប្រាប់សហព្រះរាជអាជ្ញាជាតិបន្តិចហើយ អំពីប្រជាជនជម្លៀសនោះ។ ហើយលោកនិយាយថា "លោកបានយកសាកសពដែលរលួយទៅកប់នោះផងដែរ" តើលោកនៅចាំទេ ថាតើមានសាកសពប៉ុន្មានដែលលោកប្រទះឃើញនៅលាជនោះ?

[១០:២២:៤២]

**ឆ៖** សាកសពដែលយកទៅកប់នោះ វាមាននៅជាប់នឹងផ្លូវដែក។ តែខ្ញុំធ្វើការទៅ វាប៉ះពាល់ ឬការស្អុយ ការអី ធ្វើការអត់បាន។ ប៉ុន្តែនៅតាមក្រៅពីផ្លូវដែក ខ្ញុំអត់ប៉ះពាល់ទេ ឃើញតែគេគ្របចោលបាទ។ ឃើញមានច្រើន តែខ្ញុំមិនដឹង មិនបានគិតគូរពីរឿងរាប់ប៉ុន្មានអីប៉ុន្មានទេ តែខ្ញុំឃើញគ្របចោល

នៅតាមភ្លឺស្រែ នៅតាមចញ្ចើមផ្លូវជាតិ តែបើប៉ះពាល់ផ្លូវដែក ខ្ញុំបានយកទៅកប់ ម្នាក់ មួយ។ សពហ្នឹង មួយទេ។

[១០:២៣:២៨]

**ស៖** តើលោកអាចផ្ដល់ជាចំនួនប៉ាន់ប្រមាណថាប្រហែលមានសាកសពប៉ុន្មាន ដែលលោកបានឃើញនៅក្បែរផ្លូវរទេះភ្លើង ឬក៏នៅតាមវាលស្រែ ឬក៏នៅកន្លែងណាមួយដែលបានឃើញនៅទីនោះ អាចពីប្រាំ ១០ ឬក៏២០ បាទ។ តើលោកអាចផ្ដល់ជាការប៉ាន់ប្រមាណបានដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនអាចប៉ាន់ប្រមាណបានទេ ពីព្រោះជួនកាលឃើញគ្រប់នៅហ្នឹងទៅ ស្អែកឡើងបាត់ បាត់ ដល់តែក្រោយមកទៀត ឃើញនៅកន្លែងផ្សេងទៀត ក្រោយឡើងបាត់ ខ្ញុំអត់បានប៉ាន់ស្មានចំនួនគេទេ។

**ស៖** ប្រហែលជាយើងអាចឲ្យជាក់លាក់ជាងនេះ តើលោកខ្លួនលោកផ្ទាល់ហ្នឹង លោកបានកប់សាកសពប៉ុន្មាន?

**ឆ៖** មានតែសាកសពមួយទេ ដែលនៅលើផ្លូវដែក ក្រៅពីផ្លូវដែក ខ្ញុំមិនបានទៅកប់ទេ នៅលើខាងគេបាទ។

[១០:២៤:៥៥]

**ស៖** ខ្ញុំអាចនឹងសួរសំណួរជាក់លាក់ទៅលោកសាក្សី ប៉ុន្តែខ្ញុំចង់ឲ្យច្បាស់ដើម្បីកំណត់ត្រាតុលាការ តើលោកដឹងដូចម្ដេចថា សាកសពដែលលោកបានឃើញនោះ គឺជាសាកសពរបស់ប្រជាជនជម្លៀសដែលថាជាប្រជាជនដែលដឹកជម្លៀសតាមរទេះភ្លើងទៅទីនោះ នោះ?

**ឆ៖** ពីព្រោះនៅកន្លែងហ្នឹងស្ងាត់ អត់មានប្រជាជនដែលរស់នៅជិតទេ។ មានតែប្រជាជនជម្លៀសនៅទីនោះ។ ប្រហែលជា តាមខ្ញុំប៉ាន់ស្មានប្រហែលដែលអ្នកដែលសពដែលស្លាប់នេះ កប់មិនទាន់ ហើយគ្រួសាររបស់គាត់គេជញ្ជូនទៅដាក់តាមសហករណ៍។ អាហ្នឹងតាមខ្ញុំប៉ាន់ស្មានបាទ។ បានជាសពហ្នឹងនៅលើផ្លូវដែក។ ព្រោះផ្លូវដែក -- នៅម្តុំហ្នឹងអត់មានប្រជាជនដែលរស់នៅជិតខាងទេ បាទ នៅគឺកណ្ដាលព្រៃ។

[១០:២៦:០៧]

**ស៖** សូមអរគុណ។ ខ្ញុំសួរសំណួរលោកមួយចំនួនទៀត ទាក់ទងទៅនឹងទីតាំងឈ្មោះថា វ៉ាលាជនេះ។ នៅក្នុងសំណួរ និងចម្លើយដែលសហចៅក្រមស៊ើបអង្កេតសួរលោកនៅសំណួរ-ចម្លើយ២២

លោកបាននិយាយថា “លោកនៅចាំថា ប្រជាជនខ្លះត្រូវបានគេបង្ខំឲ្យចាកចេញពីរថភ្លើង ចំណែកឯអ្នកដទៃទៀតបន្តដំណើរទៅកាន់ខេត្តបាត់ដំបង”។ ខ្ញុំសួរលោកសំណួរដំបូង តើប្រជាជនដែលគេយក ដែលថា ឲ្យចុះចេញពីរទេះភ្លើងមុនហ្នឹងគឺគេយកអ្នកហ្នឹងទៅទីណាបាទ?

**ឆ៖** ការងារចាត់តាំងទាំងអស់នោះ ខ្ញុំមិនបានដឹងទេ។ ព្រោះប្រជាជនជួនកាលគេត្រូវនឹងចុះលាដ ជួនកាលគេសល់មួយទូពីរទូគេបង្ហួសទៅបាត់ដំបង អាហ្នឹងខ្ញុំអត់បានដឹងខាងការងារចាត់តាំងទេ។ ខ្ញុំគ្រាន់តែឃើញដាក់ស្តែងនឹងភ្នែក ការងារចាត់តាំងអត់ដឹង។ បាទមិនដឹងខាងណាចាត់តាំងទៅខាងណាទេបាទ។

[១០:២៧:៥០]

**ស៖** នៅពេលដែលលោកនិយាយថា អ្នកខ្លះត្រូវបានគេបង្ខំឲ្យចេញពីរទេះភ្លើង តើខ្ញុំយល់ត្រូវដែរឬទេ គឺថាពួកយោធាជាអ្នកបង្ខំឲ្យពួកគេចេញពីរថភ្លើង ឬក៏មានអ្នកណាផ្សេងពីពួកយោធានេះ?

**ឆ៖** ប្រជាជនដែលដឹកតាមទូទេះភ្លើងចុះតាមផ្លូវលាដក្តី តាមកន្លែងផ្សេងៗក្តី មានតែយោធាមួយទេ ដែលជាអ្នកគ្រប់គ្រង អ្នកបញ្ជាឲ្យចុះ ឲ្យឡើងអី រឿងគាត់។ មានតែយោធាទេ អត់ដែលឃើញមានជនស៊ីវិលទេ។ យោធាហ្នឹងប្រដាប់ដោយអាវុធទៀត។

**ស៖** នៅក្នុងកថាខណ្ឌដដែលនេះ លោកក៏និយាយដែរផងថា “រទេះភ្លើងត្រឡប់មកភ្នំពេញដើម្បីមកយកប្រជាជនដទៃទៀត ហើយនិងត្រឡប់មកវិញ”។ ខ្ញុំចង់ឲ្យយល់ច្បាស់អំពីចម្លើយរបស់លោក រទេះភ្លើងដែលទៅដល់នោះហើយគឺបានមកភ្នំពេញ ហើយមកយកមនុស្សពីភ្នំពេញទៀត ហើយត្រឡប់មកឆ្លងកាត់តាមពោធិ៍សាត់ម្តងទៀត ហើយនិងទៅកន្លែងផ្សេងទៀត។ តើដំណើរការហ្នឹងដូច្នេះឬយ៉ាងណា?

[១០:២៩:២៦]

**ឆ៖** បាទ ត្រឹមត្រូវដូចខ្ញុំដែលបានជម្រាប។ ត្រឹមត្រូវ។

**ស៖** លោកបានឆ្លើយទៅសហព្រះរាជអាជ្ញាជាតិថា ទាហានរបស់តាមូម -- សូមកែ គឺថាតាមូម បានត្រួតត្រាលើតំបន់នោះ។ តើយោធារបស់គាត់បានចូលរួមនៅក្នុងការជួយនៅក្នុងបញ្ជូនប្រជាជនឆ្លងខេត្តពោធិ៍សាត់ហ្នឹងដែរឬទេ?

**ឆ៖** អត់មានទេ។ ទាហានហ្នឹង គេដាក់តាមទូពីភ្នំពេញមក។ ការពារពីភ្នំពេញមករហូត។ ហើយយោធាហ្នឹង គេត្រូវត្រឡប់ទៅវិញ។ ទៅតាមទូទៅវិញ ទៅយកប្រជាជនពីភ្នំពេញមកទៀត។

ទៅមកៗតាមទូ។

**ស៖** តើតាមូម ឬក៏តាមាក់ មានផ្តល់ការណែនាំទៅដល់លោក ឬក៏ផ្តល់ព័ត៌មានអ្វីខ្លះទៅដល់លោកដែរឬទេ? ដែលព័ត៌មាននេះ គឺអំពីរថភ្លើងដែលនឹងបើកឆ្លងកាត់ ហើយរថភ្លើងនោះ គឺមានដឹកមនុស្ស។ តើគាត់មានផ្តល់ការណែនាំ ឬព័ត៌មានអ្វីដល់លោកឬទេ?

[១០:៣១:៣៤]

**ឆ៖** អត់មានផ្តល់ទេ គឺខ្ញុំឃើញជាក់ស្តែង ដែលខ្ញុំឃើញនៅតាមផ្លូវ ព្រោះតាមូម និងតាមាក់ ប្រហែលជាមិនដឹងដែរ រទេះភ្លើងដែលចេញពីណាទៅណា គឺគាត់មិនដឹងដែរ។ តែខ្ញុំឃើញជាក់ស្តែងនៅដែលខ្ញុំធ្វើការនៅតាមផ្លូវដែក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ អរគុណតំណាងសហព្រះរាជអាជ្ញា។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី អ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ ខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥៩ នាទី)*

[១០:៥៩:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី សុខ ឈិន ខ្ញុំនឹងសួរសំណួរមួយចំនួនទៀត មុននឹងខ្ញុំប្រគល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំត្រឡប់ទៅរកចំណុចមួយដោយសង្ខេប អំពីចំនួនរទេះភ្លើងដែលលោកបានឃើញ លោកបានប្រាប់ពីខាងដើមថា លោកបានឃើញការដឹកចំនួនមនុស្ស។ មនុស្សនោះ គឺថានៅក្នុងខែតុលា វិច្ឆិកា រហូតដល់ខែធ្នូ ឆ្នាំ១៩៧៥។ ហើយលោកបានរៀបរាប់អំពីទូរទេះភ្លើង ហើយនិងចំនួនមនុស្សនៅក្នុងនោះផង។ នៅក្នុងសំណួរនិងចម្លើយដែលលោកបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតហ្នឹង គឺសំណួរចម្លើយ១៥ "លោកបានឃើញរទេះភ្លើងហ្នឹងពីរដង ក្នុង១សប្តាហ៍"។ ខ្ញុំសួរថាតើលោកបានឃើញរទេះភ្លើងហ្នឹង ចំនួនប៉ុន្មាន ដែលថាពីរដង ក្នុង១អាទិត្យនោះ?

[១១:០១:៣៧]

**លោក សុខ ឈិន៖**

**ឆ៖** ខ្ញុំមិនបានរៀបចំនួនទេ ប៉ុន្តែជួនកាលពីរដង ក្នុង១អាទិត្យទៅ ជួនកាល១អាទិត្យហ្នឹងឃើញមកម្តងទៅ រហូតដល់ខែធ្នូ បានចប់។ វាមិនទៀងទាត់។

**ស៖** សូមអរគុណ។ តើលោកនៅចាំដែរឬទេ ថាតើរទេះភ្លើងហ្នឹងដដែល តែមួយទៅមក ឬក៏មានរទេះភ្លើងច្រើនខុសពីមួយហ្នឹង?

**ឆ៖** បាទ ទូនៅដដែល តែក្បាល គេត្រូវដូរ។ ដូរក្បាល ក្បាល ដូរក្បាលរថភ្លើង ដូរក្បាលម៉ាស៊ីន បាទ។

**ស៖** ថាតើលោកដឹងដែរឬទេ តើរថភ្លើងហ្នឹង រទេះភ្លើងហ្នឹង ជារបស់ខាងណា? របស់អ្នកណា?

**ឆ៖** រទេះភ្លើង គឺរបស់កាលពីនៅៗសង្គមរាស្ត្រនិយមម៉្លេះ គឺអាពត វាអត់ទាន់មានកុម្ម៉ង់ក្បាលនិងរទេះភ្លើងមកទេ។ គឺរទេះភ្លើងចាស់ពីជំនាន់សង្គមរាស្ត្រនិយម ជំនាន់សម្តេចឪ បាទ។

[១១:០៣:១៣]

**ស៖** សូមអរគុណ។ និយាយអំពីបញ្ហានេះ លោកបានឆ្លើយទៅសហចៅព្រះរាជអាជ្ញាជាតិនៅព្រឹកមិញនេះថា តាមូម បានមកភ្នំពេញ ដើម្បីមកចូលរៀនវគ្គសិក្សា។ ហើយនៅក្នុងចម្លើយរបស់លោក

នៅសំណួរចម្លើយលេខ១១ ទៅសហចៅក្រមស៊ើបអង្កេត លោកនិយាយដូចខាងក្រោមនេះ "តាមូម ជាបក្ខជន បក្សកុម្មុយនីស្តកម្ពុជា ហើយគាត់រាយការណ៍ផ្ទាល់ទៅអង្គភាពនៅក្នុងទីក្រុងភ្នំពេញ"។ តើលោកដឹងដែរឬទេ ថារទេះភ្លើងទាំងអស់ហ្នឹង ដែលឆ្លងកាត់ខេត្តពោធិ៍សាត់ហ្នឹង គឺស្ថិតនៅក្រោមគ្រប់គ្រងអង្គភាពរទេះភ្លើងដែលនៅក្នុងទីក្រុងភ្នំពេញហ្នឹង ដែរឬទេ?

**ឆ៖** បាទត្រឹមត្រូវ។ រទេះភ្លើងដែលនៅឆ្លងតាមគ្រប់តំបន់ទាំងបួនហ្នឹង នៅក្រោមការគ្រប់គ្រងនៅភ្នំពេញ បាទ ប្រធានគេនៅភ្នំពេញបាទ។

**ស៖** តើលោកស្គាល់ -- តើប្រធានអង្គភាពហ្នឹង គាត់ជាអ្នកណា? គាត់ឈ្មោះអ្វី? ហើយមានតំណែងជាអ្វី តើលោកដឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹង អត់បានស្គាល់ អត់បានដឹងពីតំណែង អត់បានស្គាល់ឈ្មោះទៀត។

[១១:០៥:១៥]

**ស៖** ខ្ញុំសូមមើលផ្នែកមួយទៀត នៅក្នុងសំណួរនិងចម្លើយដែលលោកបានឆ្លើយនៅលេខ២៣ បាទ សូមអភ័យទោស គឺលេខ២៦។ គេបានសួរថា "តើអ្នកណាជាប្រធានស្ថានីយរថភ្លើងនៅពោធិ៍-សាត់?" ហើយលោកបានឆ្លើយថា "គឺមានមនុស្សបីនាក់ ដែលទទួលខុសត្រូវខាងទូរស័ព្ទ។ ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះពួកគេទេ។ ពួកគេទាំងអស់ជាទាហានខ្មែរក្រហម ហើយពួកគេមានប្រដាប់ដោយអាវុធ"។ ខ្ញុំសូមសួរលោកបន្តទៅទៀត តើទូរស័ព្ទដែលគេប្រើនៅស្ថានីយរទេះភ្លើងខេត្តពោធិ៍សាត់ហ្នឹង គេប្រើក្នុងគោលបំណងអ្វី?

**ឆ៖** ទូរស័ព្ទដែលគេប្រើជំនាន់នោះ គឺសម្រាប់ចរាចរណ៍ខ្សែរថ។ ព្រោះរទេះភ្លើងយើងមានផ្លូវតែមួយ វាត្រូវការចៀសជែងគ្នាកន្លែងស្ថានីយណាមានផ្លូវបំបែក ស្ថានីយណា។ ហ្នឹងទូរស័ព្ទគេទាក់ទងគ្នាផ្នែកខាងចរាចរណ៍ខ្សែរថ។

[១១:០៦:៣៣]

**ស៖** សូមអរគុណ។ តើលោកស្គាល់ដែរឬទេ ហើយប្រាប់ខ្ញុំបើលោកមិនដឹងទេនោះ តើស្ថានីយរទេះភ្លើងទាំងអស់នោះ ស្ថិតនៅក្រោមការគ្រប់គ្រងនៃអង្គភាពរថភ្លើងនៅភ្នំពេញដែរឬទេ?

**ឆ៖** ស្ថានីយទាំងអស់នៅក្រោមការគ្រប់គ្រងនៅស្ថានីយភ្នំពេញតែមួយ ក្តាប់ទិសតែមួយនៅភ្នំពេញ។

**ស៖** សូមអរគុណ។ តើតាមូម ជាអ្នកគ្រប់គ្រងស្ថានីយរថភ្លើងនៅពោធិ៍សាត់ ឬក៏មានអ្នកណា

ផ្សេងខុសពីគាត់ ដែលថាទទួលបន្ទុកលើស្ថានីយរថភ្លើងនេះនោះ?

**ឆ៖** តាមូម គាត់ទទួលខុសត្រូវតំបន់២។ តំបន់២ហ្នឹង ពីរមាសមកដល់ពោធិ៍សាត់។ គឺគាត់ទទួលខុសត្រូវទាំងចរាចរណ៍ខ្សែរថ ទាំងអីទាំងអស់បាទ ក្រោមការគ្រប់គ្រងរបស់គាត់។

**ស៖** សូមអរគុណ។ តើលោកដឹងដែរឬទេ ថាតើ តាមូម គាត់ទៅធ្វើរាយ -- ទៅរាយការណ៍ឲ្យអង្គភាពរទេះភ្លើងនៅភ្នំពេញហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំមិនបានដឹងទេ រឿងការងាររបស់គាត់បាទ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ នៅពេលដែលលោកឆ្លើយទៅនឹងសំណួរសហព្រះរាជអាជ្ញាជាតិ គឺថាក្រោយពីគាត់បានធ្វើដំណើរមកភ្នំពេញ តាមូម តែងតែមករៀបចំកិច្ចប្រជុំនៅក្នុងមូលដ្ឋានរបស់លោក ដើម្បីណែនាំឲ្យបុគ្គលិក ឬក៏អ្នកធ្វើការនៅស្ថានីយរថភ្លើង ដើម្បីទទួលការអប់រំ។ តើអ៊ីចឹងដែរឬទេ?

[១១:០៨:៥៩]

**ឆ៖** បាទ ត្រឹមត្រូវប្រាកដណាស់ ត្រឹមត្រូវបាទ។

**ស៖** សូមអរគុណ។ ហើយខ្ញុំមានសំណួរមួយចំនួនទៀត ទាក់ទងទៅនឹងទីកន្លែងដែលគេបញ្ជូនមនុស្សតាមរទេះភ្លើងទៅនោះគឺថា -- ហើយនិងពីទីកន្លែងដែលគេបញ្ជូនមក នៅក្នុងសំណួរចម្លើយលេខ ១៤ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គេបានប្រាប់លោកថា គេបញ្ជូនមកពីភ្នំពេញ។ ហើយនៅក្នុងសំណួរនិងចម្លើយទី២៣ លោកនិយាយថា "អ្វីដែលខ្ញុំដឹងថាមនុស្សនេះ ទាំងនេះគឺថាមកពីទិសដៅ មកពីទិសភ្នំពេញ"។ សំណួរ តើលោកដឹងទីកន្លែងជាក់លាក់ទេ ថាតើពួកគេហ្នឹងរស់នៅកន្លែងណា មុនពេលដែលគេដាក់រទេះភ្លើងបន្តទៅភូមិភាគពាយ័ព្យទៀតហ្នឹង?

**ឆ៖** ខ្ញុំអត់បានដឹងគេដឹកមកពីណាទេ បាទខ្ញុំអត់បានដឹងទេ។ ខ្ញុំឃើញដឹងតែតាមផ្លូវរទេះភ្លើង ហើយរទេះភ្លើងទៅភ្នំពេញទៅមកៗ ខ្ញុំអត់បានដឹងថាពីខាងណាចូលមកភ្នំពេញ ខ្ញុំដឹងតែពីឃើញនៅតាមផ្លូវ។ បាទ ឃើញនៅតាមផ្លូវ គឺពីដាក់ប្រជាជនដាក់អស់ រទេះភ្លើងទៅភ្នំពេញវិញ។ ហើយរទេះភ្លើងដឹកពីភ្នំពេញមក ដាក់ប្រជាជនអស់ ត្រឡប់ទៅវិញ។

**ស៖** សូមអរគុណ។ តើលោកដឹងដែរឬទេ ថាតើមនុស្សទាំងអស់នេះត្រូវបានគេដាក់ឲ្យឡើងរទេះភ្លើងនៅភ្នំពេញ ឬក៏គេដាក់នៅកន្លែងណាខុសពីភ្នំពេញ មុននឹងដឹកបញ្ជូនចេញទៅនោះ?

[១១:១១:១១]

**ឆ៖** ខ្ញុំៗអត់បានដឹងទេ ប៉ុន្តែរទេះភ្លើងទិសមកភ្នំពេញ តែមិនដឹងថាប្រជាជនហ្នឹង គេដាក់នៅពោធិ៍ចិនតុងមិនដឹង គេដាក់នៅផ្លូវបំបែកទៅកំពង់សោមមិនដឹង គឺខ្ញុំអត់បានដឹងទេ។ តែខ្ញុំឃើញរទេះភ្លើងហ្នឹងមកពីភ្នំពេញ បាទមកពីទិសភ្នំពេញ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងពិនិត្យមើលទីកន្លែងដែលគេយកប្រជាជនទាំងអស់ហ្នឹងទៅឱ្យនៅ ឬក៏ទៅដាក់នោះ គឺយើងមានផ្នែកមួយចំនួននៅក្នុងចម្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេត ដែលមានការពាក់ព័ន្ធ។ នៅសំណួរនិងចម្លើយលេខ១៩ ដែលយើងនិយាយពីខាងដើម លោកបាននិយាយថា "ប្រជាជនរង់ចាំនៅលាជ ដើម្បីគេដឹកបន្តទៅ"។ ហើយនៅក្នុងសំណួរ-ចម្លើយ២១ លោកបាននិយាយថា "ខ្ញុំដឹងថា គេដឹកប្រជាជនទាំងអស់នោះទៅសហករណ៍ផ្សេងៗតាមឡាន ដោយទាហាន ឬក៏ឈ្លបរបស់ ប៉ុល ពត"។ តើលោកអាចប្រាប់ខ្ញុំបានទេ? ថាតើលោកដឹងដោយវិធីណា ថាគេដឹកអ្នកទាំងអស់ហ្នឹងទៅសហករណ៍ផ្សេងៗនោះ?

**ឆ៖** បាទ ខ្ញុំបានឃើញផ្ទាល់នឹងភ្នែក ដឹកចេញពីលាជ ទៅទិសខាងទិសខាងណា លាជទៅខាងត្បូង។

**ស៖** នៅក្នុងសំណួរនិងចម្លើយលេខ១៤ លោកបានរៀបរាប់ពីទីកន្លែងមួយចំនួន ដែលគេដឹកប្រជាជនទៅកាន់ទីនោះ ហើយលោកនិយាយថា "ដូចជាទៅស្វាយស៊ីសុផុន បាត់ដំបង ថ្មគោល ហើយនិងភ្នំតូច"។ បើខ្ញុំមិនច្រឡំទេ គឺទីតាំងទាំងអស់នេះ គឺមាននៅបន្ទាយមានជ័យ នៅបាត់ដំបងផងដែរ។ តើអ្នកណាជាអ្នកប្រាប់លោកថា គេដឹកជញ្ជូនប្រជាជនទាំងអស់នេះទៅកន្លែងនីមួយៗដែលខ្ញុំបានអានអម្បាញ់មិញនេះនោះ?

[១១:១៣:៤៩]

**ឆ៖** ខ្ញុំដឹងតាមនៅខ្សែមួយៗមានប្រធានខ្សែរថ។ ប្រធានខ្សែរថហ្នឹង ដែលមកចុះនៅដឹកទទេមកពោធិ៍សាត់ថា "ប្រជាជនហ្នឹងយកទៅដាក់នៅស្វាយ បាទ យកទៅដាក់នៅជណ្តើរស្វា ថ្មគោល ឬភ្នំតូច" ដឹងតាមប្រធានខ្សែរថ។ ប្រធានខ្សែរថហ្នឹងមិនមែនជាយោធាទេ ជាស៊ីវិលៗ។ ជាកម្មករចាស់ដែលខ្ញុំធ្លាប់ស្គាល់បាទ។

**ស៖** នៅពេលដែលលោកនិយាយថា ប្រធានខ្សែរថ តើជាប្រធាននៃស្ថានីយណាមួយ ឬក៏ប្រធានខ្សែរថហ្នឹង គេកាន់របៀបម៉េច? សូមលោកពន្យល់ខ្ញុំឱ្យច្បាស់ជាងនេះបន្តិច។

**ឆ៖** រទេះភ្លើងកាលជំនាន់នោះ ខាងផ្នែកដឹកជញ្ជូនវាមានពីរផ្នែក។ ផ្នែកស្ថានីយ និងផ្នែកខ្សែរថ។

ផ្នែកស្ថានីយមានប្រធានស្ថានីយ។ ផ្នែកខ្សែរថ មានប្រធានខ្សែរថ។ ប្រធានខ្សែរថហ្នឹង គេទទួលខុសត្រូវខ្សែរថទាំងមូល។ ឯប្រធានស្ថានីយចាំតែទទួលខ្សែរថនៅនឹងកន្លែង ឯប្រធានខ្សែរថគេធ្វើចរាចរណ៍ពីភ្នំពេញមកតាមខ្សែរថហ្នឹងមកបាទ។

**ស៖** ចាតើប្រធានខ្សែរថហ្នឹង ដែលមកជាមួយរថភ្លើងដែលបានប្រាប់លោកថា ទិសដៅទាំងអស់នេះដែលគេត្រូវយកប្រជាជនទៅដាក់ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ ព្រោះប្រធានខ្សែរថ គេមានទិនានុប្បវត្តិខ្សែរថ។ បាទ ទិនានុប្បវត្តិខ្សែរថគឺមានពីចេញដំណើរទៅដល់ទីដៅ។ បាទ មានគេហៅថា ទិនានុប្បវត្តិខ្សែរថ បាទ។

[១១:១៦:២៥]

**ស៖** យើងពិនិត្យមើលអំពីអ្វីដែលបានកើតឡើង -- ខ្ញុំសូមរៀបសំណួរឡើងវិញបាទ។ តើលោកធ្លាប់ដឹងដែរឬទេហេតុអ្វីបានថា គេត្រូវដឹកប្រជាជនពីកន្លែងមួយទៅកន្លែងមួយបែបនេះនោះ?

**ឆ៖** អាហ្នឹងខ្ញុំអត់បានដឹងទេ។ បាទ ខ្ញុំទទួល គឺខ្ញុំដឹងតែពេលខ្ញុំនៅធ្វើការ ខ្ញុំឃើញ។ តែអារឿងប្រជាជនដែលដឹកពីកន្លែងណាទៅកន្លែងណាគឺខ្ញុំអត់បានដឹង។ ខ្ញុំជាកម្មករសម្រាប់ជួសជុលផ្លូវដែកខាងនេះ ខ្ញុំអត់បានដឹងការងាររបស់គេ។

**ស៖** លោកបានឆ្លើយទៅសហព្រះរាជអាជ្ញាជាតិថា ប្រវត្តិរូបរបស់ប្រជាជនទាំងអស់នោះ គេត្រូវបានកត់ត្រាមុន មុនពេលដែលគេដាក់ទៅលើរទេះភ្លើងធ្វើដំណើរ។ នៅក្នុងចម្លើយរបស់លោកដែរនៅក្នុងសំណួរ-ចម្លើយលេខ២៣ លោកបាននិយាយអំពីហេតុការណ៍បានកើតឡើង នៅពេលដែលប្រជាជនទៅដល់ទិសដៅណាមួយនោះ។ "ប្រជាជនត្រូវបានជម្លៀសទៅខេត្តដទៃទៀត ហើយនៅពេលដែលគេទៅដល់ខេត្ត ពួកគេត្រូវបានធ្វើប្រវត្តិរូប។ តាមប្រវត្តិរូបផ្ទាល់ខ្លួនរបស់ពួកគេ ពួកគេត្រូវបានបញ្ជូនទៅតាមទីតាំងផ្សេងៗ"។ តើលោកអាចពន្យល់ខ្ញុំបន្ថែមបានទេ នៅពេលដែលលោកនិយាយថា គេបញ្ជូនមនុស្ស ឬក៏បញ្ជូនប្រជាជនទាំងអស់នោះ ទៅកន្លែងផ្សេងៗតាមប្រវត្តិរូបរបស់គេនោះ? តើលោកចង់មានអត្ថន័យដូចម្ដេច?

[១១:១៨:៣០]

**ឆ៖** ខ្ញុំសូមជម្រាបថា ប្រជាជនដែលជម្លៀសទៅទីក្រុងភ្នំពេញទៅ វាចម្រុះ។ ខ្លះជាកម្មករសុទ្ធសាធ ធាក់ស៊ីក្លូ ធាក់រ៉ឺម៉ក ខ្លះជាមន្ត្រីរាជការ បាទ ជំនាន់នោះ ម៉្លោះហើយគេស្រង់ប្រវត្តិរូបហ្នឹងនៅតាមភូមិឃុំដែលគាត់ជម្លៀសទៅ។ បាទ នេះខ្ញុំដឹងច្បាស់ មានសាច់ញាតិខ្ញុំបងប្អូនដែលរស់នៅភ្នំពេញ ហើយ

ត្រឡប់ទៅស្រុកកំណើត គេធ្វើប្រវត្តិរូប។ ធ្វើប្រវត្តិរូបរួច បានគេបញ្ជូនជូនមកខាងទិសពាយ័ព្យតាមផ្លូវ រទេះភ្លើងមកទិសពាយ័ព្យបាទ។ ប្រវត្តិរូបមន្ត្រីរាជការអី ទាហាន ស៊ីវិល អីៗទាំងអស់បាទ។ គេធ្វើ ប្រវត្តិរូបហើយហ្នឹងបានគេជ្រើសរើស។ អត់មានប្រជាជនថ្មីទេ ចាស់ទេ ជាប្រជាជនថ្មីដែលជម្លៀស ពីទីក្រុងភ្នំពេញទាំងអស់។

[១១:១៩:៣២]

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ដើម្បីឲ្យប្រាកដថា ខ្ញុំយល់ច្បាស់ពីអ្វីដែលលោកឆ្លើយ អ្វីដែលលោកបានឮ។ នៅពេលដែលគេជម្លៀសប្រជាជនពីភ្នំពេញ ហើយគេបានធ្វើប្រវត្តិរូប ហើយ បន្ទាប់ពីធ្វើប្រវត្តិរូបហើយ គេបានបញ្ជូនទៅទិសដៅផ្សេងទៀត។ តើហ្នឹងជាសេចក្តីសង្ខេបត្រឹមត្រូវពីអ្វី ដែលលោកឆ្លើយដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវពិតប្រាកដណាស់។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកសាក្សី សុខ ឈិន ដែលលោកបានឆ្លើយទៅសហសេវិករបស់ខ្ញុំផងដែរ។ ហើយ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ខ្ញុំសូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាង ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឱកាសក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១១:២០:៣៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមទាំងអស់។ លោកមេធាវី វ៉ែន ពៅ នឹងចាប់ផ្តើមសួរមុន ហើយបន្ទាប់មក ខ្ញុំនឹងសួរសំណួរបន្តពីគាត់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី វ៉ែន ពៅ!

**លោក វ៉ែន ពៅ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពតំណាង សហព្រះរាជអាជ្ញា និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី សុខ ឈិន។ ខ្ញុំបាទឈ្មោះ វ៉ែន ពៅ ជាមេធាវីតំណាងដើមបណ្តឹង -- ខ្ញុំមានសំណួរមួយចំនួនតូចទេ ដើម្បីសួរបញ្ជាក់បន្ថែមនូវអ្វីដែលសហព្រះរាជអាជ្ញាបានសួររួចមកហើយ។ ជាដំបូង សំណួររបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់លោកដដែលទេ គឺក្នុងសំណួរ-ចម្លើយទី៧។ នៅក្នុងនោះ លោកបានបញ្ជាក់ថា នៅក្នុងក្រុមការងាររបស់លោក គឺមានចំនួន១៨នាក់ ដែលគេបែងចែកឲ្យលោកធ្វើការងារនៅស្ថានីយរថភ្លើងក្នុងខេត្តពោធិ៍សាត់នៅសម័យនោះ។ ខ្ញុំចង់សួរលោកថា តើក្នុងចំណោមសមាជិកក្រុមការងាររបស់លោកទាំង១៨នាក់នោះ ថាតើពួកគេសុទ្ធតែមន្ត្រីរដ្ឋការចាស់ៗដូចលោក ឬក៏ជាប្រភេទមនុស្សគេជ្រើសរើសចេញមកពីណាដែរបាទ?

**លោក សុខ ឈិន៖**

**ឆ៖** មនុស្សដែលចំនួន១៨នាក់ហ្នឹង បើតាមពិតជាៗបុគ្គលិកដែលរទេះភ្លើងពីដើម ដូចនៅខាងម៉ាស៊ីន ក្បាលម៉ាស៊ីន និងទូរថភ្លើង។ នៅខាងស្ថានីយ គេបញ្ចូលមកខាងជួសជុលផ្លូវដែក។ ឯជំនាន់ -- ហើយខ្ញុំអត់បានបញ្ជាក់ ហើយ៣នាក់ទៀត ជាយោធាក្តោបក្តាប់។ ទាំងអស់ហ្នឹង វា២១នាក់ ស្មើនឹង២១គីឡូម៉ែត្រ បាទ ២១នាក់។ ថែមយោធា បីនាក់ក្តាប់ពីលើខាងខ្ញុំទៀតបាទ។

[១១:២២:៣៩]

**ស៖** បាទ ខ្ញុំសូមឈានដល់សំណួរមួយទៀត គឺសំណួរចម្លើយរបស់លោកដដែលទេនៅលេខរៀងទី១០។ នៅក្នុងសំណួរនោះបានសួរលោកថា លោកដឹងថាតាមូម បានរាយការណ៍ផ្ទាល់ទៅអង្គភាពផ្លូវដែកនៅទីក្រុងភ្នំពេញ។ សំណួររបស់ខ្ញុំ ចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់ថា តើការរាយការណ៍ផ្ទាល់នោះតាមមធ្យោបាយអ្វីខ្លះទៅ? លោកអាចរៀបរាប់បានទេ? គាត់ទៅរាយការណ៍ផ្ទាល់នៅភ្នំពេញ ឬក៏គាត់ប្រើមធ្យោបាយអីផ្សេងទៀតបាទ?

**ឆ៖** បាទ ខ្ញុំអត់ដឹង អត់ដឹងគាត់។ តែពេល ឧបមាថា វាត្រូវការគាត់រៀនសូត្រ ក៏ខ្លួនគាត់ទៅមានថ្ងៃគេហៅទៅរៀនសូត្រហ្នឹង គឺគាត់ទៅរៀនសូត្រនៅភ្នំពេញ។ តែទិសណែនាំ មិនដឹងគាត់រាយ-ការណ៍តាមអី គឺខ្ញុំអត់ដឹង តែគាត់អញ្ជើញទៅ ទៅតាមរទេះភ្លើង។ ពេលនេះមានរទេះភ្លើងជូនគាត់ទៅទៅភ្នំពេញបាទ។

[១១:២៣:៣៤]

**ស៖** បាទ សំណួរ-ចម្លើយរបស់លោកដដែល គឺសំណួរ-ចម្លើយទី១៣ ដដែល។ នៅក្នុងនោះ លោកៗបានបញ្ជាក់ថា ខ្ញុំសូមអានចម្លើយទី១៣។ លោកបានបញ្ជាក់ថា "មានការប្រជុំ រៀនទិតៀនក្នុងក្រុមរបស់លោក តាមាក់ គាត់ហ្នឹងដឹកនាំប្រជុំនោះ។ ប្រជុំនោះត្រូវធ្វើរាល់ថ្ងៃបន្ទាប់ពីការងារស្លួលហើយ"។ ខ្ញុំចង់បញ្ជាក់លោកថា តើលោកអាចបញ្ជាក់ឲ្យច្បាស់ថែមទេ តើការងារស្លួលរបស់លោកនៅសម័យនោះជាអ្វីទៅបាទ?

**ឆ៖** ការងារស្លួលនៅជំនាន់នោះ។ ការងារស្លួល គឺជួសជុលពង្រឹងផ្លូវដែក ឯការងារសង្គមនិយមវិញ គឺបង្កបង្កើនផល។

**ស៖** សូមអរគុណ។ ខ្ញុំចូលដល់សំណួរ-ចម្លើយរបស់លោកទី១៥ម្តង។ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងចម្លើយរបស់លោកហាក់ដូចបង្ហាញថា លោកដឹងការជម្លៀសប្រជាជនចេញពីក្នុងភ្នំពេញតែពីរដំណាក់កាលទេ។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា តើដំណាក់កាលទី១ គឺក្នុងខែមេសា ឆ្នាំ៧៥។ ដំណាក់កាលទី២ ចន្លោះខែតុលា ដល់ ខែវិច្ឆិកា ឬធ្នូ ឆ្នាំ៧៥ ហើយដំណាក់កាលមួយទៀតគឺយើងដឹងហើយ គឺដំណាក់កាលទី៣ ឆ្នាំ១៩៧៨។ តើលោកមានសង្កេតឃើញថាមានការដឹកជញ្ជូនជម្លៀសប្រជាជនហ្នឹងជា បីដំណាក់កាល ឬក៏ពីរដំណាក់កាលបាទ?

**ប្រធានអង្គជំនុំ៖**

អត់ទាន់បើកក្បាល -- ចាំក្បាលមីក្រូដំណើរការសិនបាទ។

**លោក សុខ ឈិន៖**

**ឆ៖** តាមដែលខ្ញុំដឹង ដឹកតាមរទេះភ្លើងតែពីរដំណាក់កាលទេ។ គឺដំណាក់កាលដែលជម្លៀសចេញពីភ្នំពេញគឺខ្ញុំអត់បានដឹង ខ្ញុំដឹងតែដំណាក់កាលក្រោយមក ជម្លៀសមក ខ្ញុំដឹងដំណាក់កាលទី១ គឺដឹកដែល -- ដូចខ្ញុំថាអ៊ីចឹងប្រជាជនដែលថ្មីសុទ្ធ។ ឯដំណាក់កាលទី២ គឺដឹកៗដែរ ដឹកប្រជាជនដែរចេញពីក្រុងភ្នំពេញ។

[១១:២៦:១០]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ សំណួរខ្ញុំទី១៥ ដដែល ខ្ញុំចង់បញ្ជាក់លោកថា តាមបទពិសោធន៍ ឬក៏អ្វីដែលលោកបានឃើញដោយផ្ទាល់ភ្នែកនៅពេលនោះ ជាពិសេសគឺក្នុងខែមេសា ឆ្នាំ១៩៧៥ នោះ ថាតើក្រៅពីលោកបានឃើញការជម្លៀសប្រជាជនកម្ពុជាចេញពីទីក្រុងភ្នំពេញដោយបង្ខំតាមរថភ្លើងដែលលោកធ្វើការនៅ

ទីនោះផ្ទាល់ តើលោកមានសង្កេត ឬពិនិត្យឃើញថាមានមធ្យោបាយណាផ្សេងទៀតក្នុងការដឹកប្រជាជន តាម ឆ្លងកាត់នៅតំបន់ដែលលោកធ្វើការនោះទេបាទ?

**ផ៖** បាទ ខ្ញុំបាទអត់បានដឹងទេ ខ្ញុំដឹងតែដឹកតាមរទេះភ្លើងទេ បាទ។

**ស៖** បាទៗ ខ្ញុំឈានដល់សំណួរទី១៨ ដដែល។ ក្នុងនេះលោកបានឆ្លើយរួចហើយបញ្ជាក់ទៅនឹងសហព្រះរាជអាជ្ញាជាតិថា "លោកបានសង្កេតឃើញនៅតាមទូរថភ្លើងនីមួយៗហ្នឹងមានយោធាជាកងទ័ពខ្មែរក្រហមហ្នឹងយាមប្រហែលជាពីរនាក់ចុងទូ ដើមទូ"។ ខ្ញុំចង់សួរលោកបន្ថែមថា តើការសង្កេតរបស់លោកផ្ទាល់ តើលោកឃើញទឹកមុខ ឬក៏សកម្មភាព ឥរិយាបថរបស់យោធាទាំងនោះបែបណាដែរ តើលោកអាចបញ្ជាក់បានទេបាទ?

[១១:២៧:៤០]

**ផ៖** បាទ ខ្ញុំបានឃើញទឹកមុខគាត់ធម្មតា ព្រោះជាអ្នកៗគ្រប់គ្រង ជាអ្នកនេះហើយ ទឹកមុខបែបសប្បាយរីករាយបន្តិច។ ឃើញសកម្មភាពទាំងអស់ហ្នឹងគាត់សប្បាយនឹងមុខងាររបស់គាត់បាទ។

**ស៖** ហើយលោកក៏បានឆ្លើយបញ្ជាក់ទៅសហព្រះរាជអាជ្ញាផងដែរ ថាលោកបានសង្កេតថាមាននៅក្នុងទូនីមួយៗ ទូរថភ្លើងនោះគឺថាមានប្រជាជនដែលនៅក្នុងនោះប្រហែលពី ៤០ ទៅ ៥០នាក់ តើលោកមានបានសង្កេត តើការអង្គុយ ឬក៏ជិះនៅក្នុងទូនីមួយៗហ្នឹងបែបប្រជ្រៀតគ្នា ឬក៏ធម្មតាបាទ? លោកអាចបញ្ជាក់ពីស្ថានភាពនៅពេលនោះបានទេបាទ?

**ផ៖** ទូរទេះភ្លើងនៅពេលនោះ ទូអ្នកដំណើរអត់មានបង់អង្គុយទេ។ បាទ គឺយកទូដឹកទំនិញយកទៅដឹកអ្នកដំណើរ។ ម្ល៉ោះហើយគឺអង្គុយនឹងក្ដារផ្ទាល់បាទ។ ក្ដារបាតប្លង់ នឹងក្ដារផ្ទាល់ អត់មានបង់អង្គុយទេបាទ។ ច្រងេងច្រងាង តាពីសតាពាសតាមហ្នឹងទៅបាទ ខ្លះអង្គុយ ខ្លះឈរទៅបាទ។

**ស៖** បាទ ខ្ញុំៗសូមបន្តសំណួរទី១៨ នៅសំណួរ-ចម្លើយរបស់លោកដដែល។ លោក -- ខ្ញុំសូមអានលោកបានឆ្លើយថា "ទាហាន ប៉ុល ពត ប្រដាប់អាវុធបានយាមពួកគេនៅក្នុងរថភ្លើង ហើយពួកគេប្រាប់ប្រជាជននៅពេលវេលា និងកន្លែងត្រូវចាកចេញពីរថភ្លើងក្នុងទីតាំងផ្សេងៗ"។ សំណួររបស់ខ្ញុំចង់សួរថា តើនៅទីតាំងផ្សេងៗ ទិសដៅ គោលដៅ ដែលគេត្រូវចុះនោះ តើលោកមានបានសង្កេតឃើញមានថ្នាក់ដឹកនាំមូលដ្ឋានដូចជាគណៈស្រុក ប្រធានសហករណ៍ គេមករង់ចាំទទួលទេបាទ?

[១១:២៩:៣៤]

**ផ៖** គឺខ្ញុំអត់បានស្គាល់ប្រជាជនស៊ីវិល ខ្ញុំបានស្គាល់ខាងណាប្រធានសហករណ៍ ឬអីទេ។ ខ្ញុំ

អត់បានស្គាល់ទេ។ ឃើញតែគេយកឡានមក ហៅប្រជាជនឡើងទៅ មិនដឹងគេ តួនាទីជាស្អី បើខ្ញុំអត់បានដឹង។ មើលឡាន ហា! ក្រុមនេះឡើងទៅ ហា! ក្រុមនោះឡើងទៅ។ បាទ ខ្ញុំអត់បានដឹង។ ហ្នឹងឃើញ ខ្ញុំឃើញផ្ទាល់បាទ។

**សះ** បាទ សូមអរគុណ។ ខ្ញុំបន្តសំណួរចម្លើយរបស់លោកទី២២។ នៅក្នុងសំណួរចម្លើយរបស់លោកទី២២ លោកបានបញ្ជាក់ថា "ខ្ញុំមិនចាំអ្វីទៀតទេ ខ្ញុំថា ប្រជាជនខ្លះត្រូវបង្ខំឲ្យចាកចេញពីរថភ្លើង។ ចំណែកអ្នកដទៃទៀត បន្តដំណើរទៅកាន់ខេត្តបាត់ដំបង"។ ខ្ញុំចង់សួរលោកថា នៅពេលដែលរថភ្លើងទាំងនោះត្រឡប់មកវិញ មានឃើញដឹកអ្វីផ្សេង ឬក៏ជារថភ្លើងទទេបាទ?

**ឆះ** ពេលរទេះភ្លើងត្រឡប់មកវិញ មានតែបុគ្គលិកខ្សែរថ ប្រហែលជាបីនាក់តែប៉ុណ្ណោះ និងអ្នកបើកក្បាលម៉ាស៊ីន បីនាក់បាទ និងយោធាដែលអមដំណើរ។

[១១:៣១:១៥]

**សះ** សំណួរខ្ញុំមួយទៀតដែរ ពាក់ព័ន្ធនឹងការដឹកប្រជាជនដោយបង្ខំនេះដែរ។ ខ្ញុំចង់សួរលោកថានៅក្នុងបទពិសោធន៍របស់លោកទាំងមូល នៅក្នុងរបបខ្មែរក្រហម ដែលលោកបានធ្វើការនៅនឹងតាមផ្លូវរថភ្លើងនោះ ជាពិសេស គឺក្នុងអំឡុងពេលខែមេសា ឆ្នាំ១៩៧៥ លោកបានបញ្ជាក់ហើយថា លោកបានឃើញមានប្រជាជន មានកុមារ ចាស់ជរា ស្ត្រី អ្នកជំងឺ ដែលត្រូវបានដឹងឆ្លងកាត់តាមតំបន់នោះ។ តើក្រៅពីប្រជាជនដែលលោកបានរៀបរាប់ខាងលើនោះ ថាតើមានដូចជា ព្រះសង្ឃ ត្រូវបានគេដឹកចេញនៅតាមរថភ្លើងទាំងនោះដែរឬទេ បាទ?

**ឆះ** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

អត់ទាន់ៗ ក្បាលមីក្រូ អត់ទាន់ប្រតិបត្តិការទេ បាទ។

**លោក សុខ ឈិន៖**

**ឆះ** ខ្ញុំអត់បានឃើញព្រះសង្ឃដឹកតាមរថភ្លើងទេ តែតាមឮសួរដែលគេថា គឺព្រះសង្ឃ គឺសឹកបាត់រួចអស់ហើយ បានគេបញ្ជូនមក បាទ។

[១១:៣២:២១]

**សះ** បាទ សំណួរខ្ញុំមួយទៀត ខ្ញុំនៅសល់តែពីរសំណួរទៀតទេ។ ខ្ញុំចង់សួរលោកថា នៅក្នុងរបបខ្មែរក្រហមទាំងមូល តើសិទ្ធិសេរីភាពក្នុងការដើរហើរ ក្នុងឋានៈលោកធ្វើការឲ្យស្ថានីយរថភ្លើង

នៅក្នុងខេត្តពោធិ៍សាត់ តើលោកមានសិទ្ធិសេរីភាពពេញលេញក្នុងការដើរហើរទេបាទ?

**ឆ៖** ខ្ញុំបាទ អត់មានសិទ្ធិដើរហើរ ក្រៅពីតាមដងផ្លូវដែកទេ បាទ។

**ស៖** បាទ នេះគឺសំណួរចុងក្រោយរបស់ខ្ញុំ គឺជាចម្លើយរបស់លោកនៅក្នុងសំណួរចម្លើយទី២៧ លោកបានឆ្លើយ -- សំណួរសួរលោក -- សំណួរសួរ "ថាតើ នួន ជា, អៀង សារី, ខៀវ សំផន ធ្លាប់ធ្វើដំណើរមកកាន់តំបន់ដែលលោកធ្វើការដែរឬទេ?" លោកឆ្លើយថា"មិនដឹងទេ"។ សំណួរខ្ញុំចង់សួរថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល នៅក្នុងអង្គភាពរបស់លោក តើមានវិទ្យុស្តាប់? លោកធ្លាប់ដែលស្តាប់វិទ្យុ ឬក៏ការផ្សាយសំឡេងរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យ នៅទីក្រុងភ្នំពេញពីឈ្មោះមេដឹកនាំខ្មែរក្រហមទាំងនេះទេបាទ?

[១១:៣៣:៥២]

**ឆ៖** បាទ ជំនាន់នោះ អត់មានទេ អត់វិទ្យុស្តាប់ អត់អីទេ បាទ។

**ស៖** បើសិនជាគ្មាន អ៎! លោកបានឆ្លើយថា គ្មានវិទ្យុស្តាប់ តើការប្រជុំដែលលោកថាមានការប្រជុំជាញឹកញាប់ រៀនវគ្គនយោបាយ ឬក៏ប្រជុំទិតៀនគ្នា តើក្នុងពេលប្រជុំទាំងអស់នោះ ថាតើមានដែលថ្នាក់ដឹកនាំរបស់លោក លើកបង្ហាញពីឈ្មោះមេដឹកនាំកម្ពុជាប្រជាធិបតេយ្យឲ្យលោកស្តាប់ទេ? អ្នកណាមានតួនាទីអី? អ្នកណាអីទេ បាទ?

**ឆ៖** បាទ គេបានប្រាប់។ បើថាយើងចូលសាលារៀនទៅ គេឲ្យគោរពទង់បក្ស គោរពទង់បក្ស គោរពទង់ជាតិរួច បានគេឧទ្ទេសនាម បានគេផ្សព្វផ្សាយ។ ហ្នឹងគេបង្ហាញដែរ លោក នួន ជា, ខៀវ សំផន, អៀង សារី ហ្នឹង គាត់ធ្វើអីៗ បាទ ខ្ញុំបានដឹងតាមរយៈហ្នឹងដែរ។

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា គេបានប្រាប់លោក តើលោកចាំទេ តើគេប្រាប់លោកនៅពេលនោះ ថាតើលោក នួន ជា គាត់មានឋានៈជាអ្វីដែរ នៅពេលនោះបាទ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១១:៣៥:០០]

**ប្រធានអង្គជំនុំ៖**

ចាំៗសិន! សាក្សី ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក សុខ ឈិន៖**

**ឆ៖** បាទ អង្កាល់ហ្នឹងមេ -- អង្កាល់ហ្នឹងប្រធានអង្គប្រជុំ តាមូម គាត់អត់បានប្រាប់ទេ។ តែខ្ញុំ

ទើបនឹងដឹងឥឡូវនេះ តា នួន ជា គាត់ប្រធានរដ្ឋសភាទៅ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេ ប៉ៅ៖**

សំណួរដែលបានឆ្លើយនេះវា -- ដែលបានសួរនេះ គឺថា ខ្ញុំដូចជាជំទាស់យឺតពេលបន្តិចហើយ។ ការដែលសួរបែបនេះ គឺឲ្យសាក្សីទាយស្មានទៅលើអ្វីដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១១:៣៦:០៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តសំណួរទៀត ប្រសិនបើមានលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក វ៉ែន ពៅ៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួន ដើម្បីចោទសួរលោក លោកសាក្សី ដើម្បីបំពេញទៅលើចម្លើយរបស់លោករហូតមកទាល់ពេលនេះ។ ជាបឋមខ្ញុំសួរសំណួរពាក់ព័ន្ធទៅនឹងចំណុចដូចតទៅនេះ។ លោកឆ្លើយថា អ្នកធ្វើការនៅផ្លូវដែកកាលមុននោះ គឺបន្តធ្វើការជាមួយលោកទៀត។ ហើយនៅក្នុងចម្លើយទី៩របស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកសរសេរថា "ខ្មែរក្រហមដែលត្រូវបានតែងតាំងថ្មីនោះ ត្រូវរក្សា អ៊ំព្រឿង ដោយសារតែគាត់មានសមត្ថភាពខាងផ្នែកបច្ចេកទេស"។ ចុះកម្មាភិបាលចាស់ៗរបស់ស្ថានីយរថ -- ស្ថានីយផ្លូវដែកនេះត្រូវបានគេរក្សាទុកដែរឬទេ?

[១១:៣៧:២៦]

**លោក សុខ ឈិន៖**

**ឆ៖** អ៊ំព្រឿង ហ្នឹងគាត់ជាប្រធាន ៗប្រធានបច្ចេកទេសខាងផ្លូវដែក។ បាទ គេរក្សាទុកគាត់។

**ស៖** ចុះកម្មាភិបាលផ្សេងទៀតខាងផ្នែកផ្លូវដែកហ្នឹង ក្រៅពី អ៊ំព្រឿង ហ្នឹង តើគេមានទុក រក្សាទុកអ្នកណាផ្សេងទៀតទេ?

**ឆ៖** ខ្ញុំដឹងតែតំបន់ខ្ញុំ គឺ អ៊ំព្រឿង ប៉ុន្តែនៅតំបន់ផ្សេងទៀត គឺខ្ញុំអត់បានដឹង។

**ស៖** បើលោកមិនដឹងក៏មិនអីដែរលោកសាក្សី។ ឥឡូវនេះខ្ញុំចង់ចោទសួរឡើងវិញ នូវសំណួរពាក់ព័ន្ធទៅនឹងរថភ្លើងដែលលោកបានឃើញ ពីព្រោះថាលោកជាសាក្សីផ្ទាល់។ យើងៗមិនបានឃើញព្រឹត្តិការណ៍ទាំងអស់នោះទេ។ ដូច្នេះយើងចង់បានព័ត៌មានលម្អិតអំពីលោក សូមលោកមេត្តាផ្តល់ចម្លើយឲ្យបានលម្អិតបំផុត ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានឃើញ ដើម្បីឲ្យយើងបានយល់ច្បាស់អំពីហេតុការណ៍។ ខ្ញុំត្រឡប់មកនិយាយអំពីរថភ្លើងវិញ។ ជាពិសេសគឺចម្លើយទី១៥ ដល់២០ ដែលលោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ជាដំបូងនោះ លោកបានឆ្លើយនូវចម្លើយ១៥ ថា "គេមានដឹកមនុស្សតាមទូទំនិញ"។ ហើយលោកឆ្លើយព្រឹកមិញថា គឺរទេះភ្លើងចាស់ៗដែលគេប្រើនោះ លោកថា "ពួកគេត្រូវអង្គុយផ្ទាល់ដី ហើយមានមនុស្សប្រហែលជា៤០ ទៅ៥០ នាក់ក្នុងមួយទូៗ"។ តើប្រជាជននៅក្នុងទូនីមួយៗហ្នឹងប្រជ្រៀតគ្នាដែរឬទេ?

[១១:៣៩:៤៤]

**ឆ៖** ប្រជាជនដែលនៅក្នុងនុំង អត់បានប្រជ្រៀតគ្នាទេ វាទៅតាមចំណុះរបស់ទូ។ ចំណុះរបស់ទូគេឲ្យដាក់ប៉ុណ្ណឹង គឺប្រជាជនប៉ុណ្ណឹង អង្គាល់ហ្នឹងលើសបន្តិចបន្តួចប៉ុណ្ណឹងឯង។ វាអត់ប្រជ្រៀតគ្នាទេ មើលទៅទូលាយដែរ បាទ។

**ស៖** ហើយពួកគេអាចអង្គុយទាំងអស់គ្នាបាទទេ?

**ឆ៖** បាទ អាចអង្គុយបាន បើអ្នកណាចង់អង្គុយៗទៅ អ្នកណាចង់ឈរៗទៅបាទ។ អត់ដើរចេញទៅទូផ្សេងៗទៀតទេ បានទេ គឺនៅតែក្នុងទូដែលយើងជិះហ្នឹង។ ហ្នឹងដើរបាន អង្គុយបានតែទូដែលយើងជិះ។

**ស៖** សូមអរគុណ។ នៅពេលរថភ្លើងឈប់នៅលាជ តើលោកដឹងថារថភ្លើងឈប់នោះ ឈប់រយៈពេលយូរទេ នៅលាជហ្នឹង?

**ឆ៖** បាទ ខ្ញុំមិនបានដឹងពេលវេលារទេះភ្លើងដែលឈប់ទេ តែទាល់តែប្រជាជនចុះអស់ ឬក៏ដាក់ប្រជាជន ឧបមាថាបួនប្រាំទូអីចឹង សល់១០ទូអី គេត្រូវអូសបង្ហួសទៅខាងពោធិ៍សាត់ទៀត ឬ -- អ៊ំ!ទៅខាងមោង ទៅខាងអីទៀតបាទ។ ខ្ញុំមិនដឹងពេលវេលាដែលរទេះភ្លើងនៅហ្នឹងទេបាទ។

[១១:៤១:៣៦]

**ស៖** តើរថភ្លើងនោះឈប់បញ្ឈប់ត្រាស់ថ្ងៃ ឬក៏បណ្តោយថ្ងៃ? មានទូដែលឈប់បញ្ឈប់ត្រាស់ ឬបណ្តោយថ្ងៃទេ?

**ឆ៖** ទូហ្នឹង បើត្រូវបណ្តោយថ្ងៃក៏បណ្តោយទៅ ត្រូវបញ្ឈប់ត្រាស់ថ្ងៃបញ្ឈប់ត្រាស់ទៅ វាតាមៗចតនៅលើផ្លូវបាទ នៅលើផ្លូវដែកបាទ។ តាមស្ថានភាពផ្លូវដែកបាទ។

**ស៖** លោកនិយាយអំពីអ្នកចុះពីរថភ្លើង ហើយត្រូវរង់ចាំប្រហែល១អាទិត្យ ដើម្បីទៅកន្លែងផ្សេង ហើយលោកនិយាយអំពីជំងឺ មានអ្នកស្លាប់ មានសាកសព ហើយនិងនិយាយអំពីក្លិនអសោចនៃសាកសពទាំងអស់នោះ។ លោកនិយាយថា ពួកគេមិនមានការថែទាំ ហើយនិងមិនទទួលទទួលបានអាហារទេ។ ហើយពួកគេមានទទួលបានទឹកផឹកទេ ហើយបើទទួលបាន តើទឹកហ្នឹងបានមកពីណាដែរ?

**ឆ៖** បាទ ខ្ញុំឃើញផ្ទាល់នឹងភ្នែកគ្មានរបបទឹកទេ គឺទឹកដែល ហូបៗទឹកតាមវាលស្រែ។ តាមវាលស្រែ ដែលទឹកដក់នៅតាមវាលស្រែ គ្មានឃើញអ្នកណាដែលយកទឹកមកប្រគល់ឲ្យគេផឹក អត់មានបាទ។

[១១:៤៣:២៩]

**ស៖** សូមអរគុណ។ ចុះពួកគាត់ដេកយ៉ាងម៉េចដែរ តើមានអង្រឹងដេក ឬក៏មានអីសម្រាប់ការពារសត្វល្អិតសម្រាប់កុំឲ្យខាំទិចអីទេ?

**ឆ៖** រឿងដេកទៅតាមលទ្ធភាពផ្ទាល់ខ្លួន។ ខ្លះក៏គ្មានស្អី ខ្លះក៏មានសំពត់កៅស៊ូចងពីលើទៅ មិនឲ្យត្រូវកម្តៅថ្ងៃ ឬក៏សន្សើមអី គឺគ្មានដេកអីត្រឹមត្រូវទេបាទ។ អត់មានរបៀបរបបដេកត្រឹមត្រូវទេ ដេកតាមភ្លឺស្រែ វាលស្រែទៅបាទ ឬក៏គុម្ពោតព្រៃត្រង់ណាត្រង់ណីអីទៅ ជួនកាលអាខ្លះឆ្ការព្រៃទៅ ដេកទៅតាមព្រៃផ្សេងៗហ្នឹងបាទ។

**ស៖** ចុះគេមានចែកមុងឲ្យទេ?

**ឆ៖** គ្មានទេ គ្មានគេចែកអីឲ្យទេ បាទ។ អ្នកណាមានមុង គឺមានមុងផ្ទាល់ខ្លួន ពីផ្ទះពីសម្បែងបានស្ពាយទៅ ក៏បានចងទៅ។ អ្នកណាអត់បានមុងទៅ ក៏ដេកហាលវាលហ្នឹងទៅបាទ។

[១១:៤៥:០០]

**ស៖** ចុះលក្ខខណ្ឌអនាម័យវិញនោះ តើមានអ្វីសម្រាប់ងូតទឹកអ្វីទេ?

**ឆ៖** អត់មានអនាម័យអីទេ គ្មានអ្វីសម្រាប់ងូតទឹកអីអ៊ីចឹង អត់មានទេ។ គ្មានអនាម័យទេ ជួន

កាលគ្មានទឹកងូតផង ដាក់កន្លែងលាជអ៊ីចឹង។ ជួនកាលមានទឹកអីដក់តាមវាលស្រែ មុជតាមវាលស្រែ ទៅមុជហើយទៅដងៗហូបទឹកវាលស្រែហ្នឹងទៅបាទ។

**ស៖** លោកៗនិយាយថា លោកលាងខ្លួនហ្នឹងបានន័យថា ទឹកហ្នឹងហើយយកមកងូតហើយ យកទៅផឹកទៀត។ តើអ៊ីចឹងមែនទេ?

[១១:៤៥:៥៧]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកបានឆ្លើយថា លោកមិនអាចនិយាយជាមួយមនុស្សទាំងអស់នោះទេ។ តើថ្នាក់លើ របស់លោកនោះ អនុញ្ញាតឲ្យលោកមានផ្តល់ជំនួយអីទៅដល់អ្នកទាំងអស់នុ៎ងទេ?

**ឆ៖** គ្មានបានផ្តល់ជំនួយអីទេ ព្រោះលទ្ធភាពរៀងខ្លួន ខ្ញុំក៏ខ្វះរបបដែរ មានអី មានរបបអីត្រឹម ត្រូវអត់មាន។ ទឹកសម្រាប់តែខ្លួនឯងអ៊ីចឹង ដាក់មួយប៊ីដុងមកសម្រាប់តែខ្លួនឯងហូប គ្មានបានចែកចាយ អីដល់គ្នាទេ។ អត់មានទេ របបរៀងខ្លួនបាទ។

**ស៖** សូមអរគុណ។ ខ្ញុំជិតចប់ហើយលោកសាក្សី។ លោកបានឃើញហេតុការណ៍ទាំងអស់ នោះ ហើយសូមអរគុណដែលលោកផ្តល់នូវព័ត៌មានលម្អិតដើម្បីឲ្យយើងយល់អំពីហេតុការណ៍។ តើ ហេតុការណ៍ដែលលោកបានឃើញទាំងនោះ លោកធ្លាប់មានពិភាក្សាអំពីរឿងទាំងអស់នុ៎ងជាមួយនឹង មិត្តភក្តិដែលធ្វើការជាមួយលោកទេ?

[១១:៤៧:២២]

**ឆ៖** បាទ ខ្ញុំមានពិភាក្សាជាមួយ មានតែការសោកសង្រេង ការនឹកអាណិតអាសូរដល់ពួកគាត់ បាទ ហើយខ្លួនឯងផ្ទាល់ក៏វាពិបាកដូចតែគាត់ដែរបាទ។

**ស៖** នៅពេលដែលលោកនិយាយអំពី -- ជាមួយមិត្តភក្តិរបស់លោកនោះ តើលោកនិយាយគ្នា យ៉ាងម៉េចដែរ ហើយលោកពន្យល់គ្នាថាមានហេតុផលយ៉ាងម៉េចបានជាធ្វើអ៊ីចឹងយ៉ាងម៉េចដែរទេ?

**ឆ៖** បាទ ខ្ញុំអត់បាននិយាយពីរឿងហេតុផលទេ។ ខ្ញុំមានតែនឹកអាណិតអាសូរសោកស្តាយ ឃើញប្រជាជនខ្វះខាតអីអ៊ីចឹងទៅអត់បាននិយាយពីរឿងអីទេបាទ។ ហើយគេមិនឲ្យនិយាយទៀតពីរឿង ខ្វះខាតជំនាន់នោះ។ យើងស៊ីមិនឆ្អែត ក៏ថាឆ្អែតបាទ។

**ស៖** ហេតុអ្វីបានជាលោកមិនហ៊ាននិយាយអ្វីសោះនោះ?

[១១:៤៨:៥៥]

**លោក សុន អរុណ៖**

សូមជំទាស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

សំណួរនេះ ជាសំណួរប្រមាណវិធី។ ខ្ញុំសូមជំទាស់។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគ្រាន់តែសួរឲ្យគាត់ឆ្លើយឲ្យបានច្បាស់ ថាតើមូលហេតុអ្វីបានជាគាត់បង្ខំចិត្តមិននិយាយគ្នានោះ។ ដូច្នេះនេះមិនមែនជាសំណួរបែបឧបមាណវិធីទេ វាជាសំណួរដើម្បីរកការពិត។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់មិនមានមូលហេតុសមស្របទេ។ សេចក្តីជំទាស់មិនមានប្រសិទ្ធភាព។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលសួរលោកអម្បាញ់មិញនេះ!

[១១:៥០:១៦]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី គាត់ សាក្សីទំនងជាភ្លេចសំណួរលោកស្រីហើយ។ លោកស្រីតាំងសំណួរនោះសាជាថ្មីម្តងទៀត ដើម្បីឲ្យគាត់ស្តាប់បាន ហើយអាចឆ្លើយតបបាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកសាក្សី លោកឆ្លើយថា លោកអាណិតចំពោះអ្នកទាំងអស់នោះ ក៏ប៉ុន្តែលោកបង្ខំចិត្តមិននិយាយអ្វីទាំងអស់។ ដូច្នេះ ខ្ញុំចង់សួរលោកថា ហេតុអ្វីក៏បានជាលោកបង្ខំចិត្តមិននិយាយអ្វីសោះនោះ?

**លោក សុខ ឈិន៖**

**ឆ៖** បើរឿងគំនិតខ្លួនខ្ញុំផ្ទាល់ គឺខ្ញុំមានអីនិយាយ មានការងារអីនឹងនិយាយ មានការងារតែអាណិតអាសូរប៉ុណ្ណឹង។ វាការងារដែលត្រូវនិយាយ ក៏មិនដឹងនិយាយពីរឿងអីបាទ។ អត់ដឹងនិយាយរឿងពីអី សួរនាំពីរឿងអីបាន។ បើឃើញតែលំបាក ឃើញតែវេទនា ឃើញតែវាយហែមហាមអីចឹង។ មិនដឹងជានិយាយថាម៉េចបាទ។ យើងក៏អត់ គាត់ក៏អត់។

[១១:៥១:៤១]

**ស៖** លោកសាក្សី ខ្ញុំសួរសំណួរចុងក្រោយមួយទៀត។ តើលោកខ្លាចទេ នៅក្នុងពេលដែលលោកនិយាយអ្វីមួយនោះនៅសម័យហ្នឹង?

**ឆ៖** បាទ ខ្ញុំខ្លាចជាទីបំផុត ការងារដែលដឹងស្អីក៏អត់និយាយដែរ។ គេឲ្យខ្ញុំដាំដើមគ បាទ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកសាក្សី ដែលបានឆ្លើយសំណួរខ្ញុំ។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្តី ហើយលោកមេធាវីការពារក្តីលោក នួន ជា តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ? ហើយបើត្រូវសួរ តើចំណាយពេលវេលាប៉ុន្មាន ប្រហែលប៉ុន្មានដែរ?

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ក្រុមមេធាវី នួន ជា ប្រហែលជាត្រូវការ១ម៉ោង សម្រាប់ការតាំងសំណួរ។ បើអាចមុន ខ្លីជាងនេះ -- យឺត បានន័យថា ក្រោម១ម៉ោងបន្តិច ឬក៏លើស១ម៉ោងបន្តិច។ តែយើងត្រូវការចាំបាច់ គឺ១ម៉ោងសម្រាប់ការតាំងសំណួរ។

[១១:៥៣:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៣:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការផ្តល់ព័ត៌មាននេះ។ ហើយមុននឹងសម្រាក អង្គជំនុំជម្រះសូមប្រកាសជូនដំណឹងអំពីការកែប្រែកាលវិភាគនៃការជំនុំជម្រះរបស់ខ្លួន ដែលនឹងត្រូវចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃចន្ទ ទី៥ ខែវិច្ឆិកា ឆ្នាំ២០១២ តទៅ។

ការិយាល័យជំនួយរដ្ឋបាលរបស់អង្គការសហប្រជាជាតិដល់តុលាការខ្មែរក្រហម បានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថា ដោយសារកង្វះថវិកា អង្គជំនុំជម្រះសាលាដំបូងពុំអាចជ្រើសរើសមន្ត្រីដើម្បីមកជំនួសកន្លែងមន្ត្រីច្បាប់អន្តរជាតិសំខាន់ៗមួយចំនួន និងបុគ្គលិកអន្តរជាតិដទៃទៀតបានឡើយ។ កង្វះខាតថវិកានេះ នាំឲ្យមានការកាត់បន្ថយចំនួនបុគ្គលិកប្រហែលជាពាក់កណ្តាលនៃចំនួននៅក្នុងបញ្ជី

បុគ្គលិកភាគីអន្តរជាតិ នៃអង្គជំនុំជម្រះសាលាដំបូង។

អស់រយៈពេលជាង៣ខែមកហើយ ដែលអង្គជំនុំជម្រះបានជូនដំណឹងម្តងហើយម្តងទៀតដល់ផ្នែកពាក់ព័ន្ធនៃអង្គការសហប្រជាជាតិ និងការិយាល័យជំនួយរដ្ឋបាលរបស់អង្គការសហប្រជាជាតិដល់តុលាការខ្មែរអំពីការលំបាក ដែលអង្គជំនុំជម្រះកំពុងជួបប្រឈមដោយសារផលវិបាកនៃការខ្វះខាតចំនួនបុគ្គលិក។

ជាការឆ្លើយតប មានការផ្តល់ការធានាថា បញ្ហាបុគ្គលិកនឹងត្រូវដោះស្រាយជាមិនខាន។ ប៉ុន្តែរហូតមកដល់ពេលនេះ ពុំទាន់មានការដោះស្រាយជាស្ថាពរណាមួយឡើយ។ ហេតុដូច្នេះ នាពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ផ្នែកពាក់ព័ន្ធទាំងនោះថា ដោយសារមានការខ្វះខាតចំនួនបុគ្គលិកដើម្បីជួយបំពេញការងាររបស់អង្គជំនុំជម្រះសាលាដំបូងនោះ អង្គជំនុំជម្រះពុំអាចបើកសវនាការចំនួន ៤ថ្ងៃបានទេ ហើយថា អង្គជំនុំជម្រះសាលាដំបូងមានការសោកស្តាយជាខ្លាំង ពីព្រោះថា ការកាត់បន្ថយចំនួនសវនាការប្រចាំឆ្នាំ អ៎! ប្រចាំសប្តាហ៍ នឹងនាំឲ្យមានការអូសបន្លាយពេលវេលាដែលចាំបាច់សម្រាប់បញ្ចប់សំណុំរឿង០០២/០១។

ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងពីបញ្ហានេះ ប្រហែលពីរសប្តាហ៍មកហើយក្តី ក៏ពុំទាន់មានការបញ្ជាក់ថា បញ្ហាបុគ្គលិកនឹងត្រូវដោះស្រាយឡើយ។ ដោយសារហេតុផលនេះ និងដើម្បីផ្តល់ការជូនដំណឹងដល់ភាគី និងសាធារណជនឲ្យបានទូលំទូលាយនោះ អង្គជំនុំជម្រះសូមជូនដំណឹងថា អង្គជំនុំជម្រះសាលាដំបូងនឹងបើកសវនាការតែ ៣ថ្ងៃប៉ុណ្ណោះ ក្នុងមួយសប្តាហ៍ គឺពីថ្ងៃចន្ទដល់ថ្ងៃពុធ ដោយចាប់អនុវត្តពីថ្ងៃចន្ទ ទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ តទៅ។ បាទ នេះជាការជម្រាបជូនដំណឹង។

[១១:៥៦:៥៨]

បាទ ឥឡូវនេះ កិច្ចដំណើរការសវនាការសម្រាប់ព្រឹកនេះ ដល់ពេលសមល្មមសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះប្រកាសដើម្បីសម្រាកពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះលើកបន្តធ្វើនៅរសៀលនេះ ដោយចាប់ផ្តើមពីម៉ោងមួយ និងសាមសិបនាទី។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា មុនបាទ!

**លោក ហ្សាស្តេ ប៉ោះ**

សូមអរគុណលោកប្រធាន។ លោក នួន ជា សូមស្នើសុំតាមនីតិវិធីក្នុងរសៀលនេះ ពីបន្ទប់

ខាងក្រោម ពីចម្ងាយ ដោយសារតែលោកមិនអាចផ្តោតអារម្មណ៍ និងមានបញ្ហាសុខភាព។ យើងខ្ញុំនឹងដាក់ជូនលិខិតបោះបង់សិទ្ធិនេះ ជូនអង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ដូចគ្នានេះដែរ លោក ខៀវ សំផន គាត់មិនអាចចូលរួមសវនាការដោយផ្ទាល់នៅពេលរសៀលនេះទេ ហើយសូមអនុញ្ញាតចូលរួមតាមដានសវនាការពីខាងក្រោម ដោយសារគាត់សម្រាន្តមិនលក់ជាច្រើនយប់ ហើយធ្វើឱ្យប៉ះពាល់ដល់ការផ្តោតអារម្មណ៍របស់គាត់។ ដូច្នេះសុំលោកប្រធានអនុញ្ញាត។ យើងខ្ញុំនឹងរៀបចំលិខិត ឯកសារជាផ្លូវការជូននៅពេលបន្តិចទៀតនេះ។ បាទ សូមអរគុណ។

[១១:៥៨:២១]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៩:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមមេធាវីការពារក្តីរបស់គាត់ និងសំណើសុំរបស់ជនជាប់ចោទ ខៀវ សំផន ដែលបានធ្វើឡើងតាមមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយមូលហេតុមានបញ្ហាសុខភាព មិនអាចអង្គុយយូរ តាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សនាវការនេះបាន។ ហើយដោយឡែក លោក ខៀវ សំផន គឺមានការបញ្ជាក់ដោយលោកវេជ្ជបណ្ឌិត ដែលទទួលបន្ទុកក្នុងការត្រួតពិនិត្យ ថែទាំសុខភាពជនជាប់ចោទនៅក្នុងបរិវេណនៃដំណើរការសវនាការនៅក្នុង អ.វ.ត.ក នេះ បានផ្តល់នូវអនុសាសន៍ដល់អង្គជំនុំជម្រះថា លោក ខៀវ សំផន គួរតែអនុញ្ញាតឲ្យគាត់ទៅសម្រាក ដើម្បីតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដោយមូលហេតុថា គាត់មានបញ្ហាសុខភាព មានភាពញ័រសាច់ ទន់ខ្លួន អស់កម្លាំងខ្លាំង ដោយគាត់សម្រាន្តមិនគ្រប់គ្រាន់ក្នុងរយៈពេល២យប់ ជាប់ៗគ្នា។

អង្គជំនុំជម្រះយល់ឃើញថា សំណើសុំរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន បានធ្វើឡើង

មានមូលហេតុសមស្រប។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា និងលោក ខៀវ សំផន ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយលោក នួន ជា និងលោក ខៀវ សំផន លះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី លោក នួន ជា និងលោក ខៀវ សំផន ប្រគល់ជូនមកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬក៏ផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់ជនជាប់ចោទ។

[១២:០១:១៦]

បង្គាប់ឲ្យបុគ្គលផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទទាំងពីររូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនដោយឡែកពីគ្នា ដែលស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមចុះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០៣]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះមុននឹងជូនវេទិកាទៅ

ក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសូមសួរថា តើចៅក្រម -- បាទ ចៅក្រម លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បើមានសំណួរអីសួរសាក្សី? សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមការបំភ្លឺទាក់ទងទៅនឹងព័ត៌មានដែលផ្តល់ជូន -- ប្រហែលជាផ្តល់ជូនហើយ គ្រាន់តែប្រហែលជាខ្ញុំស្តាប់មិនទាន់ ឬក៏យ៉ាងម៉េចទេ។

[១៣:៣៣:២០]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី លោកបានពន្យល់ថា ទាក់ទងទៅនឹងការដឹកមនុស្សតាមរទេះភ្លើង ហើយដែលឆ្លងកាត់តាមបាត់ដំបង។ លោកបានកត់សម្គាល់ថា មានពីរដំណាក់កាលគឺ ដំណាក់កាលទី១ ដែលថា បន្ទាប់ពីបែកភ្នំពេញនៅខែមេសា ឆ្នាំ៧៥ ហើយនិងដំណាក់កាលមួយទៀតនៅពេលក្រោយ។ អ្វីដែលខ្ញុំចង់ដឹងនោះគឺ តើលោកដឹងអំពីទិសដៅចុងក្រោយរបស់អ្នកដែលគេដឹកជញ្ជូនទាំងអស់នេះដែរឬទេ? លោកនិយាយអំពីស្ថានីយមួយចំនួន តើហួសពីស្ថានីយហ្នឹងទៀតនោះ តើបុគ្គលទាំងអស់ហ្នឹង មនុស្សទាំងអស់ហ្នឹងត្រូវបានគេដឹកទៅណាដែរ?

**លោក សុខ ឈិន៖**

**ឆ៖** បាទ សូមគោរពលោកប្រធាន។ ខ្ញុំមិនបានដឹងៗគេដឹកទៅណា ខ្ញុំអត់បានដឹងទេ។ ខ្ញុំបានដឹងគេដឹកតាមរទេះភ្លើង ចែកទៅតាមស្ថានីយ តាមតំបន់ផ្សេងៗ តែចំពោះចេញពីហ្នឹងទៀត ខ្ញុំអត់បានដឹង។

**ស៖** បាទ ដូច្នេះអ្វីដែលលោកដឹងហ្នឹងគឺថា មនុស្សទាំងអស់ហ្នឹង ត្រូវបានដឹកទៅសហករណ៍មួយចំនួន ក៏ប៉ុន្តែលោកមិនដឹងថាសហករណ៍ណាច្បាស់លាស់នោះទេ។ តើលោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំចង់និយាយអ៊ីចឹង។ គេដឹកចេញ ដឹងតែទៅសហករណ៍ហើយ តែមិនដឹង សហករណ៍ឯណាខ្លះ។

[១៣:៣៥:១៥]

**ស៖** ខ្ញុំមានសំណួរចុងក្រោយ។ លោកបាននិយាយអំពីការដឹកមនុស្សតាមផ្លូវដែក តាមរថភ្លើង តើលោកធ្លាប់បានឃើញ ការដឹកជញ្ជូនមនុស្សតាមមធ្យោបាយផ្សេងទៀតដែរឬទេ? ឧទាហរណ៍ដូចជា

E1/137.1

យានជំនិះផ្សេងទៀត ក្រៅពីរទេះភ្លើងនោះ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងគេដឹកយានជំនិះអីផ្សេងទៀត ក្រៅពីដឹកតាមរទេះភ្លើងទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកសាក្សី ខ្ញុំសូមអរគុណច្រើន។ លោកប្រធាន ខ្ញុំលែងមានសំណួរសួរទៅកាន់គាត់ទៀតហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសក្នុងការសួរដេញដោល ចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៣:៣៦:៣៤]

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់នៅខាងក្នុង ខាងក្រៅសាលសវនាការ។ ហើយសូមជម្រាបសួរលោកសាក្សី សុខ ឈិន។ ខ្ញុំ ហ្សាស្តើ ប៉ៅ ខ្ញុំជាមេធាវីការពារក្តីឲ្យលោក នួន ជា ជាមេធាវីអន្តរជាតិ។ ខ្ញុំនឹងសួរសំណួរលោកមួយចំនួនទាក់ទងទៅនឹងចម្លើយដែលលោកបានឆ្លើយឲ្យទៅសហចៅក្រមស៊ើបអង្កេត ហើយនិងបានឆ្លើយនៅព្រឹកនេះដែរ នៅថ្ងៃនេះដែរនៅតុលាការ។ ហើយខ្ញុំនឹងនិយាយយឺតៗ ដើម្បីឲ្យអ្នកបកប្រែបានបកបានស្រួល ដើម្បីឲ្យលោកស្រួលយល់ ប៉ុន្តែបើលោកមិនយល់ទេ សូមលោកសួរឲ្យខ្ញុំបំភ្លឺសំណួរទៅលោកក៏បានដែរ។

[១៣:៣៧:២៣]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** លោក សុខ ឈិន ព្រឹកមិញនេះ លោកនិយាយថាលោកមិននៅចាំឲ្យច្បាស់ទេថា នៅពេលណាដែលលោកបានផ្តល់សម្ភាសទៅឲ្យអ្នកស៊ើបអង្កេត មកពីការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ។ តើលោកអាចប្រាប់ពីពេល ថាតើពេលណា ឲ្យលោកនឹករក ថាតើរយៈពេលប៉ុន្មានមកហើយដែលអ្នកស៊ើបអង្កេតទៅជួបលោក ដើម្បីសម្ភាសនោះ?

**លោក ហ្សាស្តើ ប៉ោ៖**

សូមជម្រាបលោកប្រធាន ឃើញថាសាក្សីបានមើលកំណត់ហេតុ ដែលខ្ញុំ -- ឃើញថា សាក្សីគាត់ទៅមើលកំណត់ហេតុ។ ដូច្នេះ សូមលោកប្រធានបង្គាប់កុំឲ្យគាត់អាន។ ឲ្យគាត់ឆ្លើយតាមការចងចាំរបស់គាត់បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកសាក្សី មិនបាច់មើលហ្នឹងទេ លើកលែងតែចំណុចណាត្រូវផ្ទៀងផ្ទាត់ប៉ុណ្ណោះ។ សាក្សីបើចងចាំគឺ ឆ្លើយតបទៅ បើមិនចងចាំ គឺឆ្លើយតាមការដែលជាក់ស្តែង ដែលលោកមិនចាំទៅ ជាការស្រេចហើយ។

[១៣:៣៨:៣៧]

**លោក សុខ ឈិន៖**

**ឆ៖** បាទ ខ្ញុំមិនបានចាំពេលវេលាទេបាទ។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានឬទេ ថាតើតាមអ្វីដែលលោកចងចាំមួយឆ្នាំកន្លងទៅ ឬក៏២ឆ្នាំកន្លងទៅ ឬក៏៣ឆ្នាំកន្លងទៅ ឬក៏៤ឆ្នាំកន្លង ឬក៏៥ឆ្នាំកន្លងទៅ? សូមលោកព្យាយាមគិតឲ្យបានថាជាក់លាក់ជាងហ្នឹងបន្តិចតើបានទេ?

**ឆ៖** តាមដែលខ្ញុំគិតនឹកមើលទៅ ប្រហែលជាឆ្នាំ២០០៩ ឬ២០០៨។

**ស៖** សូមអរគុណ។ តើលោកអាចនៅចាំដែរឬទេថា នៅក្នុងខែណា ដែលលោកបានផ្តល់សម្ភាសនោះ? ហើយប្រសិនបើលោកមិនចាំទេ លោកអាចឆ្លើយថាមិនចាំ។

**ឆ៖** បាទ ខ្ញុំមិនចាំទេ មិនដឹងខែណា ភ្លេចអស់ហើយ។

[១៣:៤០:០៤]

**ស៖** នៅពេលដែលអ្នកស៊ើបអង្កេត មកពីការិយាល័យសហចៅក្រមស៊ើបអង្កេត ទៅជួបលោកនៅៗឯភូមិរបស់លោកនោះ តើពួកគេបានពន្យល់លោកអំពីមូលហេតុ ដែលគេចង់សួរលោក សម្ភាសលោកដែរឬទេ?

**ឆ៖** គេសួរខ្ញុំតាមដែលខ្ញុំឆ្លើយទាំងអស់ ទាំងប៉ុន្មាននៅក្នុងកំណត់ត្រាហ្នឹងបាទ។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែសំណួរគឺ ខុសពីហ្នឹងបន្តិច។ នៅពេលដែលអ្នកស៊ើបអង្កេតបានទៅភូមិរបស់លោក តើគាត់បានពន្យល់លោកពីមូលហេតុ ដែលពួកគេមកនិយាយជាមួយលោកដែរឬទេ?

**ឆ៖** ខ្ញុំភ្លេចទៅហើយ មិនដឹងគាត់និយាយអីខ្លះ ខ្ញុំអត់បានចាំ។

**ស៖** តើលោកដឹងដែរឬទេ ថាតើអ្នកស៊ើបអង្កេតហ្នឹង ដឹងថា លោកបានធ្វើការឲ្យសម័យកម្ពុជាប្រជាធិបតេយ្យនៅខាងរថភ្លើងនោះ គេដឹងដោយរបៀបណា?

**ឆ៖** ខ្ញុំឃើញក្រុមគាត់ចូលមក ហើយក៏គាត់រកសួរខ្ញុំ ចូលផ្ទះខ្ញុំសួរខ្ញុំពីរឿង ខ្ញុំដែលនៅខាងរទេះភ្លើងហ្នឹងពីជំនាន់ណាខ្លះអីជំនាន់ណា គឺគាត់ចូលមកតែម្តង អត់មានតាមរយៈខាងណាអីខាងណាទេ។ គាត់ចូលមកផ្ទះខ្ញុំបណ្តោយ ព្រោះផ្ទះខ្ញុំនៅជាប់នឹងផ្លូវរទេះភ្លើង ជិតផ្លូវរទេះភ្លើងបាត់ដំបងហ្នឹង។

**ស៖** តើពួកគេបានពន្យល់លោកដែរឬទេ ពីមូលហេតុថា ហេតុអីបានជាគេមកជួបលោក មកផ្ទះមកលោក ហេតុអីក៏មិនទៅផ្ទះអ្នកផ្សេង? តើពួកគេបានដឹងដោយរបៀបណា ថាត្រូវទៅនិយាយជាមួយលោកអំពីការងាររទេះភ្លើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** បាទ នៅក្នុងភូមិខ្ញុំ ឬក៏ខាងភូមិខ្ញុំសុទ្ធតែអ្នកធ្វើការចាស់ ខាងរទេះភ្លើងទាំងអស់បាទ។ គាត់ចូលមកចំផ្ទះខ្ញុំមុនគេ *(ឮមិនច្បាស់)* ខ្ញុំ។ គាត់សួរខ្ញុំទៅ ហើយគាត់ក៏បានប្រាប់ថា គាត់ខាងសាលាក្តីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការនៅកម្ពុជាបាទ។

[១៣:៤៣:០២]

**ស៖** លោកបាននិយាយថា គឺមានអ្នកធ្វើការខាងរទេះភ្លើងហ្នឹងនៅក្នុងភូមិរបស់លោក។ តើអ្នកផ្សេងទៀតជាអ្នកធ្វើការនៅរទេះភ្លើងហ្នឹង បានជូនអ្នកស៊ើបអង្កេតហ្នឹងមកជួបលោក ដើម្បីសម្ភាសលោកដែរឬទេ?

**ឆ៖** បាទ នៅក្នុងនោះ អត់មានអ្នកណាជូនមកទេ គេចូលមកផ្ទះខ្ញុំ ក៏សម្ភាសខ្ញុំ។ ដល់សម្ភាសខ្ញុំរួចហើយ បានសម្ភាសពីរនាក់ទៀត។ ពីរនាក់ទៀត សព្វថ្ងៃម្នាក់នុ៎ង ខាងប្អូនទៅជួបហ្នឹង ថាស្លាប់បាត់ទៅហើយ ហើយម្នាក់ទៀតអត់បានមក។ នៅក្នុងនោះ ថ្ងៃនោះសម្ភាសបីនាក់។ សុទ្ធតែអ្នករទេះភ្លើងចាស់ៗ។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានដែរឬទេថា តើហេតុអ្វីបានជាលោកអាចដឹងថា អ្នកស៊ើបអង្កេតនោះ គឺគេសម្ភាសមនុស្សពីរនាក់ ឬក៏បីនាក់ផ្សេងទៀត ក្រៅពីរូបលោកនោះ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ព្រោះសម្ភាសតែខ្ញុំរួច ខ្ញុំមានការងារធ្វើ ខ្ញុំទៅបាត់ទៅមិនដឹង មិនដឹងគេសម្ភាសពីរនាក់ទៀត មិនដឹងសម្ភាសរឿងអី ខ្ញុំអត់បានដឹង។

[១៣:៤៤:៥៣]

**ស៖** លោកបានឆ្លើយព្រឹកមិញផងដែរថា អំពី អ៊ំព្រឿង ហើយនិង លោកបាននិយាយថា គាត់ជាអ្នកទទួលខុសត្រូវ ខាងបច្ចេកទេសការងាររទេះភ្លើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ ថាតើលោកធ្វើការជាមួយគាត់ទេ ជាមួយអ៊ំព្រឿង ហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្វើការជាមួយគាត់។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានដែរឬទេ ថាធ្វើការជាមួយគាត់រយៈពេលយូរប៉ុនណា ឬក៏ពេញមួយរយៈពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យ ឬក៏ក្នុងរយៈពេលខ្លីទេ?

**ឆ៖** បាទ ខ្ញុំធ្វើការជាមួយនឹងគាត់ហ្នឹង ទាល់តែពេញៗអាសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹងបាទ។

[១៣:៤៦:០០]

**ស៖** ហើយលោកបាននិយាយបន្តិច អំពីតួនាទីរបស់គាត់ថ្ងៃនេះ។ តើខ្ញុំ -- តើលោកអាចប្រាប់ខ្ញុំបន្ថែមទៀតដែរឬទេ អំពីថាតើគាត់ធ្វើអ្វីខ្លះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** គាត់មានតួនាទីជាប្រធានបច្ចេកទេសៗហ្នឹងខាងៗផ្លូវ ស្ពាន និងអគារ។ បាទ ក្រៅពីនោះគាត់មិនបានធ្វើអីទេ គាត់ធ្វើពលកម្ម ដូចជាពួកយើងខ្ញុំទាំងអស់ដែរ នៅក្រោមក្រុមរបស់គាត់ហ្នឹង។ តែគាត់គ្រាន់តែត្រួតផ្នែកបច្ចេកទេស បច្ចេកទេសខាងផ្លូវ ស្ពាន អគារ។

**ស៖** សូមអរគុណដែលលោកបានឆ្លើយ ផ្តល់នូវចម្លើយនេះ។ បច្ចុប្បន្ននេះ តើលោកនៅមានទំនាក់ទំនង ជាមួយអ៊ំព្រឿង ដែរឬទេ? នៅធ្លាប់ជួបគ្នាជាធម្មតាដែរឬទេ?

**ឆ៖** សព្វថ្ងៃជួបគ្នាធម្មតា ផ្ទះនៅជិតគ្នា ហើយ *រីធ្រែត* ពីខាង -- *រីធ្រែត* ដូចគ្នាព្រោះថានិវត្តន៍ជនដូចគ្នាបាទ។

**ស៖** តើលោកដឹងដែរឬទេថា អ៊ំព្រឿងហ្នឹងក៏ត្រូវបានផ្តល់ចម្លើយទៅអ្នកស៊ើបអង្កេត របស់សាលាក្តីនេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹង ព្រោះអត់បានសួរគាត់ អត់បានមើលរបាយការណ៍គាត់ អត់បានដឹង។

**ស៖** នៅពេលដែលលោកបានផ្តល់សម្ភាសជាមួយអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ តើអ៊ំព្រឿងនោះនៅក្បែរលោកដែរឬទេ? បានន័យថាដែលគាត់នៅផ្ទះជិតលោកដែរហ្នឹង គាត់បានវត្តមាននៅក្នុងពេលសម្ភាសហ្នឹងដែរឬទេ?

[១៣:៤៨:៣៥]

**ឆ៖** បាទ គាត់នៅដែរ តែនៅខាងក្រៅអត់មានចូលក្នុងកន្លែងសម្ភាសហ្នឹងទេ គាត់នៅខាងក្រៅផ្ទះបាទ។

**ស៖** តើលោកដឹងដោយវិធីណា ដែលថាគាត់នៅខាងក្រៅ? តើលោកបានឃើញគាត់នៅខាងក្រៅ ឬក៏គាត់ប្រាប់ៗលោកថា ពេលដែលលោកសម្ភាសនោះគាត់នៅខាងក្រៅ តើលោកដឹងដោយរបៀបណា?

**ឆ៖** បាទ ព្រោះៗខ្ញុំសម្ភាសនៅក្នុងបន្ទប់ មានបង្អួច និងមាត់ទ្វារៗបិទអត់ជិតទេ។ បានឃើញគាត់នៅដើរខាងក្រៅត្រេងត្រាងៗ។

**ស៖** តើលោកដឹងទេ ហេតុអីបានជាគាត់នៅខាងក្រៅត្រេងត្រាងហ្នឹង នៅពេលដែលលោកផ្តល់សម្ភាសហ្នឹង?

**ឆ៖** មិនដឹងថាគាត់នៅលេងជាមួយនឹងក្មេងក្មាងខាង ឬមិនដឹង ឬគាត់មានការណ៍អីនៅហ្នឹងបាទ។ មនុស្សអ្នកស្រុកភូមិផងរបងជាមួយគ្នាបាទ។

[១៣:៤៩:៥៨]

**ស៖** អនុលោមទៅតាមកំណត់ហេតុស្តាប់ចម្លើយរបស់អ៊ំ ព្រឿង នោះ លោកអ៊ំ ព្រឿង ហ្នឹងបាននិយាយថា និយាយប្រាប់អ្នកស៊ើបអង្កេតមួយចំនួនដែលមិនបានថតសំឡេងទេ។ នោះមានន័យថាអ្នកស៊ើបអង្កេតរបស់សាលាក្តី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហ្នឹងបាននិយាយជាមួយអ៊ំ ព្រឿង ប៉ុន្តែមិនបានអាត់សំឡេងនៃការសន្ទនានោះទេ។ ឯកសារយោងនោះ លោកប្រធានោះគឺថាឯកសារ D232/74, អង់គ្លេស ERN 00422355, ហើយនិងខ្មែរ ERN 00414480។ គឺនៅក្នុងសំណួរលេខ៦០ ដែលអ្នកស៊ើបអង្កេតខ្លួនឯងបាននិយាយថា "បរិបទនោះគឺដែលបានសន្ទនាមិនបានអាត់សំឡេង"។ លោកសាក្សី សុខ ឈិន ការសម្ភាសដែលលោកបានផ្តល់ហ្នឹង គឺធ្វើឡើងនៅថ្ងៃជាមួយគ្នាហើយអ្នកស៊ើបអង្កេតហ្នឹងក៏ជាក្រុមដដែលដែរ ហើយក៏ធ្វើឡើងនៅក្នុងភូមិដដែល ភូមិតែមួយ។ តើអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង បាននិយាយជាមួយលោកផងដែរ ដោយថានិយាយដោយមិនមានថតសំឡេងពីបទសម្ភាសនេះ រហូតដល់ពេលមួយទើបបានសម្ភាសមានថត តើអ៊ីចឹងដែរឬទេ?

[១៣:៥១:៤២]

**ឆ៖** បាទ អ៊ីចឹងៗ ហើយ ប៉ុន្តែខ្ញុំមិនដឹងវាមាននិយាយគ្នាមែន តែខ្ញុំភ្លេច វាមិនដឹងជានិយាយពី

រឿងអី។ បាទចប់។

**ស៖** តើអ្នកស៊ើបអង្កេតបានពន្យល់លោកដែរឬទេថា ពួកគាត់ទើបតែបាននិយាយជាមួយអ៊ំ ព្រឿង នៅពេលដែលពួកគមកសួរសំណួរមួយចំនួនដល់លោកនោះ?

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់ឲ្យលោកមេធាវីពន្យល់ពីមូលហេតុនៃការអះអាងយ៉ាងដូច្នេះ? បាទ គាត់ទើបតែលើកឡើងថាអ្នកស៊ើបអង្កេតបាននិយាយជាមួយសាក្សីម្នាក់ទៀត ខ្ញុំអត់ចាំឈ្មោះទេ មុននឹងពេលដែលសម្ភាសសាក្សីនេះ។ នេះបើសិនជាខ្ញុំយល់មិនច្រឡំទេ។ ថាតើលោកមានមូលដ្ឋានអី នៃការអះអាងយ៉ាងដូច្នេះដែរឬទេ?

ហើយភាពពាក់ព័ន្ធហ្នឹងយ៉ាងម៉េចដែរ ទាក់ទងការលើកឡើងរបស់លោកនេះ?

[១៣:៥៣:១០]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកចៅក្រម ឡាវែន៍ ដែលលោកបានបញ្ជាក់នេះ។ គឺផ្អែកទៅលើកំណត់ហេតុស្តាប់ចម្លើយនេះ គឺសាក្សីអ៊ំ ព្រឿង បានផ្តល់សម្ភាសនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ គឺថាចប់នៅម៉ោងពីរសាមសិបនាទី បាទ សម្ភាសនោះនៅម៉ោងប្រាំបួនដប់ប្រាំ។ គឺថានៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ ពីម៉ោងបាទម៉ោងប្រាំបួនដប់ប្រាំនាទី ដល់ម៉ោងពីរសាមសិបនាទីនេះគឺថា គឺខ្ញុំដឹងច្បាស់ថា បុគ្គលទាំងពីរនាក់នេះបានផ្តល់សម្ភាសនៅក្នុងថ្ងៃតែមួយ។ រីឯបទសម្ភាសន៍អ៊ំ ព្រឿង ហ្នឹងគឺសម្ភាសមុនសាក្សីរូបនេះ--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសូមឲ្យលោកបំភ្លឺបន្តិច ការណ៍ដែលសាក្សីទាំងពីរនេះត្រូវបានសម្ភាសថ្ងៃទី០១ ហើយនិងការស្តាប់ថាបន្តបន្ទាប់គ្នានេះជារឿងមួយទៀត។ ក៏ប៉ុន្តែខ្ញុំចង់ដឹងពីការពាក់ព័ន្ធនេះ មិនដឹងថាលោកនិយាយមកនេះថាមានការពាក់ព័ន្ធយ៉ាងម៉េចនឹងសវនាការយើងនេះ?

**លោក ហ្សាស្តេ ប៉ោ៖**

ដើម្បីឲ្យខ្ញុំជ្រាបច្បាស់ចៅក្រម ឡាវែន៍ ថាតើៗលោកយោងថាការអះអាងរបស់ខ្ញុំហ្នឹង ត្រង់ចំណុចណាដែលខ្ញុំចង់ឲ្យលោកបំភ្លឺខ្ញុំ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំពុំមានប្រតិចារឹកនៅនឹងមុខនោះទេ ប្រហែលជាមានបញ្ហាបកប្រែ ក៏ប៉ុន្តែខ្ញុំហាក់ដូចជាយល់ឃើញថា លោកបាននិយាយប្រាប់សាក្សីនេះថា អ្នកសួរនុំងគឺថាអ្នកសួរប្រាប់អំពីអ្វីដែលខ្លួនបានសួរទៅសាក្សីមុននោះទៅកាន់គាត់។ ខ្ញុំមិនដឹងថា លោកបាននិយាយយ៉ាងដូច្នេះ ឬក៏ខ្ញុំយល់មិនត្រូវទេ។ តើលោកអាចបំភ្លឺទេ ចំណុចហ្នឹង លោកនិយាយថា--

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំយល់ថា ខ្ញុំយល់ច្បាស់។ ខ្ញុំមិនបាននិយាយថាអ្នកស៊ើបអង្កេតប្រាប់ទៅសាក្សីរូបនេះថា គាត់បានសម្ភាសសាក្សីពីមុននោះរួចមកទេ។ ហើយខ្ញុំ ខ្ញុំសួរសាក្សីនេះថា តើគាត់ដឹងដែរឬទេ អំពីហេតុការណ៍នៃការសម្ភាសម្នាក់ទៀត ហើយនិងរូបគាត់នេះ? ដែលខ្ញុំចង់ពិនិត្យមើលពីប្រភពនៃការដឹងរបស់សាក្សីនោះ ហើយខ្ញុំមិនៗបានមានចេតនា ឬក៏មិនបានលើកឡើងអំពីការអះអាងថាអ្នកស៊ើបអង្កេតប្រាប់សាក្សីបែបនោះទេ។

[១៣:៥៦:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៦:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី បន្តការតាំងសំណួរចំពោះសាក្សី!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** ខ្ញុំមិនទាន់ប្រាកដទេថា តើសាក្សីនៅចាំសំណួររបស់ខ្ញុំដែលខ្ញុំសួរទៅគាត់ដែរឬទេ? បើអត់ចាំ ខ្ញុំនឹងសួរឡើងវិញបាទ។

**លោក សុខ ឈិន៖**

**ឆ៖** បាទ ខ្ញុំអត់ចាំ។

**ស៖** នៅពេលដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត បានមកដើម្បីសម្ភាសលោកនោះ តើគាត់បានពន្យល់លោកថា គាត់បាននិយាយទៅរក អ៊ំព្រឿង ពីមុនដែលគាត់មក

សម្ភាសលោកទេ នៅថ្ងៃនោះ?

[១៣:៥៨:០៣]

**ឆ៖** បាទ ខ្ញុំអត់បានចាំទេ ក្នុងចំណុចហ្នឹងអត់បានចាំ។

**ស៖** ដើម្បីចៀសវាងការភ័ន្តច្រឡំ តើអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនិយាយថា គាត់បាននិយាយជាមួយ អ៊ំព្រឿង ដោយមិនមានខ្សែអាត់ ដោយអត់មានបានថតសំឡេងផ្នែកនោះនៃការសម្ភាស។ តើអ្នកស៊ើបអង្កេតបានជជែកជាមួយលោកដោយមិនមានថតសំឡេងដែរឬទេ ក្នុងផ្នែកណាមួយនៃការសម្ភាសរបស់លោកនោះ?

**ឆ៖** បាទ ខ្ញុំមិនបានចាំដែលគាត់និយាយជាមួយរកមកខ្ញុំថាម៉េចទេ ខ្ញុំអត់ដឹងទេ តែដល់ពេលសម្ភាសន៍ គាត់ហៅចូលខ្ញុំទៅសម្ភាសន៍បណ្ដោយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ សូមអញ្ជើញ មានអីទៀតទេ? តំណាងសហព្រះរាជអាជ្ញាមានអីទៀត?

[១៣:៥៩:២២]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម ខ្ញុំនៅជំទាស់ គឺថាសាក្សីបានឆ្លើយ គឺថាមិនមានមូលដ្ឋានអ្វីដើម្បីដែលថាសួរគាត់អំពីទិចនិក ឬក៏វិធីសាស្ត្រនៃសម្ភាសនោះទេ ពីព្រោះអាហ្នឹងជាកិច្ចការរបស់អ្នកផ្សេង។ រីឯមេធាវីការពារក្ដី គឺថាអាចនឹងសួរសំណួរដែលពាក់ព័ន្ធ គឺសំណួរបច្ចេកទេស។ រីឯអ្វីៗដែលបានសម្ភាសបានកត់ត្រាយ៉ាងណាៗនោះគឺថាមិនអាចសួរឲ្យសាក្សីបញ្ជាក់បាននោះទេ។

**លោក ហ្សាស្តេី ប៉ោ៖**

តាមកាលៈទេសៈធម្មតាខ្ញុំអាចនឹងយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញា ប៉ុន្តែក្នុងករណីនេះខ្ញុំនិយាយអំពីៗការសម្ភាសចំនួនពីរដែលធ្វើការ -- ដែលធ្វើកើតឡើងក្នុងថ្ងៃដដែល ហើយអ្នកស៊ើបអង្កេតដដែល ហើយសាក្សីទាំងពីរហ្នឹង គឺនៅជិតគ្នា ហើយធ្វើការជាមួយគ្នាទៀតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ដោយជាក់ស្ដែងនោះ គឺថាសាក្សីមួយផ្សេងទៀតនោះត្រូវបានសម្ភាសផ្នែកខ្លះដោយមិនមានថតខ្សែអាត់ ប៉ុន្តែខ្ញុំមិនមែនអះអាងតាមមតិខ្ញុំទេ គឺអ្នកស៊ើបអង្កេតខ្លួនឯងអះអាងនៅក្នុងកំណត់ហេតុថា មានផ្នែកខ្លះមិនបានថតសំឡេងទេ ហើយអាចនឹងជាវិធីដែលអ្នកស៊ើបអង្កេតហ្នឹងបានសួរសាក្សីជាមុន ដើម្បីឈានទៅដល់សម្ភាសដោយមិនបានថតសំឡេង។ ដូច្នេះហើយនេះជាមតិរបស់អ្នក

ស៊ើបអង្កេតទេ ដែលគាត់បញ្ជាក់ថា មានផ្នែកនៃការសម្ភាសមួយទៀតនោះ គឺថាមិនបានៗថតសំឡេងទេ។

អ៊ីចឹង គឺខ្ញុំឃើញថាអាចនឹងមានការផ្តល់ព័ត៌មាន ឬក៏និយាយចាប់ផ្តើមជាមុន មុននឹងថតខ្សែអាត់រួចបានមានការសម្ភាស។ នេះជាបញ្ហាដែលខ្ញុំលើកឡើងនោះ។

[១៤:០១:១៩]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ឥឡូវនេះមានសាក្សីនៅចំពោះមុខលោកហើយ ហើយគាត់ -- លោកបានបញ្ជាក់ហើយថា អំមិញថា អ្វីដែលគាត់អាចចងចាំបានពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលបានចោទប្រកាន់នេះ គឺគួរតែប្រព្រឹត្តទៅឲ្យបានជាក់លាក់ទៅនូវអ្វីដែលគាត់បានដឹង នៅក្នុងកិច្ចដំណើរការរបស់យើង ដែលយើងបានកំណត់ អញ្ជើញគាត់មកធ្វើសវនាការ ទី១។ ហើយទី២ អង្គជំនុំជម្រះសូមរំឭកលោកថា នៅក្នុងវិធាន៧៦ ត្រង់ចំណុច ៧ ហ្នឹងគឺ បានចែងច្បាស់លាស់ គួរតែយកចំណុចនេះមកពិចារណាផងដែរ។ ដោយចំណុច៧៦ -- វិធាន៧៦ ត្រង់អនុវិធានទី៧ ហ្នឹងចែងថា “លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ”។

[១៤:០២:២៦]

យើងក៏មិនដឹងថា គោលបំណងការគិតរបស់លោកហ្នឹងយ៉ាងម៉េចទេ ប៉ុន្តែបើយើងមិនយល់ មិនច្រឡំទេ គឺការដែលលោកដេញដោលនេះ គឺចំណាយពេលវេលាទៅហើយវាចំនួវត្រង់ចំណុចនៃវិធាន៧៦ អនុវិធានទី៧ នេះ គឺបានចែងរួចហើយលើបញ្ហានេះ។

សូមលោកបន្តសំណួរទៅមុខទៀតចុះ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំស្តាប់ឮលោកប្រធានលើកឡើងថា ចេតនារបស់ខ្ញុំសួរនេះមិនច្បាស់លាស់។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ដោយខ្លីអំពីហេតុផលនៃគោលបំណងនៃការតាំងសំណួររបស់ខ្ញុំ។ ខ្ញុំមិនមែនលើកអំពីវិការៈផ្នែកនីតិវិធីនោះទេ។ ខ្ញុំមិនៗពិចារណា និងមិនខ្វល់ទៅលើចំណុចនេះទេ។ គ្រាន់តែខ្ញុំចង់សួរទៅលើសាក្សីនេះថា តើសក្ខីកម្មរបស់សាក្សីនេះ គឺបានទទួលរងប៉ះពាល់ដោយអ្នក

ស៊ើបអង្កេត ឬក៏សាក្សីមួយទៀតដែរឬទេ? គឺខ្ញុំធ្វើការងារដែលមេធាវីនានានៅក្នុងពិភពលោកនេះ គឺគាត់បំពេញកិច្ចទៅតាមហ្នឹងដូច្នោះ។ ខ្ញុំសួរតែអ្វីដែលសាក្សីនេះដឹងតែប៉ុណ្ណោះ។ ខ្ញុំសូមបន្តចូលទៅមុខទៀត។

[១៤:០៣:៥២]

**សួរដោយលោក ហ្សាស្គី ប៉ោ៖**

**ស៖** លោក សុខ ឈិន កាលពីព្រឹកមិញលោកបានលើកឡើងឆ្លើយទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីថា ថ្មីនេះលោកបាន -- ទើបតែដឹងអំពីតួនាទីរបស់ នួន ជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ។ ដូច្នេះតើលោកអាចជម្រាបប្រាប់យើងខ្ញុំបានដែរឬទេ តើលោកដឹងអំពីតួនាទីរបស់គាត់ហ្នឹងនាពេលថ្មីៗដោយរបៀបណា? លោកបានមើលអត្ថបទសារព័ត៌មាន លោកនិយាយជាមួយគេទើបលោកដឹង ឬក៏យ៉ាងម៉េច? តើលោកដឹងដោយរបៀបណាអំពីតួនាទីរបស់លោក នួន ជា?

[១៤:០៤:៣០]

**លោក សុខ ឈិន៖**

**ឆ៖** ខ្ញុំទើបតែដឹងពេលដែលខ្ញុំបើកទូរទស្សន៍មើលម្តងៗ បាទដឹងមុខនាទីរបស់គាត់ជាប្រធានរដ្ឋសភា។ អង្កាល់ពីដើមខ្ញុំអត់បានដឹងទេ។

**ស៖** នៅពេលដែលលោកនិយាយថា មើលទូរទស្សន៍នោះ តើលោក -- តើមើលទូរទស្សន៍ហ្នឹងតើកម្មវិធីអ្វីដែរ ដែលលោកបានដឹង? ហើយទូរទស្សន៍ណាមួយ?

**ឆ៖** បាទ ក្នុងកម្មវិធីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមើលតាមទូរទស្សន៍ ស៊ី.ធី.អិន។

**ស៖** នៅពេលដែលលោកតាមដានកម្មវិធីនុ៎ង តើលោកបានយកបញ្ហាហ្នឹងទៅជជែកជាមួយនឹងគ្រួសាររបស់លោក ឬក៏ទៅជជែកមួយជាមួយនឹងមិត្តភក្តិរបស់លោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានយកទៅជជែកទេ ខ្ញុំដឹងតែម្នាក់ឯង។

[១៤:០៦:០៨]

**ស៖** ចាប់តាំងពីឆ្នាំ១៩៧៩ រហូតមក តើលោកដែលយកបញ្ហាតួនាទីរបស់ នួន ជា ហ្នឹងទៅពិភាក្សាជាមួយនឹងសមាជិកគ្រួសាររបស់លោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ឬក៏លោកធ្លាប់ជជែកជាមួយគ្រួសារលោកអំពីហេតុការណ៍នៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ខ្ញុំៗដូចមិនដែលបានចាប់អារម្មណ៍ខ្វល់ខ្វាយពីរឿងហ្នឹងផង គ្រាន់តែឮសួរហើយ ក៏ខ្ញុំទុកចោលទៅ ខ្ញុំមិនបានគិតគូរពីរឿងពិភាក្សាជាមួយអ្នកនេះ អ្នកនោះ មិត្តភក្តិ គ្រួសារអីផង។

**ស៖** ហើយប្រសិនបើយើងមើល ពិនិត្យមើលលើការងាររបស់លោក ដែលលោកបានធ្វើនៅស្ថានីយរថភ្លើងនាពេលនោះ។ ជាពិសេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យវិញម្តង។ លោកបានលើកឡើងថា លោកទទួលភារៈ ទទួលខុសត្រូវ លើផ្លូវ២១គីឡូម៉ែត្រ។ បានន័យថា លោកត្រូវតែរៀងរាល់ថ្ងៃនោះ ត្រូវតែទៅពិនិត្យមើលផ្លូវ២១គីឡូម៉ែត្រហ្នឹងជារៀងរាល់ថ្ងៃ ហើយពិនិត្យមើលការងាររបស់លោកហ្នឹងជារៀងរាល់ថ្ងៃ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ត្រឹមត្រូវ ជារៀងរាល់ថ្ងៃ។

[១៤:០៧:៤៥]

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលខ្ញុំអាចនិយាយថា លោករស់នៅក្នុងត្រពាំងជង សង្កាត់ត្រពាំងជង តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ សង្កាត់ត្រពាំងជង ក្នុងខេត្តបាត់ -- ពោធិ៍សាត់ បាទសូមទោស ក្នុងខេត្តពោធិ៍សាត់។

**ស៖** តើលោកអាចពន្យល់ប្រាប់យើងខ្ញុំបានដែរឬទេថា ពីត្រពាំងជង បើគិតពីផ្លូវ២១គីឡូម៉ែត្រនោះ មកត្រពាំងជងនោះតើមានចម្ងាយប៉ុន្មានដែរ ដែលលោកត្រូវធ្វើដំណើរទៅធ្វើការពិនិត្យការជួសជុលផ្លូវនោះ?

**ឆ៖** ២៦គីឡូម៉ែត្រហ្នឹង វាក្នុងខេត្តពោធិ៍សាត់។ ពោធិ៍សាត់គិតតាំងពីៗ អាផ្លូវចូលអ្នកតាឃ្លាំងមឿង ៗ ហើយ រហូតទៅដល់ គេហៅ វ៉ាជិតបឹងខ្នារណោះ។

[១៤:០៩:០១]

**ស៖** តើលោកទៅធ្វើការនោះ ដោយមធ្យោបាយអ្វីដែរនៅពេលព្រឹក? តើរថភ្លើងនោះ នៅស្ថានីយរថភ្លើងនៅជិតសង្កាត់របស់លោកដែលលោករស់នៅ ឬក៏លោកត្រូវជិះឡានធ្វើដំណើរទៅធ្វើការ?

**ឆ៖** បាទ បើនិយាយពីរឿងបច្ចេកទេសវិញ នៅខាងសង្កាត់របស់ខ្ញុំ អ៊េ ពាក្យបារាំងគេហៅ "មីលឡូរី" ឡូរី ៗអាស្សាដែលគេដោលតាមផ្លូវហ្នឹង ជិះតាមអាឡូរីដែលមានកង់ដែក។ ជិះតាមផ្លូវហ្នឹងយើងនាំគ្នាដោលអ៊ីចឹងទៅបាទ ជិះលើហ្នឹង មើលផ្លូវទេបាទ។ គេហៅ ឡូរីអាស្សា។ ឡូរីសម្រាប់យើងជិះ។ ឡូរីហ្នឹងមានកង់បួន ហើយយើងដាក់ក្តារលើហ្នឹងទៅ ដោលទៅ ដោលលើផ្លូវហ្នឹងទៅ បាទ

ហ្នឹងគឺថា ជិះតាមមធ្យោបាយហ្នឹង ទៅមើលផ្លូវបាទ។

**ស៖** តើលោកត្រូវតែទៅធ្វើការហ្នឹង ជារៀងរាល់ថ្ងៃ ឬក៏មានថ្ងៃណាមួយដែរ ដែលលោកអាចសម្រាកនៅសង្កាត់ត្រពាំងជងរបស់លោក?

[១៤:១០:៤១]

**ឆ៖** គ្មានពេលសម្រាកទេ លើកលែងតែយើងឈឺ។ យើងឈឺហើយសុំច្បាប់គេ គេថា ឈឺសតិអារម្មណ៍ទៀតបាទ នៅពេលនោះ មិនប៊ានឈប់ទេ ជួនកាលទៅទាំងឈឺ ទាំងជាបាទ។

**ស៖** តើលោកទៅលាជ នោះញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំអត់បានទៅលាជទេ គឺខ្ញុំបាទនៅតាមដងផ្លូវរទេះភ្លើងហ្នឹង វាមានអាផ្លូវឆ្លងកាត់ ផ្លូវខេត្តហ្នឹងទៅលាជ។ បាទ លាជខ្ញុំអត់ដែលបានស្គាល់បានអីទេ គ្រាន់តែផ្លូវវាឆ្លងកាត់ទៅលាជ ប្រជាជនដាក់ត្រង់ហ្នឹង ដើម្បីដឹកទៅលាជ។ បាទ ខ្ញុំអត់ដែលបានទៅដល់លាជទេបាទ។

**ស៖** ដើម្បីឲ្យខ្ញុំយល់ចម្លើយលោកឲ្យបានច្បាស់លាស់ គឺខ្ញុំនឹងសួរសំណួរមួយផ្សេងវិញ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកទៅលាជញឹកញាប់ប៉ុនណាដែរ? បាទ ខ្ញុំសូមសួរសំណួរបែបនេះឡើងវិញ។ តើលោកទៅលាជនោះ ញឹកញាប់ប៉ុនណាដែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ខ្ញុំអត់ដែលបានទៅទេលាជ។

**ស៖** ព្រឹកមិញ លោកក៏ត្រូវបានភាគីសួរផង គេក៏សួរលោកផងដែរ កាលពីព្រឹកមិញ ខ្ញុំអត់មានប្រតិចារឹកទេ “តើតាមួម ឬក៏តាមាយ នេះបានផ្ដល់ការណែនាំព័ត៌មាន អំពីរថភ្លើងដឹកមនុស្សមកដែរឬទេ?” ហើយលោកឆ្លើយថា “គាត់ទាំងពីរនាក់ គាត់មិនបានដឹងទេ មិនបានឲ្យការណែនាំមកខ្ញុំនោះទេ។ ខ្ញុំឃើញហេតុការណ៍នេះ គឺឃើញគេដឹកមនុស្សនុំង តាមផ្លូវរថភ្លើងនោះតែម្ដង”។ តើលោកអាចពន្យល់ជូនយើងខ្ញុំដែរឬទេ ថាតើនៅពេលដែលលោកនិយាយថា “ឃើញគេដឹកមនុស្សតាមផ្លូវរថភ្លើងហ្នឹង” តើលោកចង់បានន័យយ៉ាងម៉េចដែរ?

[១៤:១៣:៤២]

**ឆ៖** ខ្ញុំមាននាទី ជាជួសជុលផ្លូវដែក ហើយចំពោះប្រជាជន ដែលដឹកមកមិនដឹងអ្នកណាបញ្ជាឲ្យដឹកមកទេ ខ្ញុំមិនបានដឹងទេ ខ្ញុំគ្រាន់បានតែឃើញរទេះភ្លើងដែលបរកាត់ ឆ្លងកាត់ បរលើផ្លូវដែក។ បាទ ខ្ញុំមិនបានដឹងអ្នកណាបញ្ជាដឹកទៅ ឃើញតែរទេះភ្លើងដឹកប្រជាជនមកដាក់នឹងផ្លូវរទេះភ្លើងៗ មានផ្លូវជាតិឆ្លងកាត់ -- អ៊ា! ផ្លូវខេត្តឆ្លងកាត់ទៅលាជបាទ។

**ស៖** នៅពេលនេះ លោកទើបតែលើកឡើងអំពីរថភ្លើង ដែលមានដឹកមនុស្ស ដឹកៗថា ដឹកទំនិញនោះ សម្ភារៈនោះ តើដឹកសម្ភារៈអ្វីដែរលោក?

**ឆ៖** ខ្ញុំដែលនិយាយអំពីទំនិញនេះ ព្រោះរទេះភ្លើងវាមានទូៗសម្រាប់ដឹកទំនិញ និងទូសម្រាប់ដឹកមនុស្ស។ តែទូដឹកទំនិញហ្នឹង មិនមែនគេដឹកទំនិញទេ គេយកមកដឹកមនុស្ស។ បាទ ដឹកមនុស្សវិញ បាទអត់មានបង់អង្គុយ អត់មានអីទេ ព្រោះទូទំនិញហ្នឹងឃ្លុបបិទជិត អត់មានបង្អួច អត់មានអីទេ។ បាទ ហើយទូទំនិញដែរគេផ្លាប់ដាក់ទំនិញហ្នឹង យកមកដឹកមនុស្ស ព្រោះទូទំនិញហ្នឹងវាអត់មាន។

**ស៖** ប្រហែលជាខ្ញុំមិនយល់ចម្លើយរបស់លោកអម្បាញ់មិញ។ ខ្ញុំគិត -- គ្រាន់តែគិតថាលោកបានឆ្លើយថារថភ្លើងនុំងដឹកទំនិញផងដែរ រួមជាមួយនឹងមនុស្ស។ តើចំណុចនេះ ខ្ញុំលើកឡើងដូច្នេះត្រឹមត្រូវដែរឬទេលោកពិតជាឆ្លើយថា មានដឹកមនុស្សផង ដឹកទំនិញផង?

**ឆ៖** ដែលខ្ញុំឆ្លើយនេះ ខ្ញុំឆ្លើយថាទំនិញនេះ ព្រោះទូហ្នឹងគេសម្រាប់ដឹកទំនិញ ហើយយកមកដឹកមនុស្ស វាខុសត្រង់ហ្នឹង។ បាទ ទំនិញអត់មានទេ តែទូហ្នឹងសម្រាប់ពីសង្គមសម្រាប់ដឹកនទំនិញ។ នៅក្នុងទូមួយចំណុះទំនិញហ្នឹង៤០តោន។ ដល់អត់ៗមានទូសម្រាប់ដឹកអ្នកដំណើរគេយក ក្នុងសម័យ ប៉ុលពត ហ្នឹងគេយកទូសម្រាប់ដឹកទំនិញហ្នឹង មកដឹកអ្នកដំណើរវិញ។

[១៤:១៦:៤៧]

**ស៖** លោកនិយាយថា ទូដែលគេយកមកដឹកមនុស្សនោះ គឺជាទូដឹកទំនិញ ដែលគេសម្រាប់ដឹកតែទំនិញតែប៉ុណ្ណោះ។ តើលោកអាចរៀបរាប់ជូនយើងខ្ញុំបានដែរឬទេ តើទូនុំង ទូគេសម្រាប់យកមកទុកដឹកមនុស្សនោះ មើលទៅវារាងយ៉ាងម៉េចដែរ? តើវាមានបង្អួចដែរឬទេទូហ្នឹង? អាចឲ្យមនុស្សមើលឃើញ មើលពីក្នុងមកដែរឬទេ? ឬក៏ទូហ្នឹងបិទជិតតែម្តង? ដែលទូហ្នឹងបិទជិតសម្រាប់ដឹកតែទំនិញហើយគេយកមកដឹកមនុស្ស តើវារូបរាងយ៉ាងម៉េចដែរទូហ្នឹង?

**ឆ៖** ទូហ្នឹងរាងបួនជ្រុងទ្រវែង ទទឹងប្រហែលជា២ម៉ែត្រ បណ្តោយ១៩ម៉ែត្រ។ ទូហ្នឹងអត់មានបង្អួចទេ ទូហ្នឹងមានតែមាត់ទ្វារបួន សម្រាប់គេលីទំនិញឡើង បង្អួចគ្មានទេបាទ។ មានតែមាត់ទ្វារបួន។

**ស៖** តើទូហ្នឹងមានបង្អួចដែរឬទេ?

**ឆ៖** ទូហ្នឹងណា៎ អត់មានបង្អួចទេ។

**ស៖** លោកបាននិយាយថា មានមាត់ទ្វារបួន តើមាត់ទ្វារហ្នឹងលោកបានន័យយ៉ាងម៉េចដែរ?

[១៤:១៨:៣៨]

**ឆ៖** មាត់ៗទ្វារហ្នឹង ដល់តែប្រជាជនមក គេឲ្យឡើងតាមមាត់ទ្វារហ្នឹង។ ទ្វារបួនហ្នឹងៗ បើដាក់ទំនិញដាក់ទំនិញហើយគេរុញបិទជិត គេចង់ឃុំបេបាទ។ តែបើដឹកមនុស្សវិញ គេឲ្យមនុស្សឡើងតាមអាមាត់ទ្វារហ្នឹង។

**ស៖** ក្រោយពីមនុស្សចូលទៅក្នុងទូ ឡើងចូលទៅក្នុងទូនោះ ថាតើទ្វារហ្នឹងបិទ -- បន្ទាប់មកគេបិទទ្វារ ឬគេបើកចំហទុកឲ្យវាចំហដដែល?

**ឆ៖** បាទ គេៗបើកចំហទាំងបួនហ្នឹង។ ហើយមនុស្សដែលជិះនៅមាត់ទ្វារ គេឲ្យខិតពីមាត់ទ្វារបាទ អត់ឲ្យនៅជិតមាត់ទ្វារទេ ហើយមាត់ទ្វារហ្នឹងត្រូវបើកឲ្យខ្យល់ចេញចូល។

**ស៖** ដូច្នេះនៅពេលដែលគេបើកទ្វារចំហអ៊ីចឹង មានខ្យល់គ្រប់គ្រាន់ចូលមកក្នុងទូហ្នឹងក្នុងពេលធ្វើដំណើរ។ តើលោកអាចវាយតម្លៃអ៊ីចឹង ថាគេធ្វើអ៊ីចឹង ដើម្បីហេតុនេះអ៊ីចឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៤:២០:១៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រមជាទីគោរព!

មេធាវីនេះគឺសួរសំណួរផ្អែកទៅលើភស្តុតាង អាចសួរតែសំណួរផ្អែកលើភស្តុតាងតែប៉ុណ្ណោះ មិនអាចសួរឲ្យសាក្សីស្មាននោះទេ។ អាចសួរថាតើទូនោះមានទឹកមនុស្ស៤០ ទៅ៥០នាក់ ឬក៏យ៉ាងម៉េច។ ហើយលើកលែងតែសាក្សីហ្នឹងជាអ្នកជំនាញ ទើបអាចឲ្យសាក្សីមានលទ្ធភាពក្នុងការវិភាគផ្តល់ជាការសន្និដ្ឋានបែបនេះបាន។

**លោក ហ្សាស្តើ ប៉ោះ**

លោកប្រធានជាទីគោរព!

ខ្ញុំមិនឃើញសហព្រះរាជអាជ្ញាជំទាស់ទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីសួរអំពីថា រថភ្លើងហ្នឹងនៅចំថ្ងៃ ឬក៏បញ្ច្រាសថ្ងៃ។ ហើយនៅពេលនេះគឺខ្ញុំគ្រាន់តែចង់សួរសាក្សី ថាតើនៅក្នុងទូនោះមានខ្យល់ចេញចូលគ្រប់គ្រាន់ដែរឬទេ តែប៉ុណ្ណោះ។

[១៤:២១:១១]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃតំណាងសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាសមស្រប។ សេចក្ដីជំទាស់មានប្រសិទ្ធភាព សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ!

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោកសាក្សី នៅពេលដែលលោកឃើញរថភ្លើងហ្នឹងបរកាត់មក តាមការវាយតម្លៃរបស់លោក តើមើលទៅហ្នឹងគឺមានខ្យល់ចេញចូលគ្រប់គ្រាន់នៅក្នុងទូរថភ្លើង ដែលមានមនុស្សជិះនោះដែរឬទេ?

**លោក សុខ ឈិន៖**

**ឆ៖** បាទ មានខ្យល់គ្រប់គ្រាន់។

[១៤:២២:១០]

**ស៖** លោកបានបញ្ជាក់ថា លោកនៅ -- រស់នៅសង្កាត់ត្រពាំងជង តើជារៀងរាល់យប់ក្រោយពីលោកទៅធ្វើការងារនោះ តើលោកស្នាក់នៅទីនោះជារៀងរាល់យប់ ឬក៏យ៉ាងម៉េច?

**ឆ៖** នៅសង្កាត់ត្រពាំងជងហ្នឹង គេធ្វើ១ផ្ទះឱ្យនៅ។ បាទនៅរហូត ទាំងយប់ទាំងថ្ងៃ ២៤ម៉ោងនៅរហូតបាទ។

**ស៖** សូមអរគុណ។ ក្រោយពីលោកបានពិនិត្យជួសជុលផ្លូវរថភ្លើងរួចហើយនោះ គឺថាគេដឹកលោកហ្នឹងមកសង្កាត់លោកវិញ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ មិនមែនអ៊ីចឹង ព្រោះគ្មាននរណាដឹកទេ គឺដោលឡូរីខ្លួនឯង។ បាទ ធ្វើពលកម្មខ្លួនឯងដោលអាហ្នឹងមកលើផ្លូវ មកយើងមកសម្រាកនៅសង្កាត់ត្រពាំងជង។

**ស៖** តើលោកអាចធ្វើការប៉ាន់ប្រមាណទេ ថាតើពីនុំង កន្លែងនុំងមកដល់សង្កាត់លោករស់នៅហ្នឹងមានចម្ងាយប៉ុន្មានដែរ? ហើយត្រូវចំណាយពេលរយៈពេលប៉ុន្មានដែរ?

[១៤:២៣:៥៧]

**ឆ៖** គឺមិនប្រាកដ។ កន្លែងក្នុង២១គីឡូហ្នឹង ជួនកាលមានកន្លែងខូចខ្លាំង យើង បាទយើងទៅធ្វើកន្លែងហ្នឹង។ កន្លែងណាខូចខ្លាំង ខូចដូចកន្លែងគីឡូម៉ែត្រលេខប៉ុន្មាន ដែលខូចខ្លាំង យើងទៅធ្វើហ្នឹង។ ជួនកាលដោលគីឡូទៅ២០ម៉ែត្រ អ៊ំ! ២០គីឡូ មកវិញ២០គីឡូបាទ។ មិនដឹងប្រើរយៈពេលប៉ុន្មានទេ អាហ្នឹងល្បឿនវាប្រហែលជា១០គីឡូម៉ែត្រក្នុង១ម៉ោងដែរ។ អាហ្នឹងដោយសារ -- ស៊ីសងកម្លាំងយើង

ដែលកម្លាំងយើងដោលវា បាទ។

**ស៖** ខ្ញុំដឹងថា លោកបានពន្យល់ចំណុចហ្នឹងរួចមកហើយ ខ្ញុំគ្រាន់តែចង់យល់តែប៉ុណ្ណោះថា តើសង្កាត់ដែលលោករស់នៅនោះ គឺនៅវានៅតាមផ្លូវរថភ្លើងហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ សង្កាត់ដែលខ្ញុំនៅហ្នឹង វានៅជាប់ គេធ្វើផ្ទះឲ្យនៅប្រហែលជាពីផ្លូវហ្នឹងទៅប្រហែលជា១០ម៉ែត្រប៉ុណ្ណោះបាទ។ មានកន្លែងនៅ មានការដ្ឋានបាយ មានការដ្ឋានកុមារអីចឹងទៅបាទ។ ប្រពន្ធកូននៅជុំគ្នាទាំងអស់។

**ស៖** សូមអរគុណលោក។ ចំណុចនេះធ្វើឲ្យខ្ញុំយល់ច្បាស់ជាងមុន។ នៅពេលនេះ ខ្ញុំចង់សួរលោកសំណួរមួយចំនួនអំពីតួនាទីរបស់ តាមូម។ លោកបានឆ្លើយព្រឹកមិញថា តាមូម នេះជាអ្នកគ្រប់គ្រង។ ហើយ តាមូម នេះអាចធ្វើការសម្រេចការងារទាំងឡាយដែលគាត់ចង់សម្រេច។ តើលោកដឹងថា តាមូម នេះអាចសម្រេចការងារអ្វីៗទាំងឡាយតាមតែគាត់នេះតាមរបៀបណាដែរ?

[១៤:២៦:៣៣]

**ឆ៖** ខ្ញុំមិនដឹងគាត់សម្រេចតាមរបៀបណាទេ ប៉ុន្តែខ្ញុំធ្វើការហ្នឹងគឺតាមតែគាត់ដាក់ទិសឲ្យបាទ។ ដាក់ត្រង់ណា គឺធ្វើត្រង់ហ្នឹង ប៉ុន្តែគំនិតគាត់មិនដឹងថាមានគំនិតបែបណា ខ្ញុំអត់បានដឹងគំនិតរបស់គាត់ទេបាទ។ តែទិសគេ គាត់ដាក់ឲ្យត្រង់ណា គឺថាខ្ញុំអនុវត្តកន្លែងហ្នឹង ឲ្យបានត្រឹមត្រូវល្អបាទ បើមិនអនុវត្តតាមទេ យើងនឹងមានទោស ថាយើងអត់បានគោរពទិសវិន័យរបស់អង្គការ។

ស៖ ដូច្នេះ វាត្រឹមត្រូវដែរទេ ដែលខ្ញុំអាចនិយាយថា គឺនៅពេលដែលលោកធ្វើការងារនោះ គឺលោកបានដឹងថា គាត់ហ្នឹងជាអ្នកធ្វើការសម្រេចទៅលើជីវិតការងារ និងជីវិតរស់នៅរបស់លោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើអីចឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកក៏បាននិយាយផងដែរថា តាមូម នេះធ្វើការរាយការណ៍ទៅស្ថានីយរថភ្លើងនៅក្នុងទីក្រុងភ្នំពេញ អង្គភាពរថភ្លើងនៅក្នុងទីក្រុងភ្នំពេញ។ តើលោកដឹងថា មូម នេះធ្វើរបាយការណ៍រាយ-ការណ៍ទៅអង្គភាពរថភ្លើងនៅក្នុងក្រុងភ្នំពេញនេះ គឺលោកដឹងដោយរបៀបណាដែរ? គឺអ្នកណាគេប្រាប់លោក នៅពេលដែលគាត់រាយការណ៍ទៅអង្គភាពរថភ្លើងនៅក្នុងទីក្រុងភ្នំពេញ?

[១៤:២៨:២១]

**ឆ៖** ខ្ញុំបានឃើញគាត់ធ្វើដំណើរទៅ ដោយគាត់មានរថភ្លើងពិសេសជិះទៅ ហើយត្រឡប់មក

វិញ គឺគាត់ប្រជុំ បាទ។ បានខ្ញុំដឹងថា តែគាត់ជិះអារថភ្លើងពិសេសទៅ ហើយត្រឡប់មកវិញប្រជុំ ខ្ញុំឃើញថាមុខតែគេ -- គាត់ប្រជុំហើយ មកដាក់ទិសឲ្យខ្ញុំធ្វើការបាទ។

**សៈ** លោកក៏បានឆ្លើយផងដែរថា រថភ្លើងដែលឆ្លងកាត់ហ្នឹង បើកឆ្លងកាត់ហ្នឹងគឺក្រោមការក្តោបក្តាប់របស់អង្គភាពរថភ្លើងនៅក្នុងទីក្រុងភ្នំពេញ។ តើធ្វើម៉េចលោកដឹងថា រថភ្លើងដែលបើកឆ្លងកាត់នេះស្ថិតនៅក្រោមការក្តោបក្តាប់របស់អង្គភាពរថភ្លើងនៅទីក្រុងភ្នំពេញ?

**ផៈ** បាទ ត្រឹមត្រូវ ពីព្រោះគ្មាននរណាប៉ានបញ្ជាទេ ទោះតាមតំបន់ក៏អត់ប៉ានបញ្ជា មានតែភ្នំពេញទេបញ្ជាបាទ។ ព្រោះខ្ញុំនៅតំបន់ខាងពោធិ៍សាត់ហ្នឹង ក៏គាត់មិនដែលមានបញ្ជារទេះភ្លើង បើរទេះភ្លើងមកដល់ហើយ ដាក់មនុស្សចុះហើយ ទាល់តែគេបញ្ជាពីភ្នំពេញមក បានរទេះភ្លើងយើងទៅយកៗប្រជាជនទៀតបាទ។ មិនមាននរណាក្រៅពីភ្នំពេញទេបាទ អ្នកបញ្ជារថភ្លើង។

[១៤:៣០:០២]

**សៈ** ហើយថា តើលោកធ្លាប់ឃើញបញ្ជា គេបញ្ជាមកលោកដែរឬទេ ឬក៏លោកឃើញឯកសារលាយលក្ខណ៍អក្សរដែលគេបញ្ជាថា ឲ្យរថភ្លើងហ្នឹងធ្វើដំណើរទៅមក អ៊ីចេះអ៊ីចុះដែរឬទេ?

**ផៈ** បាទ ខ្ញុំអត់បានដឹងៗ អត់បានដែលឃើញឯកសារគេជូនរទេះភ្លើងទៅនេះនោះទេ។

សៈ លោកក៏បាននិយាយផងដែរថា “នៅស្ថានីយរថភ្លើងដែលទាំងនោះ គឺស្ថិតនៅក្រោមអំណាចរបស់អង្គភាពរថភ្លើងនៅក្នុងភ្នំពេញ”។ សំណួរដដែល តើលោកធ្លាប់ឃើញឯកសារណាមួយទេដែលចេញមកពីភ្នំពេញ ដែលធ្វើឲ្យលោកដឹងថា អង្គភាពនៅភ្នំពេញនោះ គឺមានអំណាចនៅលើស្ថានីយរថភ្លើងដែលនៅតាមខេត្តផងនោះ?

[១៤:៣១:១៣]

**ផៈ** កាលនៅជំនាន់នោះ បើគិតទៅ ការងារទាំងអស់គេធ្វើដូចពីសង្គមដែរបាទ។ សង្គមគេបញ្ជាពីភ្នំពេញ មកដល់ជំនាន់ ប៉ុល ពត បានមានបញ្ជាពីភ្នំពេញអ៊ីចឹងដូចគ្នាបាទ។ គេធ្វើតាមលំអានពីសង្គមខ្លះដែរបាទ។

**សៈ** តើលោកទទួលការបញ្ជា ឬការណែនាំដូចម្តេច? តើអ្នកណាជាអ្នកបង្គាប់ណែនាំ តាម៉ូម ឬក៏មានអ្នកផ្សេងនៅក្រោមបង្គាប់ តាម៉ូម ដែលណែនាំ ឬបង្គាប់ឲ្យក្រុមលោកធ្វើការនោះ?

**ផៈ** ពីរឿងការងារដែលខ្ញុំធ្វើតាមដងផ្លូវដែកក្នុង ២១គីឡូនេះ ធ្វើតាមបញ្ជារបស់ តាម៉ូម។

**សៈ** លោកនិយាយថា អ្វីៗគឺថាការជួសជុលផ្លូវដែកគឺធ្វើតាមបញ្ជារបស់ តាម៉ូម តើច្បាស់ដែរ

ឬទេថា តាមូម ខ្លួនឯងជាអ្នកបញ្ជាដោយផ្ទាល់មករូបលោក ឬក៏មានអ្នកណាផ្សេងនៅក្រោមតាមូម ជាអ្នកបញ្ជូនបញ្ជាមកដល់លោកឱ្យលោកធ្វើការនោះ?

[១៤:៣៣:០១]

**ឆ៖** អត់មានអ្នកណាក្រោម តាមូម ដែលបញ្ជាទេ គឺមានតែតាមូម ម្នាក់ហ្នឹង បញ្ជាអារឿងការងារជួលជុលផ្លូវដែក។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានឬទេ? ថាតើមានបុគ្គលិកប៉ុន្មាននាក់ដែលតាមូម គ្រប់គ្រងនោះ? តើលោកអាចនិយាយពីចំនួនប៉ាន់ប្រមាណតាមលោកចាំបានទេ?

**ឆ៖** បាទ ខ្ញុំមិនចាំបានទេ ពីរឿងស្ថិតិក្នុងចំណោមដែលគាត់ក្តោបក្តាប់ ខ្ញុំអត់បានចាំទេ។ ចាំតែសង្កាត់របស់ខ្ញុំ មានមនុស្ស ដូចថាមានអ្នកធ្វើការ ពុកហ្នឹង១៨នាក់ទៅ ម៉ែ១៨ទៅ ហើយនិងកូនចៅប៉ុន្មានខ្ញុំដឹងតែប៉ុណ្ណឹងទេបាទ។

**ស៖** នេះជាចម្លើយច្បាស់។

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំស្ទើរតែបញ្ចប់ផ្នែកនៃការសួរសំណួររបស់ខ្ញុំហើយ ក៏ប៉ុន្តែសូមអនុញ្ញាតពីតុលាការដើម្បីផ្តល់លទ្ធភាពដើម្បីពិនិត្យមើល ពិភាក្សាជាមួយលោក សុន អរុណ រយៈពេលខ្លះដើម្បីសុំឱ្យគាត់សួរសំណួរបញ្ហាមួយចំនួនពីអ្វីដែលខ្ញុំមិនបាននិយាយនោះ។ ឥឡូវនេះ ខ្ញុំឃើញថា ពេលវេលាដូចជាសមស្របដើម្បីសម្រាក ដើម្បីប្រាកដ ដើម្បីនេះ គឺសូមអនុញ្ញាតលោកប្រធានដើម្បីសម្រាក ហើយយើងខ្ញុំនឹងប្រើពេលបន្ទាប់ពីហ្នឹង គឺ៥នាទីទៀត មុននឹងខ្ញុំបានពិភាក្សាជាមួយសហមេធាវីជាតិរបស់ខ្ញុំបាទ។ អ៊ីចឹងខ្ញុំសូមតុលាការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ប៉ុន្តែអង្គជំនុំជម្រះសួរបញ្ជាក់ ថាតើការប្រើប្រាស់ពេលវេលារបស់លោកហ្នឹងបានពិភាក្សាជាមួយនឹងមេធាវីការពារក្តីពីរក្រុមទៀតហើយឬនៅ? ពីព្រោះមួយភាគីយើងឱ្យតែមួយពេលទេ។ ខាងភាគីការពារក្តីមានតែមួយពេលរសៀលនេះតែប៉ុណ្ណោះ នៅក្នុងការសួរសាក្សីរូបនេះ។

[១៤:៣៥:៣៣]

**លោក ហ្សាស្តេ ប៉ោ៖**

បាទ លោកប្រធាន ខ្ញុំមិនទាន់បានពិភាក្សាជាមួយសហសេវិកមេធាវីក្រុមផ្សេងទេ។ ដូច្នេះ

ហើយ បើសិនជាតុលាការអនុញ្ញាតឲ្យខ្ញុំ ៥នាទី ក្រោយពេលសម្រាកនេះ ខ្ញុំឃើញពួកគាត់ងក់ក្បាល។ ដូច្នេះ ខ្ញុំអាចជម្រាបជូនបានប៉ុណ្ណេះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី អាង ឧត្តម!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន! លោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញា និងសហភាតាទាំងអស់! សួស្តីអ្នកទាំងឡាយ។ ខ្ញុំគិតថាមេធាវីលោក នួន ជា អាចមានពេលវេលាលើសហ្នឹងទៅទៀត។ សម្រាប់ដំណាក់កាលនេះ ក្រុមខ្ញុំប្រហែលមិនមានសំណួរនឹងសួរទេ។ អ៊ីចឹងពេលវេលាអាចមានគ្រប់គ្រាន់សម្រាប់ក្រុមយើងមេធាវីទាំងអស់។ សូមអរគុណ។

[១៤:៣៦:៤០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សម្រាប់ក្រុមយើងខ្ញុំ ក៏អត់មានសំណួរអីដែរ ហេតុដូច្នេះមេធាវីលោក នួន ជា អាចប្រើប្រាស់ពេលវេលានេះបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ឥឡូវដល់ពេលសមស្របនឹងសម្រាកហើយ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០១:៤៣]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

បាទ សូមអញ្ជើញ!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ សូមអរគុណចំពោះការផ្តល់ឱកាសឲ្យយើងខ្ញុំខ្លីបន្ថែមទៀតនេះ ដើម្បីសួរទៅលើចំណុចមួយចំនួន។ ក្រោយពី ដែលខ្ញុំពិភាក្សារួចហើយនោះ គឺថាខ្ញុំមិនមានសំណួរចង់សួរសាក្សីរូបនេះទៀតទេ។ ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា អ្នកនិយាយជាភាសាខ្មែរ បានលើកឡើងអំពីការបកប្រែដែលមិនបានការ -- បកប្រែដោយមិនមានការថតខ្សែអាត់។ នៅពេលដែលយើងនិយាយអំពីការសម្ភាសដែលមិនមានការថតខ្សែអាត់នេះ គឺយើងបានចង់មានន័យថា ការសម្ភាសដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតជាមួយនឹងសាក្សី ហើយមិនមានការថតខ្សែអាត់។ ដូច្នេះ *"អូហ្វរ៍ខត អ៊ិនធឺវីយូ"* នេះបានន័យថា ជាកិច្ចសម្ភាសន៍ដោយមិនមានការថតខ្សែអាត់។ ខ្ញុំគ្រាន់តែចង់ឲ្យអ្នកនិយាយភាសាខ្មែរនោះយល់អំពីពាក្យដែលខ្ញុំបានលើកឡើងមុននោះ -- មុននេះបន្តិចនេះតែប៉ុណ្ណោះ។

ក្រៅពីចំណុចនេះ គឺខ្ញុំមិនមានយោបល់អ្វីផ្សេង ឬក៏សំណួរអ្វីចង់ចោទសួរទៅកាន់សាក្សីរូបនេះទៀតទេ។ ខ្ញុំសូមអរគុណលោកសាក្សី ដែលលោកមកទីនេះ មកផ្តល់សក្ខីកម្មជូនយើងខ្ញុំទាំងអស់គ្នារួមទាំងក្រុមមេធាវី នួន ជា ផងដែរ។ ហើយខ្ញុំជឿថា ប្រហែលជាក្រុមមេធាវីដទៃទៀត ដូចជាមិនមានសំណួរអ្វីទៀត ដូចជាមិនមានសំណួរអ្វីចង់សួរទៅកាន់លោកនោះទេ។

[១៥:០៤:២១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមេធាវីដទៃទៀតទំនងជាមិនមានទេ ព្រោះបានបង្ហាញជំហរច្បាស់លាស់ហើយអំមិញ ហើយប្រសិនបើមានសូមអញ្ជើញ!

បាទ បើសិនជាមិនមានទេ គឺកិច្ចដំណើរការស្តាប់សក្ខីកម្មសាក្សីរូបនេះបានចប់ហើយ។

អរគុណលោក សុខ ឈិន ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះ បានចប់ហើយ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកចង់ទៅបានហើយ។

អង្គជំនុំជម្រះសូមអរគុណចំពោះលោក សុខ ឈិន ដែលបានចំណាយពេលវេលាដ៏មានតម្លៃ មកចូលរួមផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ក្នុងរយៈពេលពេញមួយថ្ងៃនេះ ប្រកបដោយភាពអត់ធ្មត់ ខិតខំ អស់ពីសមត្ថភាព និងលទ្ធភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទាន ក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬទីកន្លែងជាគោលដៅដែលគាត់ចង់ទៅវិញចុះ។

លោក សុខ ឈិន អាចចាកចេញទៅបានហើយ។ សូមអញ្ជើញ ហើយជួបតែសំណាងល្អ និងធ្វើដំណើរប្រកបដោយសុវត្ថិភាព។

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១៥:០៥:៥៧]

**ប្រធានអង្គជំនុំ៖**

ហើយមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី TCCP-64 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលមកកាន់បន្ទប់សវនាការ)*

[១៥:០៦:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនផងដែរថា ផ្អែកតាមពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់។ គាត់សុំលះបង់សិទ្ធិមានវត្តមានក្នុងការ -- សវនាការពិភាក្សាដេញដោល ស្តាប់សក្ខីកម្មសាក្សីចំនួន១០រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំមួយរូប។ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណី ប្រាំមួយរូបនោះក៏មានឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-64 ម្នាក់ដែរ។ ហើយនៅពេលនេះ លោក អៀង សារី កំពុងតែសម្រាកព្យាបាលនៅមន្ទីរពេទ្យខ្មែរ-សូវៀត ហើយបានសុំលះបង់សិទ្ធិមាន

វត្តមាននៅក្នុងកិច្ចដំណើរការពិភាក្សាដេញដោលស្តាប់សក្ខីកម្ម និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដោយមានដែនកំណត់ ដោយគាត់មានបញ្ហាសុខភាពត្រូវសម្រាកទទួលការព្យាបាល តែរូបកាយ និង ស្មារតីសមស្រប។ ហើយអង្គជំនុំជម្រះបានសម្រេចធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-64 ដោយមិនមានវត្តមានរបស់លោក អៀង សារី ដែលអនុវត្តតាមវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

[១៥:០៧:៤៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រី! តើលោកស្រីឈ្មោះអី?

**លោកស្រី ឡាយ បូនី ៖**

**ឆ៖** ចាស នាងខ្ញុំសូមជម្រាបសួរអង្គសវនាការទាំងមូលចាស់។ នាងខ្ញុំឈ្មោះ ឡាយ បូនី កើត នៅឆ្នាំ -- កើតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៥០ នៅសង្កាត់លេខ៤ ក្រុងភ្នំពេញ។

**ស៖** បាទ អរគុណលោកស្រី ឡាយ បូនី។ ហើយតើសព្វថ្ងៃនេះ លោកស្រីមានទីលំនៅទីកន្លែង ណា?

**ឆ៖** នាងខ្ញុំមានទីលំនៅ នៅភូមិត្រពាំងឈូក ផ្លូវ៣៧១ សង្កាត់ទឹកថ្លា ក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ។ ហើយតើលោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃ?

**ឆ៖** នាងខ្ញុំជាមេផ្ទះ ចាំះ។

**ស៖** អរគុណ។ ហើយចុះឪពុកបង្កើតរបស់លោកស្រី គាត់ឈ្មោះអ្វី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ ឡាយ គ្រុយ។ គាត់បានស្លាប់។

**ស៖** បាទ អរគុណ។ ចុះម្តាយបង្កើតរបស់លោកស្រីវិញ គាត់ឈ្មោះអីដែរ?

**ឆ៖** ម្តាយបង្កើតរបស់នាងខ្ញុំឈ្មោះ ឃុត ស៊ីន (ស្លាប់)។

**ស៖** បាទ អរគុណ។ ហើយលោកស្រី ស្វាមីរបស់លោកស្រីគាត់ឈ្មោះអ្វី? ហើយលោកស្រី មានកូនប៉ុន្មាននាក់?

**ឆ៖** ស្វាមីសព្វថ្ងៃ ឬយ៉ាងម៉េចចាស? សព្វថ្ងៃនេះ ខ្ញុំមានស្វាមីឈ្មោះ ចាន់ សារ៉ន ហើយមាន កូនបីនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយលោកស្រីក្នុងនាមលោកស្រី ជាដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីមានសិទ្ធិគឺអាចធ្វើសេចក្ដីថ្លែងរៀបរាប់ ដល់អង្គសវនាការអំពីស្ថានភាពទុក្ខវេទនា និងស្ថានភាពព្យសនកម្ម ដែលកើតមានឡើងចំពោះលោកស្រីដែលមានអាទិ៍ ការខូចខាតខាងផ្លូវចិត្ត ខាងផ្លូវកាយ ឬក៏ខាងសម្ភារៈ។ ហើយការព្យសនកម្មផ្ទាល់ ដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងដែលបានកើតមានពិតប្រាកដរហូតមកដល់ទាល់ពេលបច្ចុប្បន្ន ដែលនាំឲ្យលោកស្រីប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ ដែលប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយសិទ្ធិនេះគឺទុកលទ្ធភាពជូនលោកស្រី ធ្វើសេចក្ដីថ្លែង នៅពេលចុងក្រោយនៃដំណើរការពិភាក្សាដេញដោលនេះ។

អង្គជំនុំជម្រះនឹងផ្ដល់ពេលវេលាសម្រាប់លោកស្រី ការជម្រាបជូនជាមុននេះ ក្នុងបំណងឲ្យលោកស្រីឲ្យបានយល់អំពីសិទ្ធិរបស់លោកស្រី ហើយលោកស្រីមានឱកាសក្នុងការត្រៀមរៀបចំនូវអ្វីដែលលោកស្រីមានបំណងសម្ដែងថ្លែងការណ៍រៀបរាប់អំពីទុក្ខវេទនា ឬក៏/និង ព្យសនកម្មដែលកើតមានឡើងចំពោះលោកស្រីលើបញ្ហានេះ។

[១៥:១១:១២]

ហើយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអនុវត្តតាមបញ្ញត្តិនៃវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀត នៃរឿងក្ដី។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ចំពោះករណីដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គឺលោកស្រីមេធាវី ម៉ុច សុវណ្ណារី ហើយនិង អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងលើកជាសំណួរសម្រាប់លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ បាទ!

[១៥:១២:០២]

**លោកស្រី ម៉ុច សុវណ្ណារី៖**

សូមអរគុណលោកប្រធាន។ ជាដំបូង សូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល ហើយសូមជម្រាបសួរដល់អ្នកស្រី ឡាយ បូនី។

នាងខ្ញុំនឹងចាប់ផ្ដើមសួរសំណួរទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ រួចហើយអ្នកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងបន្តសំណួរ។ ហើយសំណួររបស់នាងខ្ញុំនឹងធ្វើការផ្ដែកជាសំខាន់ទៅលើកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រី ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះការិយាល័យសចៅក្រមស៊ើបអង្កេត ចុះនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩។ ឯកសារដែលមានលេខ D246/3។

ដូច្នេះ នាងខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីផ្ដល់ឯកសារនេះជូនដល់អ្នកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាសូមអនុញ្ញាតនៅក្នុងការបង្ហាញនូវផ្នែកមួយចំនួន ដែលនាងខ្ញុំយោងនៅក្នុងសំណួររបស់នាងខ្ញុំ។ សូមអនុញ្ញាត។

[១៥:១២:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារជាក្រដាសពីមេធាវីយកជូនសាក្សី អ៎! យកជូនដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនដើមបណ្ដឹងរដ្ឋប្បវេណី)*

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** ទាក់ទងជាមួយនឹងឯកសារដែលអ្នកស្រីទើបតែទទួលអម្បាញ់មិញនេះ ខ្ញុំចង់សួរអ្នកស្រីជាដំបូងទាក់ទងជាមួយនឹងការធ្វើឯកសារនេះ។ តើអ្នកស្រីមានចាំបានទេថា មានបុគ្គលិកពីខាងសាលាក្ដីខ្មែរក្រហមបានចុះទៅជួបសម្ភាសជាមួយនឹងអ្នកស្រី?

**លោកស្រី ឡាយ បូនី៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រី ឡាយ បូនី រង់ចាំៗក្បាលមីក្រូប្រតិបត្តិការ ដោយឲ្យភ្លើងសញ្ញាណក្រហម នៅទីនេះ ឬខាងក្រោមសិនណ៎ះ! សឹមនិយាយ។ បាទ ហ្នឹង ក៏បានសំឡេងរបស់លោកស្រីហ្នឹង ចូលទៅប្រព័ន្ធស្ដាប់សំឡេង ហើយនិងប្រព័ន្ធបកប្រែភាសាផង បាទ។ សូមអញ្ជើញ!

**លោកស្រី ឡាយ បូនី៖**

**ឆ៖** ខ្ញុំចាំបានថា ក្រោយពេលដែលខ្ញុំបានដាក់ពាក្យបណ្ដឹងហើយ មានដីកាហៅខ្ញុំទៅកន្លែងផ្សារកាប់គោ ដែលខ្ញុំមិនដឹងថាអី គ្រាន់តែថាជាសាលាក្ដីខ្មែរក្រហមដែរ ចាស សម្រាប់ទទួលពាក្យបណ្ដឹង។ គេបានហៅខ្ញុំទៅសួរ និងចោទជាសំណួរ ហើយឲ្យខ្ញុំឆ្លើយទៅតាមឯកសារដែលបាន ខ្ញុំបានទទួលនេះ។ ចាស ជាសំឡេងពិតរបស់ខ្ញុំ។

[១៥:១៤:៣៣]

**ស៖** ចាស សូមអរគុណអ្នកស្រី។ ខ្ញុំសូមបង្ហាញអ្នកស្រីជាដំបូង សំណួររបស់ខ្ញុំ ខ្ញុំនឹងសួរទាក់ទងនឹងបីផ្នែកសំខាន់។ សំខាន់ទី១ -- ផ្នែកទី១ គឺខ្ញុំនឹងសួរអ្នកស្រីទាក់ទងជាមួយនឹងស្ថានភាពក្រុមគ្រួសាររបស់អ្នកស្រី ក៏ដូចជាស្ថានភាពនៅទីក្រុងភ្នំពេញ មុនការមកដល់បន្តិចនៃជ័យជម្នះរបស់កងទ័ពខ្មែរក្រហម នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ ហើយផ្នែកទី២ ខ្ញុំនឹងធ្វើការសួរសំណួរដល់អ្នកស្រីទាក់ទងជាមួយនឹងអង្គហេតុដែលគេជម្លៀសអ្នកស្រីចេញពីទីក្រុងភ្នំពេញ ក្រោយមកដល់របស់កងទ័ពទាំងនោះ។ ហើយផ្នែកទី៣ ខ្ញុំនឹងធ្វើការសួរសំណួរដល់អ្នកស្រីទាក់ទងជាមួយនឹងការដែលគេជម្លៀសអ្នកស្រីនៅក្នុងដំណាក់កាលទី២ ពីស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល រហូតទៅដល់ខេត្តពោធិ៍សាត់ ស្រុកបាកាន។

[១៥:១៥:២០]

សំណួរទី១របស់ខ្ញុំនេះ ខ្ញុំនឹងសួរមុនការមកដល់របស់ទាហានខ្មែរក្រហម ដែលខ្ញុំសូមបង្ហាញឯកសារយោងទាក់ទងទៅនឹងសំណួររបស់ខ្ញុំ។ ខ្ញុំសូមបង្ហាញនូវកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រីដែលខ្ញុំបានបង្ហាញអម្បាញ់មិញ នៅក្នុងទំព័រដែលមានលេខ ERN ជាភាសាខ្មែរ 00373245, ERN ជាភាសាអង់គ្លេស 00379155 និង ERN ជាភាសាបារាំង 00422447។ នៅក្នុងផ្នែកនៃសម្រង់នៃអ្នកស្រីបានអះអាងថា "កូនប្រុសទី៣របស់អ្នកបានកើតមកភ្លាម ហើយក៏ស្លាប់ភ្លាម។ គឺ២០ថ្ងៃមុនការមកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥"។ អ៊ីចឹងខ្ញុំសូមឲ្យអ្នកស្រីធ្វើការៀបរាប់បន្តិចអំពីស្ថានភាព និងលក្ខខណ្ឌដែលកូនប្រុស -- ដែលកូនអ្នកស្រីបានប្រសូត ដែលអ្នកស្រីបានប្រសូតកូនទី៣នោះ។ តើស្ថានភាព

ស្រុកទេសនៅពេលនោះ មិនអនុញ្ញាតឲ្យអ្នកស្រីទៅឆ្លងទន្លេនៅមន្ទីរទេ ឬក៏យ៉ាងណា?

**ឆ៖** នៅពេលនោះ ស្ថានភាពស្រុកទេសកំពុងតែច្របូកច្របល់។ នាងខ្ញុំគ្រប់ខែ ហើយនាងខ្ញុំមកសំណាក់នៅផ្ទះម្តាយខ្ញុំនៅពេទ្យ ឡុង ង៉ែត នៅមុខពេទ្យ ឡុង ង៉ែត។ ពេលនោះគ្រាប់ផ្លោងពីត្រើយទន្លេខាងកើត ឆ្លងកាត់ដំបូលកាំបូឌីយ៉ាណា មករំលងដំបូងផ្ទះខ្ញុំ។ ដូច្នេះ ម្តាយខ្ញុំមិនអាចឲ្យខ្ញុំទៅឆ្លងទន្លេនៅមន្ទីរពេទ្យបានទេ ព្រោះគាត់ថា ខ្លាចមានការអីបែកខ្ញែកគ្នា។ អ៊ីចឹងគាត់ក៏បង្ខំចិត្តឲ្យខ្ញុំឆ្លងទន្លេដោយយាយម៉បខ្មែរនៅតាមផ្ទះ។ យាយម៉បខ្មែរ កាលនោះកាំបូឌីយ៉ាណាសុទ្ធតែជនភៀសខ្លួន។ ដល់អ៊ីចឹង ទៅដោះស្រាយរកយាយម៉បបាននៅទីនោះ មកបង្កើតនៅផ្ទះ។ ពេលនោះខ្ញុំឈឺពោះយូរណាស់ ខុសពីធម្មតា ខុសពីកូនពីរមុន ដែលមិនដឹងមូលហេតុ។ ដល់ក្រោយទើបខ្ញុំបានឆ្លងទន្លេរួច តែកូននោះបានស្លាប់ហើយ។ ប្រហែលជាស្លាប់នៅក្នុងពោះ ប៉ុន្តែមិនដឹងជាស្លាប់ពីអង្កាល់ ខ្ញុំអត់ដឹង ព្រោះកើតមកវាមានរបកៗស្បែក ចាស។ ដូច្នេះ ខ្ញុំឆ្លងទន្លេចប់ ដោយសារយាយម៉បខ្មែរ គាត់ធ្វើការទម្លាក់សុកមិនស្អាត ធ្វើឲ្យខ្ញុំមានជំងឺមួយដែលតាមក្បួនពេទ្យគេហៅថា “ក្រឡាភ្លើង”។ ចាស គឺគ្រុនក្តៅរងាញាក់រាល់ថ្ងៃ។

ចប់ពីនេះទៅខ្ញុំក៏បានទៅព្យាបាលខ្លួននៅពេទ្យទូតចិន កាលនោះពេទ្យនៅទូតចិនមានឆ្មបដែរ ឆ្មបពេទ្យត្រឹមត្រូវ ចាស។ ដល់ពេលទៅមើលទៅគេក៏ធ្វើការបោសសម្អាតទម្លាក់សុកឲ្យខ្ញុំស្អាតហើយ រយៈពេលខ្ញុំជាមិនទាន់ស្រួលបួលទេ ប៉ុន្តែគ្រាន់តែ២០ថ្ងៃក្រោយមក ខ្ញុំក៏ត្រូវបានថ្ងៃ១៧ មេសា មកដល់ហើយត្រូវបានជម្លៀសចេញពីផ្ទះទៅ ចាស។

[១៥:១៨:៣៦]

**ស៖** ចាស សូមអរគុណអ្នកស្រី។ ខ្ញុំសូមយោងទៅលើផ្នែកមួយទៀតនៃឯកសារដដែលហ្នឹង គឺនៅក្នុងទំព័រដែលលេខ ERN ជាភាសាខ្មែរ 00373245 ដដែល, ជាភាសាអង់គ្លេស 00379156, ជាភាសាបារាំង 00422447។ ពេលនោះអ្នកស្រីបានមានប្រសាសន៍ប្រាប់ខាងអ្នកស៊ើបអង្កេតថា “ប្តីរបស់អ្នកឈ្មោះ ប្រាក់ ស៊ីណាត ជាទាហានពាក់សក្តិ៣ ជំនាន់ លន់ នល់ ទទួលបន្ទុកសន្តិសុខ។ មានមូលដ្ឋាននៅក្នុងបរិវេណរបស់ផ្ទះ លន់ នល់ នៅចំការមន”។ អ៊ីចឹងខ្ញុំចង់សួរអ្នកស្រី ទាក់ទងជាមួយនឹងចំណុចនេះបន្ថែមថា តើប្តីរបស់អ្នកស្រីដែលជាទាហានពាក់សក្តិ៣ លន់ នល់ ហ្នឹងគាត់បានបោះបង់ឯកសណ្ឋានជាទាហាន លន់ នល់ របស់គាត់ហ្នឹងនៅពេលណាដែរ?

**ឆ៖** នៅពេលនោះស្វាមីនាងខ្ញុំបានបោះបង់ឯកសណ្ឋានជាទាហាន នៅពេលដែលលោក លន់ នល់ គាត់បានជម្លៀសចេញពីប្រទេសកម្ពុជា។ ប៉ុន្តែខ្ញុំមិនចាំថា ពេលណា ថ្ងៃណា គ្រាន់តែដឹងថាមុន

ចូលឆ្នាំខ្មែរ ពេលដែលស្រុកទេសកំពុងច្របូកច្របល់ គឺថាលោក លន់ នល់ បានភៀសខ្លួនចេញបាត់បាន ហើយ។ អ៊ីចឹងពេលនោះទាហាននៅជុំវិញផ្ទះហ្នឹង ក៏នៅជុំយាមផ្ទះគាត់ហ្នឹង ក៏ត្រឡប់មកតាមផ្ទះរៀង ខ្លួនវិញ ចាស។

**ស៖** ទាក់ទងដល់ទាហាន លន់ លន់ នៅពេលនេះ ខ្ញុំចង់សួរអ្នកស្រីបន្ថែមទៀតថា អ៊ីចឹងមាន ន័យថាយើងអាចនិយាយបានថា ទាហាន លន់ នល់ បានបោះបង់ចោលការការពារទីក្រុងភ្នំពេញ នៅពេលដែលលោកសេនាប្រមុខ លន់ នល់ ហ្នឹងចាកចេញពីទីក្រុងភ្នំពេញ ឬក៏ពេលណាផ្សេងដែលអ្នក ស្រីដឹង?

**ឆ៖** ពេលនោះ ខ្ញុំអត់ចាំទេចាស ខ្ញុំគ្រាន់តែដឹងថាពេលនោះប្ដីខ្ញុំបានប្រាប់ថា លោកសេនាប្រមុខ លន់ នល់ បានភៀសខ្លួនចេញពីប្រទេសកម្ពុជាហើយ។ ដល់អ៊ីចឹងការងារ វាធូរស្រាល គ្រាន់តែទៅ បង្ហាញមុខម្ដងម្កាលអ៊ីចឹងទេចាស។ មិនបានទៅធ្វើការទៀងទាត់ រាល់ថ្ងៃ រាល់យប់ទៀតទេ។

[១៥:២១:១៤]

**ស៖** សំណួរបន្ទាប់មកនេះ បន្ទាប់មកទៀតនេះ ខ្ញុំចង់សួរអ្នកស្រីទាក់ទងជាមួយនឹងស្ថានភាព របស់ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ មុនការមកដល់បន្ដិចរបស់ខ្មែរក្រហម។ តើស្ថានភាពរស់នៅ របស់ប្រជាជននៅពេលនោះយ៉ាងម៉េចដែរ? ហើយដោយឡែកក្រុមគ្រួសារ ជាពិសេសក្រុមគ្រួសារ របស់អ្នកស្រី ដែលអ្នកស្រីបានដឹងផ្ទាល់ ទាក់ទាក់ទងជាមួយនឹងអាហារ ទាក់ទងជាមួយនឹងៗស្បៀង ទាក់ទងជាមួយនឹងសន្ដិសុខគ្រប់បែបយ៉ាង តើអ្នកស្រីអាចប្រាប់តុលាការបានទេ ពីស្ថានភាពរបស់ពួក គាត់នៅពេលនោះ?

**ឆ៖** នៅពេលនោះ គឺថាមានការច្របូកច្របល់ពេញទីក្រុងភ្នំពេញ។ ច្របូកច្របល់ខ្លាំងបំផុត គឺទំនិញឡើងថ្លៃ អង្ករពិបាករកទិញ ហើយរបររកស៊ីហ្នឹងវាមិនចិតថេរ ម៉្ងៃថ្ងៃអ៊ីចេះ ម៉្ងៃថ្ងៃអ៊ីចុះ។ ហើយ ប្រជាជនពលរដ្ឋដែលជម្លៀសចេញពីតាមខេត្តនានា ពីតាមស្រុកនានាចូលមកកកកុញនៅទីក្រុងភ្នំពេញ ចាស។ ចំណែកគ្រួសាររបស់ខ្ញុំបានជីកជាត្រង់សេនៅក្រោមផ្ទះ លេនដ្ឋានហ្នឹងគឺថា យើងរៀបចំស្រួល បួល មានការណ៍អី រត់ជ្រកក្រោមហ្នឹងហើយ ហើយបានទិញស្បៀងជាអង្ករ ប៉ុន្ដែពេលនោះ ខ្ញុំអត់សូវ ពិបាករឿងស្បៀងទេ ព្រោះប្ដីខ្ញុំគាត់ធ្វើទាហាន ម៉្លោះហើយស្បៀងនៅខាងទាហានហ្នឹង គេអត់មាន ខ្វះខាតទេចាស។ ខ្ញុំទាក់ទងបានខាងហ្នឹងមក អ៊ីចឹងគ្រួសារខ្ញុំអត់សូវពិបាកទេរឿងស្បៀង ពិបាករឿង ម្ហូម ចាស។ ហើយយើងចេះតែរត់ពួនថ្ងៃឡើងលើ យប់រត់ពួនឮគ្រាប់ផ្លោងអ៊ីចឹងទៅ ចាស់ៗរស់នៅក្នុង

ត្រង់សេរហួត ជីដូនខ្ញុំ ម្ដាយខ្ញុំ ហើយក្មេងហ្នឹងចាំស្ដាប់ ចាំស្ដាប់ស្ថានភាព ចាំស្ដាប់ព្រឹត្តិការណ៍ តើវាប្រែប្រួលយ៉ាងណាទៀតចាស។ គ្រាន់ថាវាច្របូកច្របល់ពិបាក ដែលយើងមិនអាចនិយាយបាននេះអាមុនបែកហ្នឹង គឺពិបាកមែនទែនហើយ ចាស។

[១៥:២៣:១៦]

**ស៖** សូមអរគុណអ្នកស្រី។ អ៊ីចឹងនៅពេលដែលអ្នកស្រីធ្លាប់មានបទពិសោធន៍នៅក្នុងការរស់នៅក្នុងភាពចលាចលអ៊ីចឹង អ៊ីចឹងតើអ្នកស្រីនៅពេលនោះ មានការរំពឹងទុកយ៉ាងម៉េចដែរ ចំពោះការមកដល់ទីក្រុងភ្នំពេញរបស់ទាហានខ្មែរក្រហម ក្រោយជ័យជម្នះក្នុងខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** ក្រោយជ័យជម្នះឆ្នាំ១៩៧៥ ពេលដែលប្រទេសជាតិកំពុងតែច្របូលច្របល់ ប្រជាជនពលរដ្ឋបានរត់មកជ្រកកោននៅទីក្រុងភ្នំពេញ ហាក់ពាសពេញពិបាករស់បំផុត។ ពេលដែលទាហានខ្មែរក្រហមចូលដល់ ពួកយើងមានការសប្បាយរីករាយណាស់ អបអរសាទរថា សន្តិភាពកើតមានហើយនៅប្រទេសកម្ពុជាយើង។ នាំគ្នាលើកក្រណាត់សស្វាគមន៍ដល់ពួកខ្មែរក្រហម ពួកទាហាន ប៉ោកព្រៀវតាមថ្នល់គ្រប់ទីកន្លែងចាស។ ព្រោះជឿជាក់ថាប្រទេសយើងពិតជាមានសន្តិភាពហើយពេលនេះ។

**ស៖** អរគុណចំពោះចម្លើយអ្នកស្រី។ ខ្ញុំនឹងបន្តសួរសំណួរទាក់ទងជាមួយនឹងការដែលគេជម្លៀសអ្នកស្រីចេញពីទីក្រុងភ្នំពេញ។ អ៊ីចឹងសំណួរដំបូងនៅក្នុងផ្នែកនេះ ខ្ញុំចង់សួរអ្នកស្រីថា នៅក្នុងពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ តើអ្នកស្រីរស់នៅម្ដុំណាដែរនៅក្នុងទីក្រុងភ្នំពេញ? ខ្ញុំចង់បានទីតាំងជាក់លាក់នៃផ្ទះរបស់អ្នកស្រី។

[១៥:២៤:៤៧]

**ឆ៖** មុនដំបូង ពេលដែលខ្ញុំមានជំងឺ ចាសក្រោយពេលឆ្លងទន្លេហើយ ខ្ញុំមានជំងឺ ខ្ញុំស្នាក់នៅមុខពេទ្យ ឡុង ង៉ែត សង្កាត់លេខ៤ ក្រុងភ្នំពេញ ផ្ទះម្ដាយខ្ញុំ។ តែក្រោយពេលដែលខ្ញុំមានសុខភាពអីស្រួលបួលហើយ ខ្ញុំក៏ត្រឡប់មកផ្ទះដែលខ្ញុំនៅវិញ គឺនៅម្ដុំរោងកុនម្កុដពេជ្រ ជិតពេទ្យចិន ខ្ញុំមករស់នៅវិញ ព្រោះខ្ញុំទៅស្នាក់នោះខ្ញុំអត់មានយកអីវ៉ែអីវ៉ាន់អីទៅទេ។ អីវ៉ែអីវ៉ាន់អីនៅផ្ទះខ្ញុំខាងរោងកុនកំពូលពេជ្រ ជិតពេទ្យចិននេះទាំងអស់។ ខ្ញុំក៏ត្រឡប់មកនៅផ្ទះខ្ញុំវិញ។ ចាស ត្រឡប់មកមិនបានប៉ុន្មានថ្ងៃផងហ្នឹងស្រាប់តែដល់ថ្ងៃ ១៧មេសា ហ្នឹង ត្រូវទាហានខ្មែរក្រហមឲ្យរៀបចំអីវ៉ាន់ គឺត្រូវតែជម្លៀសចេញ។ ជម្លៀសចេញពីទីក្រុងភ្នំពេញក្នុងពេលឥឡូវនេះ ព្រោះខ្លាចទាហានអាមេរិកាំងមកទម្លាក់គ្រាប់បែកពេញភ្នំពេញ។ ហើយការជម្លៀសនេះ គឺគេឲ្យជម្លៀសតែ៣ថ្ងៃទេ ទៅ ១អាទិត្យទេ។ ដូច្នេះ ពេល

ដែលជម្លៀសចេញទៅគឺថា ពេលដែលខ្ញុំសរសៃរខ្ចីផង ពេលដែលខ្ញុំមានកូនតូចពីរនាក់ទៀត អាយុ៣ឆ្នាំ និងអាយុ ៥ឆ្នាំ ខ្ញុំមានការពិបាកខ្លាំងណាស់។ អ៊ីចឹង ខ្ញុំអត់ត្រូវការយកអ្វីច្រើនទេចាស ព្រោះខ្ញុំគិតថា ឲ្យតែមានលុយទៅដល់ទីណាក៏យើងរស់បានដែរ។ មានដូចពាក្យថាឯណា គ្រាន់តែចេញផុតពីផ្ទះទៅ គេស្រែកថាលុយអត់ចាយទេ ចប់ហើយ ពេលនោះខ្ញុំអត់មានសល់អង្ករមួយគ្រាប់សោះ មានតែបាយមួយឆ្នាំងដែលព្រលឹមឡើងខ្ញុំដាំត្រៀមចេញហ្នឹងចាស។ យកទៅតាមផ្លូវរហូតទៅ។

[១៥:២៦:២២]

ហើយពេលដែលខ្ញុំធ្វើដំណើរចេញទៅហ្នឹង គឺថា ស្ទះផ្លូវគ្រប់កន្លែង ព្រោះពេលថ្ងៃនោះ នៅទីក្រុងភ្នំពេញគឺថាកន្លែងណាក៏ត្រូវចេញថ្ងៃនុងដែរ ដល់អ៊ីចឹងទៅទាំងឡាន ទាំងម៉ូតូ ទាំងមនុស្ស ទាំងរទេះរុញ ទាំងកង់ កកកុញពេញផ្លូវ ធ្វើដំណើរថា យឺតបំផុតពីត្រឹមផ្ទះខ្ញុំម្តុងពេទ្យហ្នឹង ពេទ្យចិនហ្នឹង មិនដល់ពេទ្យចិនទេ ជិតជាងផង ទៅដល់សាលាច្បាប់ហ្នឹង គឺថាចំណាយពេលមួយព្រឹកធំ។

អន្ទ្រើកៗហើយពេលនោះខ្ញុំពិបាកបំផុតហើយ ខ្ញុំសរសៃរខ្ចីត្រូវអង្គុយលើឡាន ឡានអត់ដំបូល ឡានរបៀបយើងឥឡូវអាមួយតោនកន្លះពីរតោនហ្នឹងចាស។ ត្រូវអត់មានដំបូល ហើយបីកូនពីរនាក់ជាប់នឹងខ្លួនទៀត សរសៃរខ្ចីក្តៅហែង ដល់អ៊ីចឹងមានការពិបាកបំផុតហើយ ព្រោះពេលនោះខ្ញុំមិនដែលពិបាកផងចាស។ ខ្ញុំធ្លាប់នៅផ្ទះខ្ញុំ ខ្ញុំមានញាតិមិត្តខ្ញុំជួយការងារសព្វគ្រប់ ខ្ញុំអត់ដែលធ្វើអីទេ។ ដល់អ៊ីចឹងទៅវាមានការពិបាកបំផុតដែលយើងធ្លាប់រស់ស្រួល ហើយចាប់ផ្តើមថ្មីថ្មោងបំផុតចេញធ្វើដំណើរចេញទៅចាស។ លុះដល់យប់ៗឡើងខ្ញុំក៏បានឆ្លងផុតពីស្ពានច្បារអំពៅហ្នឹង ទៅដល់--

**ស៖** សូមទោសអ្នកស្រី ខ្ញុំនឹងទៅដល់ចំណុចហ្នឹង តែខ្ញុំនឹងសួរសំណួរមួយដំណាក់ម្តងៗ ហើយសូមអ្នកស្រីនិយាយយឺតៗជាងហ្នឹងបន្តិចដើម្បីជួយសម្រួលដល់អ្នកដែលបកប្រែភាសាផង។

អ៊ីចឹងត្រឡប់មកនៅពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ខ្ញុំសូមត្រឡប់ទៅថយក្រោយបន្តិចវិញណ៎ះ! នៅពេលដែលខ្មែរក្រហមចូលមកដល់ភ្នំពេញ ដែលគេឈ្នះហើយ អ៊ីចឹងតើអ្នកស្រីមានបានឮថា តើគេមានប្រកាសព័ត៌មានអ្វីទេ? ខ្មែរក្រហមគេមានប្រកាសព័ត៌មានអ្វីទេ ក្រោយពេលដែលគេចូលមកកាន់អំណាចហើយ? ហើយគេប្រកាសតាមមធ្យោបាយណាដែរ បើមាន?

[១៥:២៨:១៣]

**ឆ៖** ចាស ពេលនោះ គេបានប្រកាសតាមវិទ្យុជាតិយើង ចាស។ ពេលនោះ គេប្រកាសថា "ខ្មែរក្រហមចូលកាន់បានដល់ទីក្រុងភ្នំពេញ គឺបញ្ចប់ជាស្ថាពរ។ អ៊ីចឹងទេ សូមឲ្យយើងហ្នឹង អ្នកប្រជា

ពលរដ្ឋនៅទីក្រុងភ្នំពេញរក្សាភាពស្ងប់ស្ងាត់ចាំស្ដាប់ព័ត៌មានបន្តទៅទៀត ចាស។

**ស៖** អរគុណអ្នកស្រី។ តើនៅតាមវាំងដែលគេប្រកាសហ្នឹង គេមានប្រកាសអ្វីទាក់ទងជាមួយនឹងការជម្លៀសប្រជាជនហ្នឹងដែរទេ?

**ឆ៖** កន្លែងហ្នឹងខ្ញុំដូចអត់បានស្ដាប់ទេចាស។ ខ្ញុំអត់បានស្ដាប់ទេ ពេលដែលគេមកប្រាប់ឲ្យយើងជម្លៀសចេញ គឺយោធាផ្ទាល់តែម្ដងចាស ស្ពាយអាវុធដើរតាមផ្ទះប្រាប់។

**ស៖** អម្បាញ់មិញអ្នកស្រីមានប្រសាសន៍ថា យោធាបានដើរតាមផ្ទះប្រាប់ឲ្យប្រជាជនចេញ ហើយករណីផ្ទះរបស់អ្នកស្រីហ្នឹងក៏អ៊ីចឹងដែរ គឺយោធាចូលទៅ។ អ៊ីចឹងខ្ញុំចង់រំឭការចងចាំអ្នកស្រីនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រីដដែលហ្នឹងគឺនៅត្រង់ទំព័រ ដែលមានលេខ ERN ជាភាសាខ្មែរលេខ 00373245 ដដែលហ្នឹង ហើយជាភាសាអង់គ្លេស 00379156 និងជាភាសាបារាំង 00422447 ត្រង់កន្លែងហ្នឹងអ្នកស្រីបាននិយាយថា "ពួកគេមានអាវុធ ហើយនៅពេលដែលយើងឃើញអាវុធ យើងក៏ចាកចេញតាមបញ្ជារបស់គេ"។ អ៊ីចឹងត្រង់ចំណុចហ្នឹង ខ្ញុំមានសំណួរពីរបីតូចៗ ដើម្បីនឹងសួរអ្នកស្រី។ ខ្ញុំចង់ដឹងថា តើមានទាហានខ្មែរក្រហមប៉ុន្មាននាក់ដែលបានចូលមកក្នុងផ្ទះអ្នកស្រីនៅពេលនុ៎ង?

**ឆ៖** មុនដំបូង គេចូលមកផ្ទះខ្ញុំ ខ្ញុំឃើញតែម្នាក់ទេ តែបន្ទាប់ពីគេនៅនិយាយចុះឡើងជាមួយយើងហ្នឹង ទើបមានទាហានខ្មែរក្រហមពីរនាក់ទៀតមកដល់ផ្ទះខ្ញុំ ហើយម្នាក់ៗសុទ្ធតែមានស្ពាយកាំភ្លើងនៅលើស្មាទាំងអស់ចាស។

[១៥:៣០:២៣]

**ស៖** តើពួកគេពាក់ឯកសណ្ឋានរបៀបម៉េចដែរ?

**ឆ៖** គេពាក់ឯកសណ្ឋានពណ៌ខ្មៅចាស ហើយពាក់មួកៗរបៀបដូច គេហៅ *ហ្សកកី* ដូចទាហានចិនឥឡូវអ៊ីចឹងចាស។

**ស៖** នៅពេលដែលគេចូលទៅផ្ទះរបស់អ្នកស្រីហ្នឹង តើពួកគេមានអាកប្បកិរិយាដូចម្ដេច? ហើយនិយាយអីខ្លះចំពោះជាមួយនឹងអ្នកស្រី?

**ឆ៖** ពេលនោះ ខ្ញុំនៅលើផ្ទះប៉ុន្តែខ្ញុំឃើញអាកប្បកិរិយារបស់គេ គេនិយាយគ្រោតដៃគ្រោតជើងជាមួយនឹងស្វាមីខ្ញុំ និងជាមួយនឹងអ្នកជិតខាង ដែលនៅផ្ទះជាមួយខ្ញុំហ្នឹងដែរនៅខាងក្រោមចាស។ គេនិយាយគ្រោតដៃគ្រោតជើង ដល់និយាយចប់ទៅបានប្ដីខ្ញុំឡើងមកប្រាប់ខ្ញុំថា គេនិយាយម៉ាត់ៗ ហើយគេដាក់

ខគេច្បាស់លាស់អ៊ីចឹង គឺត្រូវតែចេញនៅពេលឥឡូវហ្នឹង អត់នៅបានទេ ដាច់ខាតត្រូវតែចេញ។ ហើយពេលនោះដល់ប្តីខ្ញុំឃើញមានមានកាំភ្លើង ឃើញសម្តីគេម៉ាត់ៗផង អ៊ីចឹងខោអាវខ្មៅអីអ៊ីចឹងទៅ គឺតម្រូវថា យើងត្រូវតែរៀបអីវ៉ាន់ដាក់ឡាន។ ពេលនោះ យើងក៏នាំគ្នារៀបចំអីវ៉ែអីវ៉ាន់ដាក់លើឡានទាំងអស់គ្នាទាំងបួន-ប្រាំគ្រួសារ ដែលនៅផ្ទះជាមួយហ្នឹងចាស។

**ស៖** ពេលនោះមានបានប្រកែកជាមួយគេថា មិនសុខចិត្តចេញដែរទេអ្នកស្រី?

**ឆ៖** ពេលនោះ ពួកយើងខ្ញុំមិនប៊ានប្រកែកជាមួយគេ ព្រោះឃើញអាវុធគេនៅស្ពាយលើស្មារអ៊ីចឹង ហើយសម្តីម៉ាត់ៗអ៊ីចឹងខ្លាចគេបាត់ទៅហើយ បាក់ស្បាតហើយចាស។

[១៥:៣២:១០]

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំសួរសំណួរបន្តទៅទៀត។ នៅពេលដែលខ្មែរក្រហមបានចូលដល់ផ្ទះអ្នកស្រីហ្នឹង តើទាហានទាំងអស់ហ្នឹងគេបានដឹងទេថា ប្តីអ្នកស្រីហ្នឹងគឺជាអតីតទាហាន លន់ នល់?

**ឆ៖** ចាស នៅពេលដែលគេចូលទៅដល់ទីនោះ ព្រោះគេអត់មានឡើងលើផ្ទះផង គេឈរនៅខាងក្រោម។ ដូច្នេះ គេអត់ដឹងថា ប្តីខ្ញុំជាទាហានទេចាស។

**ស៖** យើងអាចនិយាយបានថា គ្រួសារអ្នកស្រីបានលាក់អត្តសញ្ញាណខ្លួនឯងបាន ដែលទាក់ទងជាមួយនឹងទាហាន លន់ នល់។ អ៊ីចឹងតើអ្នកស្រីមានបានដឹង ឬក៏មានបានឃើញ មានទាហានខ្មែរក្រហមគេធ្វើយ៉ាងណាខ្លះ ជាមួយនឹងទាហាន លន់ នល់ មួយចំនួន ដែលគាត់មិនអាចលាក់អត្តសញ្ញាណខ្លួនគាត់បានទេ? មានឃើញទេ?

**ឆ៖** នៅពេលនោះ ខ្ញុំឃើញដែរ តែខ្ញុំឃើញតិចតួចទេ ហើយបើច្រើនឮគេនិយាយ គឺគេចងស្លាបសេកយកទៅ បណ្តើរយកទៅតែម្តង។ ហើយសួរថាហ្នឹងចី? ថា អ្ហឺ! គេមើលស្នាមៗជើងនេះ គេមើលអាកន្លែងពាក់ស្បែកជើង វាក្រិននេះ គេសង្ស័យ គេដឹងតែចងស្លាបសេកយកទៅហើយ។

**ស៖** ក្រុមគ្រួសាររបស់អ្នកស្រីទាំងមូលត្រូវបានគេជម្លៀសចេញពីភ្នំពេញ តើអ្នកគ្រូ -- តើអ្នកស្រីអាចជម្រាបជូនតុលាការបានទេថា នៅពេលនោះតើសមាសភាពក្នុងក្រុមគ្រួសាររបស់អ្នកស្រី ដែលទៅជាមួយគ្នានៅក្នុងឡានហ្នឹង គឺមានអ្នកណាគេខ្លះ ហើយចំនួនប៉ុន្មាននាក់?

[១៥:៣៣:៤៨]

**ឆ៖** នៅពេលនោះក្រុមគ្រួសារខ្ញុំមានសមាជិកតែបួននាក់ទេចាស គឺប្តីនាងខ្ញុំ ខ្ញុំ ហើយនិងកូនពីរនាក់។ ព្រោះមុន អាហ្នឹងកូនដែលកើតហើយស្លាប់វាចប់ហើយណ៎ា អ៊ីចឹងមានតែបួននាក់ទេ។ ប៉ុន្តែ

ពេលដែលយើងជម្លៀសចេញទៅហ្នឹង ឡើងឡានមានបងជីដូនមួយខ្ញុំ ដែលនៅផ្ទះជាមួយគ្នាត្រូវជិះឡានហ្នឹងដែរ ហើយអ្នកជួលផ្ទះរបស់គាត់ហ្នឹង មានពីរគ្រួសារទៀត ក៏ត្រូវជិះឡានជាមួយគ្នាហ្នឹងដែរចាស។ ឡើងឡានមូលគ្នា ចេញទៅ។

**ស៖** អរគុណអ្នកស្រី។ អ៊ីចឹង ខ្ញុំសូមនាំអ្នកស្រីចូលទៅក្នុងអតីតកាល នៅពេលដែលអ្នកស្រីធ្វើដំណើរចេញពីផ្ទះនៅលើដង -- នៅលើតាម -- នៅលើដងវិថីក្នុងទីក្រុងភ្នំពេញ ដើម្បីចាកចេញពីគេហដ្ឋានរបស់អ្នកស្រី។ ខ្ញុំសូមនាំអ្នកស្រីទៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រីដដែល នៅក្នុងទំព័រដែលមានលេខ ERN ជាភាសាខ្មែរ 00373246, ជាភាសាអង់គ្លេស 00379156 ដល់ 57, ជាភាសា

បារាំង 00422448។ នៅត្រង់ចំណុចនេះ គឺអ្នកស្រីបានអះអាងថា "បើមានអ្នកណាប៉ានត្រឡប់ក្រោយ ពួកទាហានទាំងនោះនឹងបាញ់សម្លាប់ភ្លាម"។ អ៊ីចឹងត្រង់ចំណុចនេះ ខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីបានដឹងពីរឿងនេះ ពីហេតុការណ៍នេះដោយរបៀបណាដែរ? តើខ្មែរក្រហមបានប្រកាសប្រាប់អ្នកស្រីដោយផ្ទាល់មាត់ ឬក៏យ៉ាងណា?

**ឆ៖** ពេលនោះ ខ្ញុំដឹងតាមរយៈប្តីខ្ញុំ និងបងប្អូនរួមដំណើរជាមួយចាស ព្រោះឃើញស្លាប់អីកណ្តាលផ្លូវអ៊ីចឹងសួរថា ហេតុអីបានជាមានស្លាប់អ៊ីចឹង? ថា អ្ហ៎ សុទ្ធតែបកក្រោយ គេហាមអត់ឲ្យទៅក្រោយវិញទេ ឲ្យតែចេញដើរទៅមុខរហូត បើប៉ានបកក្រោយគេអត់ទុកជីវិតទេចាស។ ខ្ញុំឃើញសាកសពតាមផ្លូវចេះតែឆ្ងល់សួរទៅចាស។

[១៥:៣៥:៥៤]

**ស៖** នៅក្នុងទំព័រដដែលនេះ ខ្ញុំចង់សួរអ្នកស្រីៗបានមានប្រសាសន៍ទៀតថា "នៅតាមផ្លូវ ខ្ញុំបានឃើញប្រជាជនត្រូវជម្លៀសចេញពីមន្ទីរពេទ្យរុស្ស៊ី ហើយខ្ញុំបានឃើញអ្នកជំងឺសម្រាកនៅលើគ្រែពេទ្យមានព្យួរសេរ៉ូម ធ្វើដំណើរតាមផ្លូវ ដោយមានគេរុញគ្រែនោះ"។ ត្រង់កន្លែងនេះ ខ្ញុំសួរថាតើអ្នកស្រីបានឃើញប្រជាជនដែលត្រូវបានគេ -- ប្រជាជនយើង អាចនិយាយបានថាជាអ្នកជំងឺ ដែលត្រូវបានគេជម្លៀសចេញពីមន្ទីរពេទ្យនោះ មានចំនួនប្រហែលជាប៉ុន្មាននាក់ដែរអ្នកស្រី?

**ឆ៖** នៅពេលនោះ ខ្ញុំអត់បានរៀបរាប់បានទេចាស គ្រាន់តែខ្ញុំចោលភ្នែកពីលើឡានទៅ ឃើញអ៊ីចឹងមែន ហើយខ្ញុំសួរគេថា គាត់មកពីណា? ថាសុទ្ធពួកចេញពីពេទ្យហើយ! ព្រោះគ្រែហ្នឹងគ្រែពេទ្យតែម្តង ហើយបន្ដោងសេរ៉ូមស្រាប់ទៀត ហើយក៏សួរគេតទៅទៀតថា ហើយចុះអ្នកផ្សេងទៀត អ្នកជំងឺផ្សេងទៀតដែលនៅក្នុងមន្ទីរពេទ្យ? ថារត់រប៉ាត់រប៉ាយអស់ហើយ អ្នកដើរបានដើរមក អ្នកដើរមិនបាន

សែងអង្រឹង។ អ្នកណាមានគ្រែ រុញគ្រែអ៊ីចឹងមកចាស គឺមកពីពេទ្យរុស្ស៊ី។

**សៈ** អ៊ីចឹងនៅក្នុងហេតុការណ៍ដែលគេជម្លៀសអ្នកជំងឺចេញពីមន្ទីរពេទ្យហ្នឹង តើអ្នកស្រីមានបានឃើញដោយផ្ទាល់ភ្នែកនូវទាហានខ្មែរក្រហមដែលកំពុងតែធ្វើការជម្លៀសនេះដែរទេ? ហើយបើសិនជាក្នុងករណីដែលអ្នកស្រីបានឃើញមានទាហានខ្មែរក្រហមទាំងនោះ តើអ្នកស្រីអាចរៀបរាប់បានទេថាពួកគេមានអាកប្បកិរិយាយ៉ាងម៉េចដែរចំពោះអ្នកជំងឺទាំងអស់នោះដែលត្រូវគេជម្លៀសចេញហ្នឹង?

[១៥:៣៧:២៦]

**ផៈ** នៅពេលនោះ ខ្ញុំឃើញយោធាខ្មែរក្រហមហ្នឹង គឺមានអាកប្បកិរិយា គឺមុខមាំៗ ស្ពាយកាំភ្លើងច្រូងច្រាង ភ្នែករវៀសមើលណេះ មើលណោះនាយអាយ ប៉ុន្តែឃើញអ្នកជំងឺហ្នឹងគាត់អត់មានយកចិត្តទុកដាក់ទេ ព្រោះគាត់គិតថាត្រូវតែជម្លៀសចេញ ទោះបីអ្នកឯងឈឺ អ្នកពិបាកយ៉ាងណាក៏ដោយ ចាស ធ្វើម៉េចឲ្យចេញឲ្យផុតពីភ្នំពេញ ចាស។

**សៈ** នៅក្នុងឯកសារដដែល ហើយនៅក្នុងទំព័រដដែលហ្នឹង អ្នកស្រីបានអះអាងថាអ្នកស្រីបានឃើញសាកសពនៅតាមផ្លូវនៅក្នុងភូមិព្រែកប្រា។ អ៊ីចឹងសំណួរជាដំបូងទាក់ទងនឹងចំណុចនេះ ខ្ញុំចង់សួរអ្នកស្រីថា តើភូមិព្រែកប្រាដែលអ្នកស្រីបាននិយាយនោះ មានទីតាំងនៅកន្លែងណាដែរ?

**ផៈ** ភូមិព្រែកប្រាហ្នឹងមានទីតាំងនៅគល់ -- ចាំមើលយើងទៅដល់គល់ស្ពានច្បារអំពៅហ្នឹង មានផ្លូវបត់ៗស្តាំនៅជួរទន្លេបាក់សាក់ហ្នឹងតែម្តង។ ប៉ុន្តែពេលដែលយើងធ្វើដំណើរទៅរាល់ថ្ងៃហ្នឹង ច្រើនតែចាម ទៅជាភូមិចាម រស់នៅសព្វថ្ងៃហ្នឹងចាស។

**សៈ** នៅពេលដែលអ្នកស្រីបានទៅដល់ភូមិនោះដំបូង តើអ្នកស្រីសង្កេតឃើញទិដ្ឋភាពនៅក្នុងភូមិនោះមានលក្ខណៈយ៉ាងម៉េចដែរ?

[១៥:៣៨:០៣]

**ផៈ** នៅពេលដែលខ្ញុំទៅដល់ដំបូងហ្នឹង គឺថា ខ្ញុំមានការស្រេកទឹក ក្តៅពេកធ្វើដំណើរមួយថ្ងៃវាស់ល្ងាចស្រេកទឹក អ៊ីចឹងទេ ខ្ញុំក៏ប្រាប់ទៅប្តីខ្ញុំថាឲ្យមើលកូន ខ្ញុំចុះទៅរកទឹក។ ដល់តែពេលខ្ញុំចូលទៅអើ វាព្រលប់ៗទៅហើយ វាមិនមើលឃើញអីច្បាស់ទេ ខ្ញុំទៅអើតមើលផ្ទះនោះ អូ៎ ឃើញខ្មោច ទៅអើតនៅក្នុងអង្រឹងឃើញកូនក្មេង ខ្ញុំចេញហើយ ខ្ញុំទៅមើលកន្លែងផ្សេងទៀតក៏ឃើញខ្មោចទៀត ពីរបីផ្ទះហ្នឹងដល់តែឃើញខ្មោចអ៊ីចឹង ខ្ញុំដូចថាមានទឹកចិត្តហ្នឹងបាក់ស្បាតណាស់ ស្រឡាំងកាំង ហើយខ្លាចបំផុតព្រោះយើងអត់ដែលឃើញខ្មោចអីរដូករណែលអ៊ីចឹងទេចាស។ នាងខ្ញុំក៏បានចេញមកក្រៅ ចាសជួប

បងប្អូនផ្សេងទៀត គេថាអញទៅក៏ឃើញខ្មោចដែរ! ហើយមិនដឹងថាស្លាប់យ៉ាងម៉េច យើងក៏អត់ដឹងដែរ ចាស។

**ស៖** សាកសពដែលអ្នកស្រីបានឃើញហ្នឹង តើជាសាកសពថ្មី ឬក៏សាកសពចាស់? ចង់បានន័យថា ជាសាកសពដែលមានក្លិនស្អុយ ហើយឬនៅ?

**ឆ៖** នៅពេលនោះ ដូចជាមិនទាន់មានក្លិនអីស្អុយអីខ្លាំងទេ បើសិនជាស្អុយ យើងអត់ហ៊ានចូលទៅទេ ចាស។ មានក្មេងនៅក្នុងអង្រឹង មានមនុស្សចាស់ មានស្ត្រី។

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំសូមបន្តដំណើររបស់អ្នកស្រីទៅទៀត នៅពេលដែលអ្នកស្រីធ្វើដំណើរចេញពីផ្ទះ។ នៅក្នុងឯកសារដដែល នៅក្នុងទំព័រដែលមាន ERN ជាភាសាខ្មែរលេខ 00373246 ដល់ 47, ជាភាសាអង់គ្លេស 00379157, ជាភាសាបារាំង 00422448 -- 49 សូមទោស។

[១៥:៤០:៥៣]

ពេលនោះ អ្នកស្រីបាននិយាយថា “ខ្ញុំមិនអាចបន្តដំណើរទៅមុខ ដោយសារខ្ញុំនៅសរសៃខ្ចី ទើបតែឆ្លងទន្លេ ហើយគ្រុនទៀត។ គ្រួសារខ្ញុំបានចុះពីឡាននៅវត្តស្វាយប្រទាល ហើយឡាននោះ ក៏បន្តដំណើរទៅមុខទៀត។ ហើយយើងស្នាក់នៅវត្តនោះ ប្រហែល២អាទិត្យ”។ អ៊ីចឹងត្រង់ចំណុចហ្នឹង ខ្ញុំចង់សួរអ្នកស្រីបន្តទៀតថា តើសាច់ញាតិអ្នកស្រីណាខ្លះ បានបន្តដំណើរទៅមុខទៀត? ហើយហេតុអ្វីបានជាគេមិននៅជាមួយនឹងអ្នកស្រី បែរជាទៅមុខទៀត?

**ឆ៖** នៅពេលនោះ ខ្ញុំឆ្លងកាត់ឃុំកោះក្របី ហើយខ្ញុំក៏ឆ្លងកាត់រហូតដល់ល្វាច ខ្ញុំទៅដល់ឃុំស្វាយប្រទាល ស្រុកស្អាង។ ទៅដល់មានវត្តមួយ ខ្ញុំក៏សម្រាកនៅទីនោះ ហើយពេលនោះ ខ្ញុំស្រៀវរងាញាក់រហូត ក្នុង១ថ្ងៃខ្ញុំញាក់ពីរទៅបីដង។ អ៊ីចឹង ប្ដីខ្ញុំថា អ៊ី មិនអាចបន្តដំណើរទៅទៀតទេ ត្រូវសម្រាកនៅវត្តនេះសិន ចាំគិតទៀត។ ហើយនៅពេលនោះ បងជីដូនជាមួយខ្ញុំ ដែលនៅផ្ទះជាមួយគ្នាគាត់ក៏ឈប់នៅទីនោះ ចុះនៅទីនោះដែរ។ គាត់រើអីវ៉ាន់ រើអី ចុះនៅសម្រាកនៅវត្តហ្នឹងដែរ។

ក្រោយមក អ្នកឡានហ្នឹងគេសួរយើងថា ទៅមុខទៀតអត់? ហើយខ្ញុំថា ប្ដីខ្ញុំឆ្លើយថា “ខ្ញុំមិនអាចទៅបានទេ ព្រោះប្រពន្ធខ្ញុំសរសៃខ្ចី ហើយ១ថ្ងៃញាក់ពីរបីដងអ៊ីចេះ ទៅអត់រួចទេ។ អ៊ីចឹង បងចង់ទៅដល់ណាទៀត ក៏ទៅ ទៅ”។ ហើយគេថា គេទៅមុខទៀតហើយ ព្រោះគេប្រាប់ថាទៅមុខទៀត ទៅជួបអង្គការ។ ជួបអង្គការបានៗស្រួល។ អ៊ីចេះ តែខ្ញុំមិនដឹងថា អង្គការស្អី អត់ដឹងដែរ ចាស។

**ស៖** ទាក់ទងនឹងបញ្ហាសុខភាពរបស់អ្នកស្រី ខ្ញុំមានសំណួរមួយទៀត សួរបន្តទៀត។ ស្ថានភាព

ស្នាក់នៅរបស់អ្នកស្រីនៅភូមិស្វាយប្រទាលហ្នឹង តើមានលក្ខណៈដូចម៉េចដែរ? ជាពិសេសទាក់ទងជាមួយនឹងវិធានការរបស់ទាហាហាខ្មែរក្រហមដែលគេបានធ្វើ ចំពោះប្រជាជនដែលកំពុងត្រូវជម្លៀស។ ទាក់ទងជាមួយនឹងការផ្គត់ផ្គង់អាហារ ជម្រក ថ្នាំពេទ្យ ហើយជាពិសេសករណីរបស់អ្នកស្រី គឺដោយឡែក ដោយសារអ្នកស្រីកំពុងតែឈឺ ហើយមានកូនតូចៗពីរនាក់ ដែលអ្នកស្រីត្រូវមើលថែ ដែលពួកគេជាកុមារតូចៗ ហើយទាមទារឲ្យមានការយកចិត្តទុកដាក់ និងថែរក្សាសុខភាពរបស់គេ។ តើខ្មែរក្រហមនៅពេលនោះមានវិធានការដូចម្ដេចដែរ ចំពោះក្រុមមនុស្សដូចជាអ្នកស្រីអ៊ីចឹង?

[១៥:៤៣:១១]

**ឆៈ** នៅពេលនោះ គឺថាខ្ញុំដូចជាគ្មានឃើញទាហានខ្មែរក្រហមមានវិធានការអ្វីចំពោះប្រជាជនថ្មីហ្នឹងទេ ចាស។ ខ្ញុំចេះតែរស់នៅរយៈពេល៤ទៅ៥ថ្ងៃ។ ពេលនោះ ខ្ញុំទៅដល់ភ្លាម ខ្ញុំអត់មានអង្ករដាំបាយទេ ព្រោះខ្ញុំទៅពីនេះទៅ ញ៉ាំបាយអស់ហើយ ដល់បាយអស់ ត្រូវអត់មានអង្ករដាំទៀតទេ។ អ៊ីចឹងខ្ញុំបានដើរចូលភូមិគេ ហើយគេថា នៅទីនេះ ទោះបីអ្នកមូលដ្ឋាន ក៏អត់មានអង្ករហូបដែរ។ គេយកពោតយកមកកិនជាន់ទៅជាអង្ករពោត។ ដូច្នេះ ខ្ញុំថា ស្អីក៏បានដែរ ឲ្យដែលជួយចែករំលែកដូរមកខ្ញុំ ខ្ញុំក៏សម្ភារៈខ្លះ យកទៅដូរជាអង្ករពោត យកមកដាំហូបៗ។ នៅពេលនោះហើយដែលកូនស្រីរបស់ខ្ញុំ កូនប្រុសរបស់ខ្ញុំ កើតជំងឺរាកមួលឈាម ព្រោះគ្នាក្មេងផង ហើយធ្លាប់តែហូបបាយបញ្ចុក ហើយដល់ទៅលេងហូបអង្ករពោត។ អ៊ីចឹងទេធ្វើឲ្យសុខភាពហ្នឹង ធ្វើឲ្យពោះវៀនហ្នឹង ក្រពះមិនទទួលបាន ទៅជាមានជំងឺប្រចាំកាយ គឺជំងឺរាកមួល។

ដល់នៅយូរប្រហែលជា៤, ៥ថ្ងៃហ្នឹងទៅ ហូបបាន៤, ៥ថ្ងៃហើយ ទើបអ្នកមូលដ្ឋាន ខ្ញុំចេះតែចូលទៅអង្គុយក្រោយពេលខ្ញុំគ្រុនញាក់ស្រៀវហើយ ខ្ញុំងើបដើរហើយ ឲ្យតែគ្រុនញាក់ស្រៀវហើយ ខ្ញុំងើបដើរហើយ ដើរសួរគេ ពីស្ថានភាព ពីអីអ៊ីចឹងទៅ។ គេប្រាប់ថា “នែ៎ៗ អ្អែង ទៅចុះឈ្មោះ ណ៎ា ទៅបើកអង្ករពីយោធា យោធាគេនៅ គេចង្អុលប្រាប់ខ្ញុំថា យោធានៅកន្លែងនោះ ទៅបើកអង្ករទៅ”។ ខ្ញុំក៏ធ្វើតាមគេ ចាស ទៅចុះឈ្មោះហើយ ក៏ទៅបើកអង្ករ គេឲ្យយើងមែន។ ក្នុងអង្ករ -- ក្នុងម្នាក់បានមួយកំប៉ុង ១ថ្ងៃ។ អ៊ីចឹងគ្រួសារខ្ញុំមានបួននាក់ ចាស បានបួនកំប៉ុងដែរ។

[១៥:៤៤:៥២]

ប៉ុន្តែទោះបីបានអង្ករមកហូបក៏ដោយ យើងនៅពិបាកម្ហូប។ ហើយពេលនោះ កូនខ្ញុំវាមានជំងឺប្រចាំកាយបាត់ទៅហើយ ព្រោះដោយសារគ្មានថ្នាំពេទ្យព្យាបាល។ មានដែរ គ្រុនក្ដៅបន្តិចបន្តួចដោយ

ពីផ្ទះទៅ ដល់អាចចំរាកមួលធ្វើទុករលាកពោះវៀនហ្នឹង គឺអត់មានតែម្ដ។ ធ្វើឲ្យកូនខ្ញុំទទួលជំងឺមួយប្រចាំកាយរហូត ចាស។

**ស៖** បន្តមកទៀតនៅក្នុងឯកសារដដែលហ្នឹង អ្នកស្រីបាននិយាយថា អ្នកស្រីបានចេញពីភូមិស្វាយប្រទាលហ្នឹង ហើយបានធ្វើដំណើរមកដល់ឃុំឈើទាល ស្រុកកៀនស្វាយ។ អ្នកស្រីបានប្រាប់សហចៅក្រមស៊ើបអង្កេត នៅក្នុងទំព័រដែលមានលេខ ERN ជាភាសាខ្មែរ 00373247, ភាសាអង់គ្លេស 00379158, ភាសាបារាំង 00422449។ អ្នកស្រីបានប្រាប់គាត់ថា “យើងចង់ទៅស្រុកខ្សាច់កណ្ដាល ដោយសារយើងដឹងថាម្ដាយរបស់ខ្ញុំនៅទីនោះ”។ អ៊ីចឹងត្រង់ចំណុចនេះ ខ្ញុំចង់សួរអ្នកស្រីបន្ថែមទៀតថា នៅក្នុងស្ថានភាពដែលកំពុងតែចលាចលបែបនេះ តើអ្នកស្រីបានដឹងដូចម្ដេចថាម្ដាយរបស់អ្នកស្រីនៅទីនោះ?

[១៥:៤៦:២២]

**ឆ៖** នៅពេលនោះខ្ញុំដឹងថា គ្រួសារខ្ញុំ ទាំងម្ដាយខ្ញុំ ទាំងម្ដាយធំខ្ញុំ បងប្អូនខ្ញុំទាំងអស់ គេបានទៅដល់ស្រុក -- ភូមិអញ្ចែងលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ដោយសារជីដូនមួយខ្ញុំនឹងគេដើររក ដើររកពួកខ្ញុំ ដល់ដើររកគេឃើញ គេជិះកង់ពីរមក។ ដល់គេឃើញខ្ញុំទៅ គេថា ណ៎! យើង បងប្អូនយើងនៅជុំគ្នាណោះអស់ហើយ។ អ៊ីចឹងមក! រៀបអីវ៉ាន់ទៅ។ ខ្ញុំក៏លើកអីវ៉ាន់ បងជីដូនមួយខ្ញុំក៏លើកអីវ៉ាន់មានទូលមានរែក មានអាណាត្រូវដឹកកង់ ដឹកកង់ ព្រោះយើងចេញទៅ មានដូចបងខ្ញុំគាត់មានកូនគាត់កំលោះៗអ៊ីចឹងណ៎ា គាត់អាចរែកទូលបានទៅ ដាក់កង់ អាណាសំខាន់ដាក់កងទៅ។ អ៊ីចឹងទៅយើងចុះពីឃុំស្វាយប្រទាល បកមកស្រុកកៀនស្វាយវិញ ត្រង់ឃុំឈើទាលៗ ហ្នឹងមានផ្លូវមួយត្រូវឡើងទៅឃុំដីឥដ្ឋ។ ចាស ខ្ញុំក៏ធ្វើដំណើរត្រឡប់មកហ្នឹងវិញ ដើម្បីទៅជួបម្ដាយខ្ញុំ ព្រោះថាយើង ខ្ញុំសរសៃខ្ចីឈឺ កូនខ្ញុំក៏ឈឺណ៎ះ ដូច្នេះបើបានជួបញាតិមិត្ត បងប្អូនម្ដាយហាក់ជួយសម្រាកកម្លាំង ជួយជាយោបល់ ជួយជាគំនិត ជួយជារកថ្នាំសង្កូវ ឫសឈើ ឫសព្រៃអីជួយព្យាបាល។ ចាស ទើបខ្ញុំមានបំណងត្រូវតែជួបអ៊ីចឹងតែម្ដង ទោះពិបាកស្រណុកយ៉ាងម៉េចក៏ដោយចាស។

[១៥:៤៧:៤៦]

**ស៖** សូមអរគុណអ្នកស្រី។ នៅក្នុងទំព័រដដែល អ្នកស្រីបានមានប្រសាសន៍តទៀតថា “ខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងបន្តដំណើរទៅមុខទៀតទេ ហើយយើងក៏មិនអាចត្រឡប់ក្រោយដែរ។ ប្រសិនបើយើងព្យាយាមត្រឡប់ក្រោយ ខ្មែរក្រហមនឹងសម្លាប់យើង”។ នៅត្រង់ចំណុចនេះ តើអ្នកស្រី

ដឹងរឿងនេះដោយរបៀបណា? តើមានគេគំរាមអ្នកស្រីមិនឲ្យទៅមុខ ឬក៏ថយក្រោយ ឬក៏យ៉ាងណា?

**ឆ៖** នៅពេលនោះគឺថាយើងដឹងពេលដែលយើងចេញដំណើរទៅ គឺថាមានកន្លែងយោធាគេកាត់តែម្តង គេដាក់របាំងឫស្សីកាត់អត់ឲ្យទៅទេ។ ហើយគេប្រាប់ថា "មិនបាច់ទៅមុខទៀតទេ ឲ្យចូលភូមិទៅ ទៅនៅទៅ! កុំឲ្យដើររតេតរតូតទៀត។ ចាំៗមើលអង្គការគេមានវិធានការអីឲ្យចូលភូមិ"។ តែខ្ញុំមិនអាចចូលបាន ខ្ញុំសម្រាកមែន សម្រាកនៅលើផ្លូវហ្នឹង ដោយថ្ងៃសម្រាក យប់ឡើងខ្ញុំលួចរត់ ចាស។ រាល់យប់លួចរត់ ប៉ុន្តែរត់អត់រួច រត់ទៅយោធាដឹង គេបង្អាក់ឲ្យមកវិញ។ ៤យប់ ទម្រាំដែលខ្ញុំរួចរត់រួច។ ពេលនៅពេលនោះមុននឹងខ្ញុំរត់រួចហ្នឹង គឺបងប្អូនជីដូនខ្ញុំគេអស់ចិត្តហើយ គេលែងនៅចាំខ្ញុំហើយ។ អ៊ីចឹងគេយកកង់ជិះទៅវិញបាត់ហើយ គេឈប់នៅទទួលយើងហើយ។ អ៊ីចឹងខ្ញុំត្រូវរត់ពីរនាក់ប្តីប្រពន្ធហ្នឹងដោយទូលផង រែកផង កូនចងពីមុខ កូនតូចចងពីមុខ កូនធំចងពីក្រោយ ហើយទូល ហើយយួរទៀត ហើយប្តីខ្ញុំរែក ចាស។ ព្រោះយើងអត់មានអីដឹកៗ ស្បៀងទៀតទេ ដឹកអីវ៉ែអីវ៉ាន់ទេ មានតែកម្លាំងកាយរបស់យើង។

[១៥:៤៩:២៤]

ពេលនោះដោយសារខ្ញុំចិត្តចង់ជួបម្តាយខ្ញុំពេក ខ្ញុំគិតពីរឿងថា ខ្ញុំសរសៃខ្ចី ខ្ញុំមានជំងឺអី លែងគិតតែធ្វើម៉េចឲ្យដល់ជួបម្តាយរបស់ខ្ញុំ។ ហើយនិយាយពីជួនមួយខ្ញុំ ដែលថាចុះឡានជាមួយខ្ញុំ ឃុំស្វាយប្រទាល អត់ទៅមុខរួចហ្នឹង រយៈពេល៣, ៤ យប់ហ្នឹង គេថា "អ្អេ! គេអត់ទៅទៀតទេ បើយោធាមិនឲ្យទៅ គេទៅភូមិហើយ"។ អ៊ីចឹងនៅពេលនោះ នៅតែគ្រួសារខ្ញុំបួននាក់ទេ ពីរនាក់ប្តីប្រពន្ធ និងកូនពីរហ្នឹងទេដែលព្យាយាមរត់ចាស។ រត់រហូតដល់រួច។

**ស៖** សូមអរគុណអ្នកស្រី។ ដូច្នេះ ប្រសិនបើយើងអាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រី ព័ត៌មានដែលអ្នកស្រីបានប្រាប់ទៅដល់សហចៅក្រមស៊ើបអង្កេត គឺអ្នកស្រីបានប្រាប់ថា អ្នកស្រីត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ឆ្លងកាត់តាមមន្ទីរពេទ្យរុស្ស៊ី កាត់តាមភូមិព្រែកប្រា ឃុំកោះក្របី ស្រុកកៀនស្វាយ ខេត្តកណ្តាល, ភូមិស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល, ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល រហូតមកដល់ភូមិអញ្ចេញលើ ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តខ្សាច់កណ្តាល -- ខេត្តកណ្តាល គឺជាកន្លែងដែលម្តាយរបស់អ្នកស្រីស្នាក់នៅ។ អ៊ីចឹងសរុបមកវិញ ខ្ញុំចង់សួរអ្នកស្រីថា តាមផ្លូវពីភ្នំពេញរហូតដល់ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលហ្នឹង តើអ្នកស្រីមានបានឃើញទាហានខ្មែរក្រហម គេបានឆែកមើលពីប្រវត្តិរូបរបស់ប្រជាជនដែលកំពុងតែត្រូវបានជម្លៀសនៅតាមផ្លូវហ្នឹង

ដែរឬទេ?

[១៥:៥០:៥៧]

**ឆ៖** ខ្ញុំអត់បានឃើញទេនៅពេលនោះ ប៉ុន្តែខ្ញុំសូមឆ្លងទៅបន្តិចចុះ ឈានទៅមុខបន្តិច។ ពេលដែលខ្ញុំទៅដល់ ជួបម្ដាយខ្ញុំ ទើបម្ដាយខ្ញុំប្រាប់ថា បងថ្លៃខ្ញុំដែលជាទាហានពាក់សក្តិ៥ហ្នឹង ត្រូវគេប្រមូលចូលភ្នំពេញអស់ហើយ។ គេថាអ្នកណាដែលជាទាហានប្រមូលចូលទៅភ្នំពេញវិញ ដើម្បីធ្វើការងារបន្តទៅមុខទៀតចាស។ ខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹងចាំះ។

**ស៖** សូមអរគុណអ្នកស្រី។ អីចឹងដើម្បីភ្ជាប់ទៅនឹងការដែលគេជម្លៀសអ្នកស្រីនៅក្នុងដំណាក់កាលទី២ ខ្ញុំសូមសួរអ្នកស្រីទាក់ទងជាមួយនឹងកាលដែលគេចាត់ចែងទទួលអ្នកស្រីបណ្ដោះអាសន្ននៅក្នុងសហករណ៍ដែលអ្នកស្រីបានទៅដល់ គឺនៅក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលហ្នឹង។ នៅពេលដែលអ្នកស្រីបានទៅដល់ទីនោះ តើកម្មាភិបាលខ្មែរក្រហម គេបានទទួលអ្នកស្រី និងប្រជាជនដែលត្រូវបានគេជម្លៀសទៅឯទៀតយ៉ាងរបៀបម៉េចដែរ? គឺខ្ញុំចង់សំដៅទៅលើការរៀបចំការស្នាក់នៅ ការចាត់ចែងឲ្យធ្វើការ ក៏ដូចជាការបង្រៀនផ្សេងៗ ដែលគេចង់បង្រៀនទៅដល់ប្រជាជនដែលទើបតែទៅដល់ថ្មីហ្នឹង? តើមានទេ?

[១៥:៥២:០១]

**ឆ៖** ចាស នៅពេលនោះ ពេលដែលខ្ញុំទៅដល់ភ្លាម ខ្ញុំបានទៅស្នាក់នៅ ខ្ញុំទៅចុះឈ្មោះជាមួយនឹងមិត្ត យន។ មិត្ត យន ហ្នឹងជាមេក្រុម ហើយជាញាតិទៀត ស្គាល់គ្នា។ ម្ល៉ោះហើយខ្ញុំបានទៅចុះឈ្មោះនៅជាមួយនឹងក្រុមរបស់គាត់។ គាត់ក៏ឲ្យខ្ញុំទៅសំណាក់ម្ដាយខ្ញុំ ខ្ញុំអីទៅសំណាក់នៅផ្ទះគាត់។ ផ្ទះគាត់ហ្នឹងធំណាស់។ ផ្ទះគាត់ធំ អ្នកដែលគេហៅថា ផ្ទះអ្នកមានស្រុកចម្ការចាស។ ផ្ទះធំណាស់ អាចដាក់បានបួនប្រាំគ្រួសារ គឺរលុង។ ដល់អីចឹង ខ្ញុំទៅសំណាក់នៅទីនោះ។ ហើយខ្ញុំទៅធ្វើការងារកងចម្ការ។ មុនដំបូងទៅកាប់ៗភ្លឺ កាប់អីដូចថាវាមិនទាន់ភ្លៀងធ្លាក់អីជោគបានទៅធ្វើស្រែទេ។

ហើយដល់ក្រោយមក ទើបគេចែកដីឲ្យខ្ញុំសង់ផ្ទះ។ ពេលនោះខ្ញុំ និងម្ដាយខ្ញុំគិតទៅសរុបទៅមាន១០នាក់សង់ផ្ទះមួយហ្នឹង នៅជុំគ្នា គេឲ្យដី ដោយដោយដូរឫស្សី ដូរស្លឹកអីធ្វើខ្ទមមួយនៅខ្លួនយើង។ ហើយបងប្រុស និងបងស្រីខ្ញុំពីរនាក់ប្តីប្រពន្ធ គាត់អត់មានកូនទេ គាត់សង់ផ្ទះនៅជិតនោះដែរចាស។ ហើយយើងបានទៅធ្វើការព្រឹកអីចឹងចេញទៅ ខ្ញុំថ្ងៃត្រង់មកវិញ បើប្តីខ្ញុំព្រឹកអីចឹងចេញទៅ ថ្ងៃត្រង់មកវិញ ដូចគ្នាចាស មកមើលកូននៅផ្ទះហ្នឹង។

[១៥:៥៣:១៥]

ហើយក្រោយមក រដូវចភ្លៀង ខ្ញុំក៏បានទៅស្ទូងដកអីដូចគេអីចឹង ប៉ុន្តែពេលនោះខ្ញុំអត់ចេះទេ។ អីចឹងទេ ខ្ញុំត្រូវរៀន ខ្ញុំត្រឡប់មកយប់ៗ ខ្ញុំខំប្រឹងដកជើងថយ ថាគេស្ទូងដកជើងយ៉ាងម៉េច ថយយ៉ាងម៉េច ទៅមុខម៉េច ណា៎ះ ! ព្រោះខ្ញុំខ្លាចគេសម្លាប់ ខ្ញុំប្រឹងធ្វើការណាស់ចាស។ ហើយមានម្តងកាលណានោះ ខ្ញុំទៅៗស្ទូងនៅ ដែលគេហៅៗស្ពានព្រែកកង់វ៉ាន់ៗហ្នឹង ខ្ញុំទៅស្ទូងនៅស្រែខាងហ្នឹង។ នៅរាល់ថ្ងៃនៅឃុំពុកឫស្សីហ្នឹងចាស។ ដល់ពេលខ្ញុំអត់ដឹង គេប្រាប់ថា មកឆ្លងទឹកមកៗទៅធ្វើស្រែនៅណោះ។ ខ្ញុំវាអត់ដឹង ហើយវាអត់ចេះហែល គេក៏អត់ដឹងថាខ្ញុំអត់ចេះហែល ខ្ញុំក៏ឆ្លងទៅ ខ្ញុំលង់ភ្លឹបទៅ បានពួកស្រីៗវ៉ៃយកណ្តាលហ្នឹង ដែលទៅធ្វើការជាមួយគ្នាហ្នឹង គេស្គាល់អាណិតខ្ញុំ គេបោចសក់ឡើងមកចាស។ លង់ទឹកមួយពេលហ្នឹងមួយសាទៅចាស។ ហើយតាំងពីថ្ងៃហ្នឹងមក ខ្ញុំខិតខំទៅធ្វើស្រែ ធ្វើដកស្ទូងអី ធ្វើម៉េចឲ្យដូចប្រជាជនថ្មីអីចឹង ប៉ុន្តែ--

[១៥:៥៤:១៨]

**ស៖** ចាស សូមអរគុណអ្នកស្រី ខ្ញុំសូមកាត់អ្នកស្រីត្រឹមកន្លែងនេះ ព្រោះខ្ញុំមានសំណួរសំខាន់តទៀតសួរដល់អ្នកស្រី។ អ្នកស្រីអាចរៀបរាប់ពីទុក្ខសោករបស់អ្នកស្រី នៅដូចដែលលោកប្រធានបានមានប្រសាសន៍ជម្រាបអ្នកស្រីអីចឹង នៅពេលដែលអ្នកស្រីថ្លែងអំពីទុក្ខសោករបស់អ្នកស្រី។

អម្បាញ់មិញអ្នកស្រីបាននិយាយអំពីបុគ្គលម្នាក់ឈ្មោះ យន។ អីចឹង ខ្ញុំសូមនាំអ្នកស្រីទៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រីដដែលហ្នឹង នៅក្នុងឯកសារដែលមានទំព័រលេខ ERN ជាភាសាខ្មែរត្រង់ទំព័រ 00373247 ទៅដល់ 48, ជាភាសាអង់គ្លេស 00379158 និងជាភាសាបារាំង 00422450។ អ្នកស្រីបានមានប្រសាសន៍ថា "យន ជាប្រធានក្រុមខ្មែរក្រហម ហើយក៏ត្រូវជាបងប្អូនអ្នកស្រីដែរ។ ហើយគាត់បានជួយលាក់អត្តសញ្ញាណគ្រួសាររបស់អ្នកស្រីដែលជាទាហាន លន់ នល់"។ អ្នកស្រីអាចបញ្ជាក់បានទេថា អ្នកស្រីបាន -- ហេតុអ្វីបានជាអ្នកស្រីដឹងថា គាត់ហ្នឹងបានជួលលាក់អត្តសញ្ញាណរបស់អ្នកស្រី?

**ឆ៖** ខ្ញុំដឹងដោយសារប្រពន្ធរបស់ យន ហ្នឹងប្រាប់ខ្ញុំ។ ប្រាប់ខ្ញុំថា ដូចថា ប្រពន្ធ យន ហ្នឹងគាត់ស្គាល់ ព្រោះប្រពន្ធ យន ហ្នឹងត្រូវជាប្អូនរបស់ពូថ្លៃខ្ញុំ។ ដល់អីចឹងគេស្គាល់ខ្ញុំច្បាស់ណាស់ថា ខ្ញុំពី -- នៅផ្ទះហ្នឹងធ្វើអីពីមុនមក គ្រួសារខ្ញុំមានស្ថានភាពបែបណា គេដឹងច្បាស់ណាស់។ អីចឹងហើយគេក៏បានប្រាប់ខ្ញុំថា មកនៅទីនេះ កុំប្រាប់គេឲ្យសោះ ប្រាប់បងប្រាប់ប្អូន ប្រាប់កូនចៅ បើគេសួរថា ធ្វើអី? ប្តីធ្វើ

អី? ប្រាប់ថា រត់ឡាំប្រើតា។ កុំប្រាប់គេថា ធ្វើការងារ ទោះបីការងារទាហាន មិនទាហានក៏ដោយឲ្យតែធ្វើការងាររដ្ឋ កុំនិយាយឲ្យសោះ។ បើសិនជាអ្នករកស៊ីអត់អីទេ។

[១៥:៥៦:១៥]

ដូច្នេះ ខ្ញុំក៏ប្រាប់កូនប្រាប់ចៅខ្ញុំ ហើយពីពេលនោះមក យន ហ្នឹងចេះតែជួយលាក់ខ្ញុំ ព្រោះអត់បែកការណ៍។ ជួយលាក់រហូត ដែលដឹងដោយសារម្នាក់ទៀតនោះ ដែលមានប្ដីគាត់ធ្វើទាហានដែរ ហើយទៅស្នាក់នៅផ្ទះហ្នឹងដែរ ហើយបងប្អូនជាមួយ យន ហ្នឹងជិតជាងខ្ញុំ។ ម្ល៉ោះហើយអ្នកស្រុកអ្នកភូមិគេស្គាល់ច្បាស់។ ដល់អ៊ីចឹងគេស្គាល់ច្បាស់ទៅ គេដឹង គេសម្គាល់ដឹងហ្នឹងគេយកប្ដីគាត់ហ្នឹងទៅបាត់តែម្ដង បាត់ដោយមិនឃើញមកវិញ។ យប់ឡើងឲ្យរៀបអីវ៉ាន់ទៅ មិនដឹងទៅដល់ណាចាស។ បាត់រហូតទើបគាត់ប្រាប់ពួកខ្ញុំអ៊ីចឹងថា ឲ្យលាក់ឲ្យមែនទែន អត់មានអ្នកណាដឹងទេនៅនេះចាស។

**ស៖** ចាស សូមអរគុណអ្នកស្រី។ ខ្ញុំនឹងបន្តសំណួរចូលទៅកាលដែលគេជម្លៀសអ្នកស្រីនៅក្នុងដំណាក់កាលទី២ ចេញពីស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ទៅស្រុកបាកាន ខេត្តពោធិ៍សាត់។ នៅក្នុងឯកសារដែលអ្នកស្រីបានបញ្ជាក់ថា "មេភូមិឈ្មោះ ប៉ាត បានមកដល់ផ្ទះរបស់យើង និងបានប្រាប់យើងថា យើងត្រូវតែរៀបចំអីវ៉ាន់ដើម្បីចាកចេញទៅខេត្តបាត់ដំបង"។ ហើយអ្នកស្រីបានមានប្រសាសន៍ថា "មានតែអ្នកចំណូលថ្មីទេ ដែលត្រូវបានគេបញ្ជូនចេញ"។ អ៊ីចឹងខ្ញុំមានពីរបីសំណួរ ត្រង់កន្លែងនេះចង់សួរអ្នកស្រី។ តើពាក្យថា "អ្នកចំណូលថ្មី" ដែលអ្នកស្រីបានមានប្រសាសន៍ហ្នឹង តើអ្នកស្រីសំដៅទៅលើក្រុមមនុស្សប្រភេទណាដែរ?

[១៥:៥៧:៤២]

**ឆ៖** អ្នកចំណូលថ្មីដែលខ្ញុំនិយាយសំដៅហ្នឹង គឺអ្នក១៧មេសា។ អ្នកដែលត្រូវជម្លៀសចេញពីភ្នំពេញមក អ្នក១៧មេសា ហើយទើបតែមកថ្មីៗដូចពួកខ្ញុំអ៊ីចឹង ចាស។

**ស៖** សូមអរគុណអ្នកស្រី។ នៅពេលដែលមេភូមិនោះ បានប្រាប់អ្នកស្រីឲ្យចាកចេញពីផ្ទះអ្នកស្រីនៅក្នុងខេត្តកណ្ដាលហ្នឹង ដើម្បីទៅខេត្តបាត់ដំបងហ្នឹង តើគាត់មានប្រាប់អ្នកស្រីទេថា គាត់បានទទួលបញ្ជាឲ្យអ្នកស្រីចាកចេញហ្នឹងពីអ្នកណាដែរ?

**ឆ៖** ពេលនោះ គាត់មិនបានប្រាប់ខ្ញុំថាម៉េចទេចាស។ គ្រាន់តែប្រាប់ថា ឲ្យរៀបរាប់អីវ៉ាន់ទៅអ្នកថ្មីហ្នឹងគេយកទៅរស់នៅខេត្តបាត់ដំបងវិញ គេជម្លៀសទៅនោះវិញ ព្រោះនៅនោះវាសំបូរ មានស្រូវមានអង្ករ មានត្រី មានផ្លែឈើអី នៅស្រុកយើងនេះដូចថា ទើបតែសន្តិភាពអ៊ីចឹងវាខ្វះខាត។ ចាស គ្រាន់

តែប្រាប់ប៉ុណ្ណឹងចាស។

[១៥:៥៨:៥០]

**ស៖** សូមអរគុណអ្នកស្រី។ អ្នកស្រីនិយាយអំពីឈ្មោះ ប៉ាត ជាមេភូមិ អ៊ីចឹងអ្នកស្រីអាចបញ្ជាក់ជូនតុលាការបានទេថា ឈ្មោះ ប៉ាត ហ្នឹងក្នុងតំណែងគាត់ជាមេភូមិហ្នឹង តើគាត់ស្ថិតនៅក្នុងឋានានុក្រមបែបណាដែរ នៅក្នុងជួររដ្ឋអំណាចរបស់ខ្មែរក្រហមនៅពេលនោះ អ្នកស្រីអាចដឹងបានទេ?

**ឆ៖** ខ្ញុំមិនអាចដឹងបាន គ្រាន់តែដឹងថា គេប្រាប់គាត់ហ្នឹងជាមេភូមិ ហើយនៅក្នុងភូមិហ្នឹងវាចែកជាក្រុម។ មានក្រុម មានក្រុមនេះៗអ៊ីចឹងទៅចាស។ ដឹងតាមរយៈគេប្រាប់ទេចាស ឲ្យថាក្នុងជួររដ្ឋកម្មាភិបាលហ្នឹង ខ្ញុំអត់ដឹងទេ។

**ស៖** តើមេភូមិហ្នឹងគាត់មានបានប្រាប់អ្នកស្រីទេ ពីមូលហេតុដែលថាមានតែអ្នកស្រី ហើយនិងអ្នកចំណូលថ្មីផ្សេងទៀត ត្រូវបញ្ជូនចេញទៅខេត្តបាត់ដំបង? ហេតុអីក៏មិនមែនជាក្រុមមនុស្សប្រភេទផ្សេងទៀតនៅក្នុងតំបន់នោះ មានតែអ្នកចំណូលថ្មី? គាត់មានប្រាប់ពីមូលហេតុទេ?

**ឆ៖** គាត់ប្រាប់ដែរ គាត់ប្រាប់ថា យើងទៅបាត់ដំបងទៅ ព្រោះវាសំបូរស្រូវសំបូរអង្ករ ហើយអង្គការដូចថា នៅទីនេះយើងទទួលបានចំណុះតែប៉ុណ្ណឹងៗគ្រួសារ ប៉ុណ្ណោះគ្រួសារទេ។ អ៊ីចឹងលើសវាអាចខ្វះខាតអីអ៊ីចឹងណ៎ា ឲ្យយើងទៅៗគឺដឹងតែសប្បូរតែម្ដងទៅដល់នោះ។ ហើយយើងដឹងស្រាប់ហើយ ឮតែបាត់ដំបង អើយសប្បាយចិត្តណាស់ ចាស ខេត្តស្រូវហើយ។

[១៦:០០:២៥]

**ស៖** អ៊ីចឹង តើអ្នកស្រីអាចបញ្ជាក់ជូនតុលាការបានទេថា អ្នកណាជាអ្នករៀបចំឲ្យអ្នកស្រីចាកចេញពីផ្ទះរបស់អ្នកស្រី នៅស្រុកខ្សាច់កណ្ដាលហ្នឹង ទៅឆ្ពោះទៅទិសដៅខេត្តបាត់ដំបង? អ្នកណាជាអ្នករៀបចំការធ្វើដំណើរទាំងអស់ហ្នឹង?

**ឆ៖** គឺមេភូមិហ្នឹងតែម្ដងចាស។ ពេលដែលខ្ញុំរៀបអីវ៉ាន់ហើយ គេយករទេះមកបញ្ឈរមុខផ្ទះយើងក៏ជញ្ជូនអីវ៉ាន់ដាក់លើរទេះ ហើយគេប្រាប់ទៀត អ្នករទេះហ្នឹងគេៗមានតួនាទីរបស់គេ គេដឹងថាត្រូវដឹកយើងទៅណា ទៅដល់ណា ត្រូវដាក់យើងត្រឹមណា ចាស។

**លោកស្រី ម៉ុច សុវណ្ណារី៖**

សូមគោរពលោកប្រធាន ខ្ញុំមានសំណួរប្រហែលជាប្រាំ-ប្រាំមួយសំណួរទៀត ដើម្បីសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលនេះ ហើយខ្ញុំឃើញថា ពេលវេលាដល់ម៉ោងសម្រាកហើយ។ ដូច្នេះ ខ្ញុំគួរបន្ត

ឬក៏ចាំថ្ងៃស្អែក?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះ ក៏សូមជម្រាបជូនភាគី សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងតំណាងសហព្រះរាជអាជ្ញាផងដែរថា ពេលវេលានៃការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ភាគីទាំងពីរមានពេលវេលាតែមួយពេលទេ មួយព្រឹក។ ហើយឥឡូវនេះអស់មួយម៉ោងហើយ ហើយនៅសល់ស្អែកគឺមានតែម៉ោងទី១ នៃពេលព្រឹកប៉ុណ្ណោះ។ អ៊ីចឹងសូមរៀបចំនូវសំណួរធ្វើយ៉ាងណាឲ្យការប្រើប្រាស់ពេលវេលា ដែលបានកំណត់បែងចែកឲ្យនេះមានប្រសិទ្ធភាព។

អរគុណលោកស្រី ឡាយ បូនី។ កិច្ចដំណើរការសវនាការថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២៤ ខែតុលា ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ឡាយ បូនី។

លោកស្រី ឡាយ បូនី ការស្ដាប់សក្ខីកម្មរបស់លោកស្រី នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មលោកស្រីនៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះកោះអញ្ជើញលោកស្រីមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

[១៦:០២:៤១]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ ហើយនិងឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*